

កម្មវសុនយា

ប្រុងបិទ្ធិតាស្រមនឆ្នាប់
ទស្សនាវដ្ត្រី ផ្សាយខាងសាសនា នឹង អក្សរសាស្ត្រ
COMMISSION DES MOEURS & COUTUMES

ឆ្នាំទី ៤២ ខែ ឧសភា

ព.ស. ២៥១៤ គ.ស. ១៩៧០

-ភ្នំពេញ-



អម្ពុជសុនយា

ទស្សនាវដ្ឋី ផ្សាយទាងសាសនា និង អក្សរសាស្ត្រ

បេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : លាង ហ័បអាន

និពន្ធនាយក-អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះមុនីកោសល ស្ងរ-ហាយ

លោក លិម-លាឥដិន លោក ឌីតា-តាម

លោក ផល-ធិត លោក ព្រួច-ភុម

អ្នកស្រី ពេជ-សល់

មញ្ជីរឿង

អត្ថបទ	ទំព័រ

វិជ្ជកសាសនា

១— កើតទៀតឬទេ ? (ត) ព្រះមហារីរិយបណ្ឌិតោ ប៉ាង-ទាត់ រៀបរៀង . .	៤៦៣
២— អត្តនាថកថា ព្រះពុទ្ធវង្ស សេក - នាង រៀបរៀង	៤៨៩

វិជ្ជកអក្សរសាស្ត្រ

៣— រឿងសាមកុក ណេក ឧកញ៉ា នូ-កន ប្រែរៀបរៀង	៤៩៨
៤— រឿងគ្រោះថ្នាក់នាវាដោយឧ្យល់ព្យុះ អ្នកស្រីពេផ-សល់ ប្រែរៀបរៀង . .	៥១០
៥— អំពីសត្វដែលគេចិញ្ចឹមក្នុងប្រទេសកម្ពុជា ឯកសារទំនៀមទម្លាប់ខ្មែរ ណេក ស្ទិ - សែម រៀបរៀង	៥២៥
៦ - រឿងវរវង្សសូរវង្ស ចម្លងចេញពីសាស្ត្រាស្លឹករឹត សហ. លី - ជាមតេង ពិនិត្យផ្ទៀងផ្ទាត់	៥៤២

ផ្ជកកំណត់ប្រវត្តិការណ៍

៣ - មរណភាពនៃណេក យឿន - ចឹម អតីតអត្តលេខាធិការ នៃ ពុទ្ធសាសនបណ្ឌិត្យ	៥៣៤

តម្លៃជាវ :

ម្ជយផ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ។

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ	ធ្វើការអាក្រក់
ជាការលាមក	ឲ្យធ្វើល្អទៅ,
ឲ្យជុំសខាត់ចិត្ត	កុំឲ្យហ្មងសៅ
បីនេះលោកហៅ	ពុទ្ធសាសនា ។

ប.ព

កើតទៀតឬទេ ?

ព្រះមហាវីរិយបណ្ឌិតោ ចាន់-ខាត់ រៀបរៀង

[តពីលេខមុន]

បទទីប្រាំមួយ

ជាតិគឺកំណើត កើតឡើងបានដូចម្ដេច?

ប្រស្នាដែលយើងនិយាយនេះ ជាចំណុចសារវន្ត មានអាថ៌សុខុមគម្ភីរភាព ហើយជាប្រស្នាដែលយើងជួញចិត្តគិតណាស់ទៀតផង គួរតែមានអត្ថាធិប្បាយមួយពិសេស ជួយបំភ្លឺសេចក្ដីឲ្យបានយល់ពិតតាមពិតតាមគន្លងពុទ្ធសាសនា ។

ឥឡូវ យើងសន្មតថា មានមនុស្សម្នាក់ឈឺធ្ងន់ ហើយដំតទិនស្លាប់ហើយ ៗ យើងគិតពិចារណាពីខណៈចិត្តទី ៧ ទៅ រាប់ត្រឡប់

ទៅមុនពេលមរណកាល តាំងពីពេលនោះ យើងពុំឃើញមានផ្នែកនៃសរីរាង្គណាមួយ ដើរជាថ្មីទៀតទេ ។ ពេលនេះ កម្មជរូប "រូបកើតអំពីកម្ម" ក៏មិនកើតទៀតដែរ ប៉ុន្តែកម្មជរូប ដែលបានសាងឲ្យកើតជាសរីរាង្គនៃមនុស្សសត្វ មុនពេលដែលខណៈចិត្តតាំងទៅហើយនោះ នៅមានឋិតថេរទៅឡើយ ហើយឋិតថេរនៅរហូតទៅដល់កាលចុតិចិត្តចុះក្រោយបង្អស់ ទើបផុតរលត់ទៅ(១) ។

ប្រស្នាល្អិតសុខុមចាក់ក្នុកស្មើរមិនយល់នេះ លោកប្រៀបដូចការកម្រើកញាប់ញ័រត្រីត្រាត់នៃអណ្តាតភ្លើងចង្កៀង មុនពេលដែលអណ្តាតភ្លើងចង្កៀងនោះនឹងរលត់ទៅ ។ ពេលនោះ សត្វស្លាប់ មើលឃើញច្បាស់នូវអារម្មណ៍ពីអតីតកាលរបស់ខ្លួន តាមផ្លូវចិត្តក្នុងមនោទ្វារ (មនោ-វិញ្ញាណ) ដែលភាសាធម៌លោកហៅថា កម្ម កម្មនិមិត្ត និងគតិនិមិត្ត ។ ធម៌ ៣ ប្រការនេះ មិនគឺអ្វីទេ គឺអំពើល្អ ឬ អាក្រក់ដែលបុគ្គលម្នាក់ ៗ បានធ្វើហើយ បង្កើតជានិមិត្តឲ្យឃើញ ។ ពេលនេះហើយដែលគេអាចកត់សម្គាល់បាន នូវដំណើរកម្ម ជាអំពើល្អក្តីអាក្រក់ក្តី នៃបុគ្គលម្នាក់ ៗ ដោយអាការរបស់កម្មនោះឯង គឺ

១- ក្នុងពុទ្ធសាសនា កម្មជរូបនេះ កើតមកពីធម៌ ៤ ប្រការគឺ ១- កម្មជាកុសលឬអកុសលក្នុងអតីតជាតិ ។ ២- ចិត្ត ឬ សង្ខារ ។ ៣- រដូវ គឺការផ្លាស់ប្តូរនៃរាងកាយ ឬ តេជោធាតុចាប់តាំងពីក្តៅត្រជាក់ជាដើមទៅ ។ ៤- អាហារ បានដល់អាហារដែលចិញ្ចឹមជីវិតិន្ទ្រិយឲ្យរស់នៅ ។

ក) កម្ម "អំពើ" ជាកុសល ឬ អកុសលនេះ ១ៃ:ជាកម្ម-
ក្ម "កម្មធ្ងន់" បើជាកុសល ចានដល់កម្មដែលបុគ្គលចម្រើនឈាន
សមាបត្តិ បើខាងអកុសល ចានដល(១)កម្មដែលបុគ្គលសម្លាប់មាតាបិតា
ឬ ព្រះអរហន្ត ។ល។ កម្ម១:ទៀត ឲ្យផលជិត ១ ជាកុសលក្តី
ជាអកុសលក្តី ចានដល់កម្មដែលបុគ្គលធ្វើក្នុងពេលជិតស្លាប់ ឬ កម្ម
របស់បុគ្គល ដែលទ្ធានចិត្ត១ខ១ឲ្យប្រសើរ ហើយមិនចានធ្វើអ្វីជា
អកុសលដ៏ធ្ងន់ផង ហៅថា អាសន្នកម្ម(២) "កម្មជិត" ពាក្យថា
អាសន្នកម្ម "កម្មជិត" នេះ ចានសេចក្តីថា កម្មដែលនៅជិតចិត្ត ឬ
ជាប់នឹងចិត្ត ចិត្តទៅណាទៅជាមួយផង ១ បមាដូចបង្ហើបទ្រព្យដែលបុគ្គល
ជាក់ជិតដៃ១ខ១ បើត្រូវការទៅណាក្ដាមលើកដៃលូកទៅចាប់បង្ហើបទ្រព្យ
នោះ ហើយកាន់ដើរចេញទៅ មិនចាប់រាល់អំពាល់ដើរទៅរកនៅទីឆ្ងាយ
ពីដៃ១ខ១ទេ ។ បើមិនមានអាសន្នកម្មនេះ ចូលមកកាត់ឲ្យផលទេ កម្ম
ដទៃទៀតជាកុសលក្តី ជាអកុសលក្តី ដែលបុគ្គលចានធ្វើ១ុកយូរហើយ

១- កម្មនេះ ឈ្មោះថា អនន្តរិយកម្ম "កម្មធ្ងន់ជាចំដុត" មាន ៥ យ៉ាង គឺ មាតុឃាត, បិតុឃាត, អរហន្តឃាត, ណេហ៊ីតុប្ផាទ, សង្ឆភេទ, ។ ២- អាសន្នកម្មនេះ ជាធម៌ មាន
អានុភាពខ្លាំងណាស់ អាចរារាំងបិទបាំងកម្មដទៀតទាំងអស់ មិនឲ្យចូលមកឲ្យផលមុនបាន ។
អាស្រ័យដោយហេតុនេះហើយ ប្រទេសកាន់ពុទ្ធសាសនា បង្កើតជាប្រពៃណីតាំពុទ្ធសាសនិក-
ជន ដែលប្រាថ្នាក្តីសុខ ឲ្យបំពេញកុសលក្នុងពេលមានជម្ងឺធ្ងន់ជិតស្លាប់ ដើម្បីឲ្យមានបុញ្ញនិធិ
"ចំណត់ទ្រព្យគឺបុណ្យឬបង្ហើបបុណ្យ" ឲ្យមាននៅជិតខ្លួន ស្លាប់ទៅ កាន់បង្ហើបបុណ្យទៅ
ជាមួយ១ ជាអារ៉ាយទ្រព្យ ជួនដំណើរ១ខ១ឲ្យទៅកើតក្នុងសុគតិ ។

តែមិនក្ងេច ទឹងចូលមកឲ្យផលដ៏ទ្ធ ។ កម្មនេះលោកហៅ អាចិណ្ណ-
កម្ម "កម្មដែលបុគ្គលធ្វើយូរហើយ តែមិនចេះក្ងេចសោះ ទឹកឃើញ
កម្មនេះជានិច្ច" ។ បើអាចិណ្ណកម្មនេះ មិនចូលមកឲ្យផលទេ មាន
កម្មមួយទៀត លោកហៅថា ឋានត្ថាកម្ម "កម្មស្រាល" ទឹងត្រូវ
ចូលមកឲ្យផល ។ កម្មនេះ សត្វឃើញអារម្មណ៍តែកន្ធមនោទ្វារទេ ។

១) ឋានូបមិត្ត "ឧបមិត្តឃើញកម្ម" ។ តាមធម្មតា សត្ត (កំពុងស្លាប់) ច្រើនតែប្រើអាយតនៈខ្លួនគឺភ្នែក ត្រចៀក ច្រមុះ អណ្ណាត
កាយ ឲ្យទទួលយកអារម្មណ៍ពីខាងក្រៅពុំបានទេ យើងអាចនិយាយបាន
ថា អាយតនៈទាំងនោះ ស្លាប់អស់មុនហើយទៅក៏បានដែរ ប៉ើនឹង
ឃើញ ឃើញបានតែធម្មារម្មណ៍កន្ធមនោទ្វារ ដែលជារូប សំឡេង
ក្លិន រស សម្ផស្ស របស់កម្មពីអតីតកាល ដែលកំពុងប្រព្រឹត្តទៅ, តែបើ
ឋានូបមិត្តនេះ ជាបច្ចុប្បន្ន, អ្នកស្លាប់នោះ ឃើញអារម្មណ៍ក្នុងទ្វារ
ទាំង ៥ បាន ។ ដូច្នេះ ឋានូបមិត្ត មានពីរយ៉ាង ជាអតីត ១ ជាបច្ចុ-
ប្បន្ន ១ ។ ឋានូបមិត្ត ជាអតីត ភ្ជាប់ប្រាកដនៅតែក្នុងមនោទ្វារ
ឯឋានូបមិត្តជាបច្ចុប្បន្ន ភ្ជាប់ប្រាកដនៅក្នុងទ្វារទាំង ៥ ។ បើជា
អកុសល(១) ឃើញដូចខ្លួនកំពុងប្រព្រឹត្តធ្វើបាបកម្ម ការនាំវុធកាប់សម្លាប់

១- មានន័យនៅច្រើនណាស់ អតីតន័យនាំមាន បច្ចុប្បន្នន័យនាំមានដែរ ផ្ទ្ធ្ចន័យនាអ្នក
សម្លាប់ពោ សម្ងាប់ជ្រូក ភ្ជាដើង ២ ស្រែកផ្ទ្ធ្ចពោ ឬ ផ្ទ្ធ្ចជ្រូក ឬ ផ្ទ្ធ្ចព្រានសន្ទូចឃើញ
សន្ទូចដាប់មាត់ខ្លួន យកដៃទាញសន្ទូចចេញពីមាត់ ។

សត្វ ឬ បាបកម្មណាមួយ, បើជាកុសល(១) ឃើញដូចខ្លួនកំពុងបំពេញកុសលធ្វើបុណ្យទានរក្សាសីល ឬ ស្តាប់ធម៌ទេសនា ។

គ) ឯ គតិនិមិត្ត "និមិត្តឃើញដំណើរកម្ម" ឃើញអារម្មណ៍ណាមួយក្នុងមនោទ្វារ បើជាអកុសល ឃើញភ្លើងឆេះ ឋាននរក ទីឋានដែលខ្លួនកំពុងប្រព្រឹត្តធ្វើបាបកម្ម, បើជាកុសល ឃើញទីឋានប្រសើរ ឋានសួគ៌ ទីវត្តអារាម ដែលខ្លួនធ្លាប់បំពេញកុសល ធ្វើបុណ្យទានរក្សាសីលស្តាប់ធម៌ទេសនា ។

ការឃើញអារម្មណ៍ទាំងនេះ ពុំមែនទៅឃើញ តាមអាយតនៈរបស់ខ្លួនទេ ឃើញតែក្នុងមនោទ្វារ (មនោវិញ្ញាណ) ប៉ុណ្ណោះ ។ ការឃើញខ្លះ រហ័សណាស់ រហ័សស្មើនឹងចិត្ត ទោះជាមរណកាលនោះដូចម្តេចម្តាក៏ដោយ ដូចក្នុងករណីវាយមូសសម្លាប់ មូសដែលទំលើអន្ទាក់ដែក ហើយគេយកញញួរដែកទៅវាយម៉ាំងស្លាប់ស្រួស, មូសនៅតែឃើញអារម្មណ៍ណាមួយ តាមយថាកម្មរបស់ខ្លួនទាន់បាន ពេលគឺ ជវនសុះក្លែតទៅដល់ខណៈចិត្តចុងក្រោយបំផុត ដែលជាចុតិចិត្ត=(ស្លាប់)

១- និទានធម្មិកឧបាសក ឃើញទេវតាយករថទឹមសេះមកទទួល ហើយនិយាយប្រាប់ថា "ឲ្យវាយផ្ទាំងដីគឺរាងកាយមនុស្សចោលទៅ ឲ្យទៅយកផ្ទាំងមាស គឺ កាយទិព្វជារបស់ទេវតាវិញ ។ រឿងបច្ចុប្បន្ន អ្នកខ្លះឮភ្លេងឋានសួគ៌ទាំងយប់ នឹកស្មានថាជាសម្លេងវិទ្យុ ទំ ដើរទៅបើកវិទ្យុខ្លួនស្តាប់ ។ ក្នុងបច្ចុប្បន្នកាលនេះ មានភិក្ខុមួយអង្គ កាលពីជាតិមុនធ្លាប់កើតជាដំរី ស្លាប់ពីដំរីបានមកកើតជាមនុស្ស ហើយបួសសព្វថ្ងៃនេះ ។

ហើយទៅតជាប់នឹងខណៈចិត្តដើមដែលជាបដិសន្ធិចិត្ត= (កើត) នៅក្នុង ១ ខ្នុបញ្ជុកៈមួយថ្នាំទៀត ពោះជាកំណើតណាមួយក៏ដោយ ។

និយាយដោយសង្ខេប ក្នុងមរណាសន្នជវន "ជវនស្ទុះទៅក្នុងពេលដិតស្លាប់" កម្មទាំង ៣ ប្រការ ដែលបានពោលមកហើយ កម្មណាមួយ នឹងចូលមកប្រាកដតាមយថាកម្មរបស់ខ្លួន ក្នុងខណៈចិត្តចុងក្រោយបង្អស់នៃជីវិត ។ អ្នកស្លាប់ ដឹងច្បាស់ខ្លួនឯងក្នុងមនោទ្វារ (មនោវិញ្ញាណ) ដ៏ជាក់ស្តែង ។ កម្មនេះឯង ជាតួវិបាក "ផលរបស់កម្ម" ជាធម្មសម្រេចកិច្ចចុងនិងបដិសន្ធិ ហើយសត្វដែលយើងហៅថា "ស្លាប់" ទ្ទុះ ត្រង់កន្លែងណា: "ខណៈចិត្តរលត់" ជាខណៈចិត្តចុងក្រោយបំផុតនៃជីវិត ដែលហៅថា ចុតិ "ខណៈចិត្តឃ្លាតចាកកាយ=ស្លាប់" ហើយដែលហៅថា "កើត" ត្រង់ឧបប្ជាទ-ក្ខណៈ "ខណៈចិត្តកើត" ជាខណៈចិត្តដើមបង្អស់នៃជីវិត ដែលលោកហៅថា បដិសន្ធិចិត្ត "ខណៈចិត្តតភ្ជាប់=កើត" នៅក្នុងម៉ាស៊ីនពោលគ្រាងកាយ ដែលជាតួ ១ ខ្នុបញ្ជុកៈមួយថ្នាំទៀត ទើបខណៈចិត្តបន្ទាន់ណើររបស់វាតគ្នាដឹកទៅ ពីខណៈចិត្តមួយទៅខណៈចិត្តមួយទៀត គឺកើតឡើង-តាំងនៅ-រលត់ទៅ, កើតឡើង-តាំងនៅ-រលត់ទៅ, កើតឡើង-តាំងនៅ-រលត់ទៅ . . . . . ដែលយើងបបួលគ្នានិយមហៅថា ជីវិត "ការរស់នៅ" របស់យើងគ្រប់គ្នាដ៏រហ័សក្រៃលែង

ដោយកម្ចាំងកម្មដែលជាថាមពល ប្រៀបប្រដូចសន្ទុះហូរនៃទ្សទឹកដែលហូរ(1)ឆ្ទាញ់ចុះពីលើកំពូលភ្នំ មិនចេះដាច់ដូច្នេះឯង នេះហើយជាវិធីការរស់នៅ "ជីវិត" មនុស្សសត្វគ្រប់គ្នាទាំងអស់ ។

និយាយដោយសង្ខេបមកនេះ ស្តាប់បានដែរ តែបានដោយលំបាកណាស់ មិនបានដោយងាយទេ ។ ហួសវិស័យមនុស្សទេឬ ? ថាហួសក៏ថាទៅចុះ តែដោយពិត ពុំមែនហួសទេ, មនុស្សជាសត្វមានធម្មសញ្ញា ពោលគឺបញ្ញាវិសេសអស្ចារ្យបំផុត ។ ចិត្តមនុស្សប្រសើរណាស់ មិនមានអ្វីប្រសើរប្រៀបផ្ទឹមឲ្យស្មើបានឡើយ បើបានទទួលការសិក្សាបរិបូណិ ពោលគឺបំប៉នអាហារបស់ចិត្តគឺវិជ្ជាឲ្យចិត្តស៊ីឆ្អែតបរិបូណិ ដូចគេបំប៉នអាហារកងកាយហើយ ចិត្តជាត់មានសុខភាពបរិបូណិ ធ្វើអ្វីបានទាំងអស់, កុំថាឡើយត្រឹម ទឹក ដី ភ្លើង ខ្យល់ ដែលមើលឃើញនៅជុំវិញខ្លួនមនុស្ស ឬចាំបាច់និយាយថ្វី សព្វបើលោកព្រះចន្ទព្រះអង្គារ ដែលគេមើលឃើញ+នុះ សូម្បីតែព្រះនិព្វាន ដែលភាសាមនុស្សនិយាយស្តាប់មិនបាន ពន្យល់នៅតែស្តាប់មិនបានទៀត ក៏ចិត្តមនុស្ស (ព្រះអរហន្ត) យល់បាន ធ្វើឲ្យសម្រេចបាន ។ នេះជាអានុភាពចិត្តមនុស្សដ៏អស្ចារ្យ ដែលមនុស្សគ្រប់រូបគួរកសាងឲ្យកើតមានឡើង ។

តែទោះបីម្តេចម្តា យើងត្រូវយល់ថា ធម៌ដែលយើងកំពុងដោះ

1- សុត្តន្តបិដក ភាគ ៤៧ អង្គុត្តរនិកាយ សុត្តកនិបាត ទំព័រ ២៤៩ ។

ស្រាយនេះ ជាធមិសុខុមគម្ភីរភាពវិក្រលែង គួរចង់ចេះដឹង គួរឲ្យមានការយើញយ៉ាងវិចិត្រពិស្តារពិតតាមពិត ជាធមិសារវន្ត ដែលព្រះសម្ពុទ្ធទ្រង់រកយើញនៅក្រោមពោធិមណ្ឌល មានហេតុផលគ្រប់ចរិបូណិតាមលក្ខណៈវិទ្យាសាស្ត្រ ជាធមិផ្សេងពីទ្រឹស្តីព្រាហ្មណ៍ដែលស្តីថា មានអាត្មន៉ាចេញមកពីព្រហ្មន៉ ហើយវិលចូលទៅ ព្រហ្មន៉ ឬបរមាត្មន៉, ស្លាប់តែកាយក្រៅ ឯអាត្មន៉មិនចេះស្លាប់ ឋិតថេរនៅនិត្យ ។ យើងគួរលើកយកមកនិយាយសាជាថ្មីទៀត ដោយយកឧទាហរណ៍អ្នកឈឺធ្ងន់ជិតស្លាប់ជដែលនេះឯងមកនិយាយ ហើយឥឡូវនេះ យើងសន្មតថា អ្នកស្លាប់ហើយទៅកើតក្នុងសុគតិភព ដោយអំណាចកុសលកម្មទៅចុះ តែធ្វើម្តេចឲ្យអធិប្បាយរបស់យើងងាយយល់គួរជាទីពេញចិត្តហ្នឹ ?

អ្នកឈឺធ្ងន់ជិតស្លាប់ មុនធ្វើមរណកាល តែងតែយើញអារម្មណ៍ណាមួយតាមយថាកម្មរបស់ខ្លួន ។ ក្នុងមរណាសន្នជវ៉ន "ជវ៉នចិត្តស្ទុះទៅជិតស្លាប់" ភវង្ក "លំនៅចិត្ត" ត្រូវកាត់ផ្តាច់ចេញ. ខ្សែភវង្គនេះ ញ៉ារអស់ពីរខណៈចិត្ត ហើយទើបរលត់ទៅ, បន្ទាបំពីភវង្គចិត្តនេះ មនោទ្វារាវជ្ជនៈ "ការវិចារក្នុងមនោទ្វារ" កើតឡើង ហើយរលត់ទៅទៀត ។ តមក ជវនចិត្ត "សន្ទុះចិត្ត" កើតឡើង, ឯជវនចិត្តនេះ ប្រព្រឹត្តទៅបានត្រឹម ៥ ខណៈចិត្តតែប៉ុណ្ណោះទេ ដោយអាស្រ័យជវនចិត្តនេះ ទន់ខ្សោយខ្លាំងពេក មិនអាចទៅបានគ្រប់ខណៈ

ចិត្ត តាមធម្មតា ត្រូវប្រព្រឹត្តទៅជល់ ៧ ខណៈ ។ ជវនចិត្ត ទន់ ខ្សោយបែបនេះ ជាហេតុនាំឲ្យជនកកម្មពាំងអស់ថមថយកម្ចាំង ព្រោះកិច្ចសំខាន់របស់ជវនចិត្តនេះ ជាការជួយតាក់តែងភពថ្មីឲ្យប្រព្រឹត្ត ទៅដោយប្រពៃ តាមកាសាធមិ លោកហៅថា អភិនវការណៈ "ការតាក់តែងភពថ្មី" ។ បើអារម្មណ៍អ្នកស្ថាប់ជាឥដ្ឋារម្មណ៍, ចិត្តអ្នក នេះប្រកបដោយកុសល ទោះជាអសំខាវិកា "ឥតគេដឹកនាំ" ក្តី ទោះជាសសំខាវិកា "មានគេដឹកនាំក្តី" តែងតែប្រកបដោយ សោ-មនស្សវេទនា (សោមនស្សសហគតៈ) ហើយជាញាណ-សម្បយុត្ត "ប្រកបដោយបញ្ញា" តាមដំណើរដែលអាចប្រព្រឹត្តទៅ បាន ។ តមក តទាលម្ពនចិត្ត "ចិត្តទទួលយកអារម្មណ៍នោះ" មានកិច្ចត្រូវស្រាវយក ឬ ត្រូវតោងយកអារម្មណ៍ដែលប្រព្រឹត្តទៅនោះ អស់ពីខណៈចិត្តទៀត, តែជួនកាលចិត្តនេះកើតឡើង ក៏មានមិនកើត ឡើងក៏មានដែរ ។ បន្ទាប់ពី តទាលម្ពនចិត្ត នេះមក ចុតិ-ចិត្ត "ខណៈចិត្តឃ្ចាតចាកកាយ=ស្ថាប់" ក៏កើតឡើង ជាខណៈចិត្ត ចុងក្រោយបំផុតនៃជីវិត ។ ត្រង់នេះ កម្មជាកុសល(1) ឬអកុសល ដែល មកប្រាកដក្នុងមនោទ្វារនោះ ឈ្មោះថា ជនកកម្ម "កម្មនាំឲ្យ កើត" ហើយជាមរណាសន្នវិថី ជាចិត្តមានកិច្ចតាក់តែងឲ្យកើតជា កំណើត=(ជាតិ) ដែលជាភពថ្មី ។ វិចុតិចិត្ត នេះ ជួនកាលកើត

1- អភិធម្មត្ថសង្គហៈព្រះគេធព្រះគុណព្រះឧត្តមមុនី អ៊ុ-ស្ទ៉ូរ ទំព័រ ១៥១ ។

ឡើងកន្លងទៅបំផុតនៃដំណើរ ជួនកាលកន្លងទៅបំផុតនៃតម្លៃ ជួនកាលកន្លងទៅបំផុតនៃការវិវត្ត ។

សេចក្តីដែលយើងត្រូវនិយាយតទៅទៀតនេះ ជាធម្មតាម្តងកាត់តែលំនាំសុទ្ធមិនឡើង អ្នកសិក្សាគួរប្រយ័ត្នដោយពិសេស ដើម្បីតម្រង់ការយល់របស់យើងឲ្យដើរទៅត្រង់តាមគន្ធធ្ងន់ពុទ្ធវចនៈ ។ ចំណុចលំបាកយល់ ហើយការយល់តែងតែមានផ្សេងគ្នាទុ:ះ គឺចំណុចថា អ្វីទៅដែលកើតទៀត? ខ្ញុ:យល់ថា ចិត្ត ឬ វិញ្ញាណ ឬក៏ ចុតិចិត្ត នេះឯង ជាធម្ម-ជាតទៅកើតជាកំណើតមានមុខទៀត ។ តើការយល់នេះ ខុសជាយល់ត្រឹមត្រូវ ឬកាន់ប្រឡាំងហួតចាកពុទ្ធវចនៈ? យើងគួរសង្ក្តត់សេចក្តីនេះឲ្យធ្ងន់ចិត្ត គួរសើរើពិនិត្យមើលគម្ពីរដីកាសាជាច្រើនទៀត ដើម្បីឲ្យបានយល់ពិតៗ ត្រឹមត្រូវតាមគន្ធធ្ងន់ពុទ្ធវចនៈ ។ បើប្រសិនជាយើងយល់ថា ចិត្ត ឬ វិញ្ញាណ ឬក៏ ចុតិចិត្ត ជាធម្មជាតទៅកើតជាកំណើតថ្មីទៀតពិតមែនទុ:ះ ចិត្ត ឬ វិញ្ញាណ ឬក៏ ចុតិចិត្ត នេះឯង ទំនងមានន័យប្រហាកដដូចជា អាត្មន "ព្រលឹង" មិនចេះស្លាប់ របស់លទ្ធិសាសនាព្រាហ្មណ៍ពិតមែន ។ ទ្រឹស្តីបែបនេះ ពុំមែនជាសេចក្តីពិតទេ អង្គព្រះសម្ពុទ្ធបដិសេធចោលក្រាមពោធិមណ្ឌលទៅហើយ ។ ដូច្នេះ សេចក្តីពិត ដែលថា អ្វីកើតទៀតនោះ គឺនឹងមានផ្សេងពីសេចក្តីយល់របស់យើងទាងលើនេះទៅវិញ ។

ពុទ្ធកាសិតច្រើនអង្ខ្ញើណាស់ ក្នុងគម្ពីរពុទ្ធសាសនា ដោយពិសេស

ពុទ្ធភាសិតដែលអង្គព្រះសម្មុទ្ធបានត្រាស់ដឹងក្នុងយាមនៃរាត្រីកាលចាំង ៣ មិនយើញមានសេចក្តីថា ចិត្ត ឬ វិញ្ញាណ ឬក៏ ចុតិចិត្ត នេះ ទៅកើតជាកំណើត=(ជាតិ)ទេ ទ្រង់តែងតែត្រាស់ថា អវិជ្ជា តណ្ហា ឧបាទាន កម្ម ជាធម៌ភាក់តែងឲ្យមានកំណើត=(ជាតិ) ទៀត និយាយខ្ញុំគឺកម្មជាតួសន្ធារ, សន្ធារនោះឯង ភាក់តែងជាតិ "កំណើត" មានខ្ទុប.ញ្ជុកៈជាគ្រឿងប្រាកដ ពោលគឺ មានរូបហើយ ធម៌ចាំងឲ្យយគឺ វេទនា សញ្ញា សន្ធារ វិញ្ញាណ ក៏ត្រូវតែកើតមានឡើងដែរ ។ រីធម៌គឺ វេទនា សញ្ញា សន្ធារ វិញ្ញាណ ចាំងនេះហោត ពុំមែនជាធម៌ថេរនៅនិត្យទេ តែងតែប្រែប្រួលផ្ទាស់ប្តូរ គឺពុំមែនដដែល ។ ជាឯកលក្ខណៈទេ, ចានជាលោកពោលថា អនិច្ចំ "ពុំថេរនៅនិត្យ", ធម៌មួយក្រុម គឺជីវិត អត្តភាព (ប្រុស ស្រី ល្អ អាក្រក់ ពាល ប្រាជ្ញ មានវ៉ាសនា ឥតវ៉ាសនា ដែលយើងសន្មតថាជាតួបុគ្គល គឺយើង គឺអញ) ត្រមចាំងសុខទុក្ខចាំងអស់នេះ ប្រព្រឹត្តទៅស្ទើរដោយខណៈចិត្តមួយ កើតឡើង កើតចាំងអស់ រលត់ទៅ រលត់ទៅវិញចាំងអស់ ជាធម៌ប្រព្រឹត្តទៅចាំងក្រុម ដូចខ្សែទឹកហូរទៅចាំងក្រុម ហើយមួយក្រុមៗ ពុំដដែល ពោលគឺ អ្នក "ក"នេះ ពុំមែនជាអ្នក "ក" ១ចាំងមុខទេ, អញវិញ ពុំមែនអញពីមុន ទ្រឹងពុំមែនអញស្អែកទេ, តែមិនគឺអ្នកណាគឺអ្នក "ក" គឺអញ នេះឯង= ១ ១ សោ ១ ១ អ្ញោ ។

មួយទៀត ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា វិញ្ញាណនេះ អាស្រ័យដោយរូប
វេទនា សញ្ញា សង្ខារ ទើបកើតឡើង, វិញ្ញាណមិនអាចតាំងនៅដោយ
ឡែកពីធមិទាំងនេះបានឡើយ, ដូចពុទ្ធកាសិតដែលទ្រង់ត្រាស់ទុកថា(1) :

"អ្នកណាអាចនឹងនិយាយប្រាប់បានថា "វិញ្ញាណ" មក - ទៅ
កើត - ស្ងាប់ - ចម្រើនឡើង - លូតលាស់ឡើង - ធំឡើង - ក្រៅពី រូប
វេទនា សញ្ញា សង្ខារទាំងឡាយ យ៉ាងនេះ ?"

ដូច្នេះ ធម្មតាជាតិជាលក្ខណៈកំណើត គឺ ជាតិពិត តាមពិតនោះ ពុំ
មែនចិត្ត ឬ វិញ្ញាណ ឬក៏ចុតិចិត្តនេះទេ, ធមិទាំងនេះ ពុំមែនជ ធមិមាន
អានុភាពពិសេស ធ្វើឲ្យមានកំណើតគឺជាតិបានឡើយ ។ ជនកាកម្ម
ទេតើ ជាមរណាសន្នជវ័ន ជាតួកម្ម កុសល ឬ អកុសល ទើបជា
ធមិមានពលានុភាពពិសេស ធ្វើឲ្យមានកំណើត គឺជាតិ=បុនព្ភវៈ=
កំណើតថ្មីទៀត ។ កាលបើចុតិចិត្តរលត់ទៅហើយ ពាក្យសន្មតថា
"មរណៈ= ស្ងាប់" ក៏កើតមានឡើង ។ តទៅទៀត ចិត្តជរូប
"រូបកើតពីចិត្ត" និងអាហារជរូប "រូបកើតពីអាហារ" ទាំងពីរ
នេះ មិនអាចកើតឡើងទៀតទេ មានតែឧតុជរូប "រូបកើតពីរដូវ"
មួយទេ ឋិតថេរនៅឡើយ នៅរហូតទៅដល់សពនេះក្ងាយទៅជាអសុក
ហើយតទៅទៀត កើតទៅជាផង់ធូលីអស់ទៅ ។

1- សុត្តន្តបិដក ភាគ ៣៣ សំយុត្តនិកាយ ឧបាយវត្ត ទំព័រ ១២២ ។

ពាក្យថា "ស្ងប់" (មរណៈ=) នេះ បើតាមគម្ពីរអភិធម្មលោក ហៅថា "ការលត់" នៃចិត្ត - កាយ ដែលទ្រទ្រង់ជីវិតន្ទ្រិយ នៃមនុស្សសត្វមួយ ។ នៅក្នុងកពនេះ, ចានសេចក្តីថា អាយុ ក្ខើងជាតុ (ឧស្ម) វិញ្ញាណ លះបង់លែងនៅជាមួយសរីរាង្គ ហើយសរីរាង្គនៅទទេ ពោលគឺត្រឿងម៉ាស៊ីន "ចិត្ត-កាយ" ឈប់លែងដើរ នៅបង្ក្រឹងទទេ ។

បើនិយាយតាមពាក្យអ្នកទស្សនវិទូបស្ចិមវិញ "ស្ងប់" នេះ គឺការលត់ចាតុកាត ឬឧបាទិណ្ណ បណ្តោះអាសន្នមួយៗណ.ស៊ីន, តែដោយពិត ពុំមែនជាការលត់សូន្យរលីង នៃតួបុគ្គល ជាបុគ្គលបញ្ញត្តនោះទេ, សរីរាង្គដែលទ្រទ្រង់ជីវិតន្ទ្រិយនោះ លត់ទៅមែន តែកម្លាំងកម្ម "កម្មពលៈ" ជាធម្មជាតិជីវិតន្ទ្រិយ ធ្វើឲ្យរស់ប្រព្រឹត្តទៅនេះ មិនបានលត់ទៅទេ, កម្លាំងនេះ ស្ទុះលឿនទៅមុខ ទៅគោលយកកពថ្មីទៀត ដូចសេចក្តីដែលលោកពោលទុកថា (១)

"បដិសន្ធិក្នុងកពថ្មី និងវត្ថុចិត្តមុនបដិសន្ធិ មានអារម្មណ៍ឯកមួយ-ជាមួយគ្នាក្នុងកពនេះដែរ, អារម្មណ៍នេះឯង ស្ទុះលឿនទៅដល់កពខាងមុខ ដូចជាសំឡេងស្គរដែលបុគ្គលវាយនៅក្នុងទីនេះ សន្ទុះសូរសំឡេងនៃស្គរនោះលឿនហួតទៅដល់ទីឯនោះ" ។

១- អភិធម្មត្ថសង្គហៈ របស់ព្រះតេជព្រះគុណ ព្រ-ឆត្តមុនី អ៊ុ-ស្ទ ទំព័រ ១៥៣ ។

សេចក្តីនេះ មានឧបមាដូចភ្លើងអគ្គិសនី, ភ្លើងអគ្គិសនីដែលយើងមើលឃើញ យើងមើលឃើញតែបាតុភាពខាងក្រៅ នៃថាមពលអគ្គិសនីតែប៉ុណ្ណោះទេ, ឯថាមពលអគ្គិសនីនុ៎ះ យើងមើលពុំឃើញទេ; ឯមនុស្សសត្វ ក៏មានឧបមេយ្យដូច្នេះដែរ គឺយើងមើលឃើញបានតែបាតុភាពខាងក្រៅនៃថាមពលរបស់កម្មតែប៉ុណ្ណោះទេ, ឯថាមពលកម្មនុ៎ះ យើងមើលពុំឃើញឡើយ ។

មួយទៀត ប្រស្នាដែលថា មនុស្សសត្វស្លាប់, ចិត្ត ឬវិញ្ញាណទៅកើតឯណា? នេះក៏យើងអាចយកភ្លើងអគ្គិសនីនេះ ឯងមកធ្វើជាឧបមាឧបមេយ្យឲ្យយល់បានដែរ ។ ឧបមាថា អំពូលភ្លើងមួយមានអន្តរាយ, ភ្លើងក្នុងអំពូល ត្រូវតែរលត់ទៅដែរ, ចុះភ្លើងដែលរលត់នោះទៅឯណា? យើងនិយាយដូចម្តេចឲ្យត្រឹមត្រូវតាមពិត យើងនិយាយថា "ភ្លើងឆេះក្នុងអំពូលហើយរលត់ទៅនេះ វាលោតផ្លោងឆ្លងទៅឆេះជាភ្លើងភ្លឺនៅក្នុងអំពូលមួយទៀតដូច្នេះ ត្រឹមត្រូវដែរឬទេ?, ទេទេ ពុំមានហេតុផលត្រឹមត្រូវទេ ។ សេចក្តីពិត ភ្លើងនេះវារលត់បាត់ទៅហើយ ប៉ុន្តែចរន្តនៃថាមពលអគ្គិសនី វាមិនបាត់ទៅជាមួយភ្លើងទេ, វានៅមាន, បើគេគ្រាន់តែផ្លាស់ដាក់អំពូលល្អថ្មីមួយចូលទៅទៀត ជាជំនួសកន្លែងដដែល, វានឹងឆេះជាភ្លើងភ្លឺដូចដែលទៀត ឥតសង្ស័យឡើយ, មានឧបមេយ្យដូចកាយ-ចិត្តដូច្នោះដែរ បើមានគ្រឿងម៉ាស៊ីន ពោលគឺ១ ឆ្លុះញ្ញាកៈបរិបូណ៌

ជាគ្រឿងបន្ទាស់ពោលគឺកតជ្ជៈហើយ, ចិត្ត ឬ វិញ្ញាណ នឹងកើតមានឡើងប្រាកដ មិនគួរមានក្តីសង្ស័យទេ, ព្រោះថា ចិត្ត ឬ វិញ្ញាណ អាស្រ័យនឹង១ ទ្ទ្ធ:ញ្ជ:ក: ទើបកើតមានឡើង និយាយថា ចិត្ត ឬ វិញ្ញាណ ដដែលនេះ វាលោតទ្ទ្ធ:ទៅកើតទៀត មិនមានហេតុផលសមរម្យពិតឡើយ ។

ដូច្នេះ យើងមានហេតុផលបរិបូណ៌ និងនិយាយថា ឫមពលនៃកម្ម មិនមានវិបត្តិអ្វីសោះ សព្វបើគ្រាន់តែសរីរាង្គវាបែកធ្លាយ (ស្លាប់) ទៅនោះទេ សេចក្តីពិត ឯការលត់ទៅនៃវិញ្ញាណបច្ចុប្បន្ន គ្រាន់តែជាការនាំឲ្យកើតចិត្ត ឬ វិញ្ញាណ ក្នុងកំណើតគឺជាតិមួយទៀតប៉ុណ្ណោះ, ព្រោះថា នៅមានវិបាករបស់កម្មជាឫមពលនៅឡើយ ។ សេចក្តីពិត ១ណ:ចិត្តក្រោយដ្ឋ:ស់លត់=(ភង្គ:) នៃបុគ្គលអ្នកស្លាប់ គឺជាសន្ទ:ចិត្តដែលនឹងកើតឡើង=(ឧបន្ទ:) ហើយកាន់យកកតជ្ជៈមួយទៀត ដូចសេចក្តីដែលលោកពោលទុកថា[1]

"ក្នុងមរណាសន្ទ:ដ:" "ដំណើរជិតស្លាប់" ជវនចិត្ត មានកម្លាំងខន់ខ្សោយពេក កើតឡើងបានត្រឹមតែ ៥ ១ណ:ចិត្តប៉ុណ្ណោះទេ, ភាគ្ម ភាគ្ម:ធ:ម:ត្ត ឬ ភ:ត:ធ:ម:ត្ត មកកើតប្រាកដឲ្យឃើញ ពុំបានដល់ត្រប់ ១៧ ១ណ:ចិត្តទេ, ឫតិចិត្តនឹងកើតឡើងហើយ សត្ត្រូវស្លាប់ ពោលគឺត្រូវអិលហ្លាតចាកកាវ:ង "ទីលំនៅចិត្ត" ដែលហៅថា ស្លាប់,

---

១-អភិធម្មត្ថសង្គហ: របស់ព្រះពោធិ:ព្រះគុណ:ព្រះ:ឆត្តមមុនី អ:ម-ស្ទ:រ ទំព័រ ១៥៣ ។

ហើយអារម្មណ៍ដែលជាថាមពលរបស់កម្មនោះ ។ ក៏ត្រូវឈានទៅតាងយកបដិសន្ធិក្នុងភពមុខ" ។

ឯបដិសន្ធិវិញ្ញាណ ដែលកើតឡើងនេះ ចាប់យក ឬផ្តិតជាប់ទំនងរួមគឺ សុក្កោសិតា និង អណ្ឌោសិតា ដែលជារបស់មាតាបិតា ហើយតាំងនៅក្នុងកាវង្គតទៅ ។ ដោយអាស្រ័យបដិសន្ធិ-វិញ្ញាណនេះ កាយ ឧ ស ក:(១) គឺធាតុ ៤, ភាវ ឧ ស ក:(២) ភាពជាបុរសស្ត្រី, វត្ថុ ឧ ស ក:(៣) ទីតាំងនៃវិញ្ញាណ កើតឡើង ។ ឧ ស ក: មានកាយ ឧ ស ក: ជាដើម កើតប្រាកដឡើងក្នុងពេលដែលសត្វចាប់បដិសន្ធិនេះ ។ ឯភាពជាបុរសស្ត្រី ពុំមែនកើតឡើងដោយអាស្រ័យការផ្ទៀសុក្កោសិតា និង អណ្ឌោសិតា ទេ គឺកើតឡើងដោយអំណាចកម្មដោយឡែក ។

ការរលត់ទៅនៃវិញ្ញាណក្នុងកំណើត គឺជាតិជាអតីត ជាឧកាសនាំឲ្យកើតវិញ្ញាណក្នុងកំណើត គឺជាតិ ១ ទៅទៀត ។ ប៉ុន្តែ ធម្មនេះ អ្នកសិក្សាគួរយល់ថា វិញ្ញាណនេះ ពុំមែនជាមិនប្រែប្រួល មិនផ្ទាស់ប្តូរ ឬថេរនៅនិត្យទេ ជាធម្មជាតតែងតែបន្ត្រាដឹកមក តាំងតែ

១- ឯនដ្ឋិតធាតុ ៤ គឺបថវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។ ដោយអាស្រ័យធាតុ ៤ នេះ វណ្ណ: គន្ធ: រស: ឱជា ជីវិតិន្ទ្រិយ កាយ កើតឡើង ។ ២- ភាប់យកកាយទសក: ៩ ១ាងដើមនេះ មកផ្ទ្ប៉ាំងនឹងភាវទសក:, ឯវត្ថុទសក: ភាប់យកកាយទសក: ៩ នេះ ផ្ទ្ប៉ាំ ហើយផ្ទ្ប៉ាំគ្នានឹងវត្ថុទសក: ជា ១០ ប្រការ ។

ពីអតីតរហូតមកបច្ចុប្បន្ន ប្រៀបដូចជាកន់រទេះ ដែលចេះតែវិលទៅ ។ ហើយចុះដាមួយចំណែកម្ខាង ។ បន្ទាត់ជ្រៀងដកបទៅ ។ ដោយហេតុដូចពោលមកនេះហើយ សាធុជនគ្រប់គ្នាគួរយល់ថា ការរស់នៅរបស់យើងដែលហៅថា "ជីវិត" នេះ ចានត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះទេ ពោលគឺយើងកំពុងរស់នៅតែក្នុងបច្ចុប្បន្នកាល ហើយបច្ចុប្បន្នកាលយើងនេះ កំពុងតែហូរចូលទៅកាន់អតីតកាលហើយ មិនមានអ្វីមកកាត់ផ្តាច់ចានឡើយ ។ វិញ្ញាណនីមួយ ។ កាលបើកំពុងលត់ទៅ ចានត្រាន្ទ្ធ ជាមពលរបស់ខ្លួនតាំងអស់ ឬកាន់យកអារម្មណ៍តាំងអស់ដែលខ្លួនចានទទួលហើយ ឲ្យទៅកាន់វិញ្ញាណដែលនឹងមានតទៅ ។ ឯវិញ្ញាណតា ។ គ្នានេះ តែងតែចានទទួលនូវពលានុភាព ជារបស់វិញ្ញាណមុន ។ តាំងអស់ ព្រមតាំងកម្ចាំងដទៃទៀតផង ហើយចេះតែប្រព្រឹត្តជានិច្ចជាដរបទៅ ។

ក្រសែវិញ្ញាណតាំងនេះ ចេះតែហូរតទៅមិនចេះជាប់ ។ ឯការលត់ទៅនៃវិញ្ញាណនីមួយ ។ ជាការលត់ដើម្បីសម្រេចកិច្ចឲ្យមានវិញ្ញាណមានកំណើត គឺជាតិទៅកន្លែងមុខទៀត ហើយវិញ្ញាណដែលនឹងកើតមានឡើងទៀត តែងតែទទួលការ:កម្មពីអតីតរបស់ខ្លួនតាំងអស់ដែលមានមកហើយទៀតផង ។ សេចក្តីនេះ គួរនឹកស្ញើចដល់លោកឡៅតឺ ដែលលោកស្ញប់ក្នុងលិ្ចតៅ+ របស់លោកថា "ដើមឈើដម្រុះ

ស៊ីកក្នុងរដូវស៊ីកឈើជ្រុះ ជាឱកាសសម្រាកយកកម្លាំង ដើម្បីលូតលាស់ជាសន្លឹកតទៅទៀត ។ សម្ដីនេះពិរោះណាស់ ។ រូបសត្វថ្មី ជាធាតុភាព-បច្ចុប្បន្ននៃក្រសែថាមពលកម្ម តែពុំមែនដូចដែលទឹងសត្វពីអតីតកាលនោះទេ គឺពុំមែនមានអត្តភាពបេះបិទដូចបោះពុម្ពនោះឡើយ ។ ខន្ធបញ្ចកៈថ្មីដែលសង្ខារតាក់តែងឡើងនេះផ្សេងគ្នា មានអត្តភាពផ្សេងគ្នា ប៉ុន្តែទឹងថាជា “សត្វដទៃ” ក៏ទេដែរ ព្រោះជាក្រសែថាមពលកម្មដដែលគ្រាន់តែមានការប្រែប្រួលនៃរូបកាយទៅផ្សេង គឺជាធាតុភាពមួយផ្សេងទៀត ដែលជាវត្តមានក្នុងបច្ចុប្បន្នកាល ហើយដែលគេមើលឃើញហាក់ដូចជារូបថ្មីមួយទៀតប៉ុណ្ណោះ ។

ការឆ្លងទៅនៃជវ័ន “សន្ទុះហូរ” បន្តពីមួយទៅមួយ ប្រព្រឹត្តទៅរហ័សអស្ចារ្យ ហើយស្ទុះហូរទៅ មិនមានកំណត់នៅក្នុងអន្តរភពទេ ។ តែពុទ្ធសាសនិកជន មិនមានជំនឿទ្រឹស្ដីដែលថា “មានព្រលឹង” (អាត្មន) របស់អ្នកស្លាប់ មានទីឋានសំចតរេរង់ចាំរកទីឋានសមគួរ ដើម្បីអវតារ” ដូច្នេះទេ ។ តំណនៃជវ័នក្នុងពេលមរណកាលនេះ តែងតែប្រព្រឹត្តទៅមិនបេះដាច់ ទៅតាមកម្រិតពេលវេលារបស់ខ្លួនដដែល ពុំមានអ្វីមកផ្ដាច់បង់បវត្តវិញ្ញាណនោះឡើយ ។

ឯការផ្សេងគ្នា មានផ្សេងតែបន្តិច រវាងចន្លោះខណៈចិត្តដែលកន្លង

ទៅទីឯខណៈចិត្តមួយទៀត និងរវាងចន្លោះខណៈច្យុត ដែលហៅថា ចុតិ-ចិត្ត និងខណៈចិត្តកើតឡើង ដែលហៅថា បដិសន្ធិចិត្ត ដែលយើងហៅថា "ស្លាប់" ជាគ្រឿងសម្គាល់ដែលយើងមើលឃើញប៉ុណ្ណោះ ។ ពាក្យថា ជាតិគឺ "កំណើត" ក៏បានទទួលនាមក្នុងពេលកើតនោះភ្លាម ពោលគឺស្លាប់ភ្លាម កើតភ្លាម ។ ឯរយៈវេលាដែលចិត្តចរទៅកើត ក៏មិនមានការវែងជាងគ្នាទេ តែងប្រព្រឹត្តទៅស្មើគ្នា ទោះយោបីសត្វទៅកើតក្នុងឋានសួគ៌ ឬ ទៅកើតក្នុងឋាននរក ក្នុងកំណើតតិរច្ឆាន ឬក៏ ក្នុងកំណើតមនុស្សក៏ដោយ ។ សេចក្តីនេះ ព្រះ នាគសេនត្ថេរ និងព្រះបាទមិលិន្ទ បានចោទសួរដោះស្រាយទុកក្នុងគម្ពីរ មិលិន្ទបញ្ហាថា :

លោកម្ចាស់នាគសេន! (ព្រះបាទមិលិន្ទក្រាបទូលសួរ) ឧប-មាថា មនុស្សម្នាក់ស្លាប់ក្នុងទីនេះ ហើយទៅកើតក្នុងឋានព្រហ្ម មនុស្សម្នាក់ទៀតស្លាប់ក្នុងទីនេះ ហើយទៅកើតក្នុងប្រទេសកាស្មីរ, តើអ្នកណាបានទៅដល់កើតមុនគេ ?

មហារាជ! (ព្រះនាគសេនត្ថេរ ថ្វាយព្រះពរ) មនុស្សទាំងពីរនាក់នេះ ទៅក្នុងទីនោះៗ ស្មើគ្នា មិនមុនមិនក្រោយឡើយ ។ តទៅព្រះនាគសេនត្ថេរថ្វាយព្រះពរទូលសួរព្រះបាទ មិលិន្ទវិញថា

—មហារាជ! ព្រះករុណាទ្រង់សម្ភពនៅក្នុងក្រុងណា ?

លោកម្ចាស់ ! (ព្រះបាទ មិលិន្ទ ក្រាបទូល), ខ្ញុំព្រះករុណាកើត
ក្នុងភូមិមួយឈ្មោះកាលាស៊ ។

-មហាវាជ ! (ព្រះ នាគសេនឆ្លើ ទូលសួរ), ភូមិកាលាស៊
ឆ្ងាយពីទីនេះទៅប៉ុន្មាន ?

លោកម្ចាស់ (ព្រះបាទ មិលិន្ទឆ្លើយតប), ទានប្រោសប្រមាណ
ជាពីរយោជន៍ ។

-មហាវាជ ! (ព្រះ នាគសេនឆ្លើ ទូលសួរ), ចុះប្រទេសកាស្មីរ
ឆ្ងាយពីទីនេះទៅប៉ុន្មាន ?

លោកម្ចាស់ ! (ព្រះបាទ មិលិន្ទ ត្រាស់តបវិញ), ទានប្រោស
ប្រមាណជា ១២ យោជន៍ ។

-មហាវាជ ! (ព្រះនាគសេនឆ្លើទូលសួរ), ឥឡូវ សូមព្រះ
ករុណាទ្រង់ព្រះចិន្តាទៅដល់ភូមិកាលាស៊ទៅមើល ?

លោកម្ចាស់ ! (ព្រះបាទមិលិន្ទរាជត្រាស់តប), ខ្ញុំព្រះករុណា
នឹកទៅដល់ហើយ ។

-មហាវាជ ! (ព្រះនាគសេនឆ្លើទូលសួរ), ឥឡូវ សូមទ្រង់
ព្រះករុណា ទ្រង់ព្រះចិន្តាទៅដល់ប្រទេសកាស្មីរទៀតមើល ?

លោកម្ចាស់ ! (ព្រះបាទមិលិន្ទរាជត្រាស់តប), ខ្ញុំព្រះករុណា
នឹកដល់ទៅហើយ ។

-មហាវាជ ! (ព្រះនាគសេនត្រេរទូលសួរ), ចុះទីហានទាំងពីរនេះ ដែលទ្រង់ព្រះករុណាបានតិតឡេជល់ហើយ តើទីហានណា ទ្រង់ព្រះករុណាព្រះចិន្តាឡេហើយ ជឹងជល់មុន ទីហានណា ទ្រង់ព្រះករុណាព្រះចិន្តាឡេហើយ ជឹងជល់ក្រោយ ?

លោកម្ចាស់ ឱ្យព្រះករុណានឹកឡេជល់ទីហានទាំងពីរនេះ ជឹងជល់ស្មើ ៗ គ្នា មិនមុនមិនក្រោយទេ ។

-មហាវាជ ! មានឧបមេយ្យដូច្នោះឯង អ្នកដែលស្លាប់នៅទីនេះ ហើយឡេកើតនៅហានព្រហ្មលោក ក៏ដូចគ្នាដែរ ពុំមែនយឺតយូរជាងគ្នាទេ, ឯអ្នកស្លាប់ក្នុងទីនេះ ហើយឡេកើតក្នុងប្រទេសកាស្មីរ ក៏កើតពេលស្មើគ្នាដែរ មិនមុនមិនក្រោយទេ ។

លោកម្ចាស់ ! (ព្រះបាទមិលិន្ទក្រាបទូលសួរដេញទៀត), សូមមេត្តាប្រោស ! ប្រៀបធៀបឧបមាឧបមេយ្យមកទៀតមើល ?

មហាវាជ ! (ព្រះនាគសេនត្រេរទូលតបវិញ,) ទ្រង់ព្រះចិន្តាដូចម្តេច ? ដូចបក្សីពីរហិចហើរលើអាកាសវេហាស៍ ហើយចុះឡេទំលើដើមឈើមួយជាមួយគ្នា, មួយទំលើមែកឧស់, មួយទៀត ទំលើមែកទាប ។ តើស្រមោលបក្សីទាំងពីរនោះ ស្រមោលបក្សីណា ចោលមកលើផែនដីក្រោយគេ ?

លោកម្ចាស់ ! (ព្រឡាទមិលិន្ទរាជក្រាបទូល). ស្រមោលបក្សីតំងពីរនេះ ចោលមកលើដែនដីស្ងើគ្នា មិនមុនមិនក្រោយទេ ។

មហារាជ ! ព្រះនាគសេនត្ទេរថ្វាយព្រះពរ, មានឧបមេយ្យដូច្នោះឯង មនុស្សស្លាប់តំងពីរនាក់ដែលយើងនិយាយគ្នានេះ ទៅកើតស្ងើគ្នា ពុំមែនម្នាក់កើតមុន ហើយម្នាក់ទៀតកើតក្រោយទេ ។

តទៅនេះ យើងបែរមកនិយាយពីប្រស្នាយើងទៀត ។ យើងចោទដណ្តឹងស្ងរតទៅទៀតថាចុះ "សុត្ថាកោសិកា និង អណ្ឌ-កោសិកា" នេះ តែងតែត្រៀមខ្លួនចាំទទួលយកនូវ បដិសន្ធិ-វិញ្ញាណាជានិច្ចទៅឬ ?

ចម្លើយតបនឹងសំនួរនេះ យើងទុកជូនលោកឧល្ពា (Dr. Dahlke) ឲ្យធ្វើយចុះ ។ ចម្លើយលោកជូចតទៅនេះថា :

"ការចាប់បដិសន្ធិនេះ ពុំមែនជាប្បាប់មានកម្រឹត ដែលទុកជាប្បាប់ប្រព្រឹត្តទៅតាមការទៀងទាត់នោះទេ គឺជាប្បាប់ "ខ្លួនឯងក្នុងខ្លួនឯង" ដូចជាចំណុចណាមួយនៅលើដែនពសុធានេះតែងតែត្រៀមខ្លួនទុកស្រេច ចាំទទួលថ្មមួយដុំដែលនឹងត្រូវធ្លាក់ចុះមកលើពុំខានឡើយ ។

(នៅមានត)

អត្តនាថកថា

ព្រះពុទ្ធវង្ស សេកា - នាង រៀបរៀង

កថាដែលសម្តែងអំពីខ្លួនជាទីពឹងរបស់ខ្លួនឬ កថាដែលសម្តែងអំពីការពឹងខ្លួនឯង តាមពុទ្ធកាសិតថា អត្តា ហិ អត្តនោ នាថោ "ខ្លួនឯងជាទីពឹងរបស់ខ្លួន" ហៅថា អត្តនាថកាថា ។

ពាក្យថា "ខ្លួន" ក្នុងទីនេះ ប្រែបេញមកពី អត្តា និង អត្តនោ ។ អត្តា និង អត្តនោ នេះមកពីស័ព្ទដើមថា អត្ត ដូចគ្នា ។ ពាក្យថា អត្ត នេះ ស្របគ្នានឹងតាសាសំស្ត្រឹតថា អាត្មន៉ ។

អត្ត ឬ អាត្មន៉ នេះ មានន័យតួរប្រែបាន ៤ យ៉ាង គឺ ប្រែថាចិត្ត១, កាយ១, សភាព (កុសលធម៌ឬកុសលកម្ម) ១, បរមអត្ត ឬ បរមាត្មន៉ គឺព្រលឹងដ៏ពិសេស ១ ។

អត្ត ក្នុងព្រះបាលីថា អត្តានំ ឧមយន្តិ បណ្ឌិតា "ប៉ណ្ឌិតទាំងឡាយ តែងទូន្មានទូវខ្លួន" ពាក្យថា "ខ្លួន" ក្នុងព្រះបាលីនេះ សំដៅយកចិត្ត ។

អត្ត ក្នុងព្រះបាលីថា ឧត្តិ អត្តសមំ បេមំ "សេចក្តីស្រឡាញ់ស្មើដោយខ្លួនមិនមាន" ពាក្យថា "ខ្លួន" ក្នុងព្រះបាលីនេះ សំដៅយកកាយ ឬ ពងកាយទាំងមូល ។

អត្ត ក្នុងព្រះបាលីថា អត្តទីបា ភិក្ខវេ វិហរថ "ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយ ចូរមានខ្លួនជាទីពឹង" ពាក្យថា "ខ្លួន" ក្នុងព្រះបាលីនេះ សំដៅយកកុសលធម៌ ឬ កុសលកម្ម ។

អត្ត ក្នុងព្រះបាលីថា អយំ អត្តា និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ "ធម្មជាតគឺខ្លួននេះឯងទៀងទាត់ ស្ថិតស្ថេរ មានការមិនប្រែប្រួលជាធម្មតា" ពាក្យថា "ខ្លួន" ក្នុងព្រះបាលីនេះ សំដៅយកបរមអត្ត ឬបរមាត្មន៍ គឺអ្វីមួយដ៏ពិសេស ដែលជនជាតិឥណ្ឌាប្រកាន់ជឿរហូតមកដល់សព្វថ្ងៃនេះ ។ អត្តក្នុងន័យទី៤នេះ ផ្ទុយគ្នានឹង អនត្តា ដែលប្រែថា មិនមែន អត្ត ឬ អាត្មន៍ (ខ្លួន,ព្រលឹង) ។ ជនជាតិឥណ្ឌាប្រកាន់ជឿថា អត្ត ឬ អាត្មន៍ មិនចេះស្លាប់ មិនមានការបែកធ្លាយទេ ជារបស់ទៀងទាត់ ស្ថិតស្ថេរ, មនុស្សគ្រប់រូបសុទ្ធតែមានអត្តឬអាត្មន៍ ព្រោះថា មនុស្សនិងសត្វដែលស្លាប់ទៅ, អត្តឬអាត្មន៍ (ព្រលឹង) មិនចេះស្លាប់ទេ, អត្តឬអាត្មន៍ នឹងធ្វើអ្វី ក៏អាចធ្វើបាន, គុណអំណាច សេចក្តីអាច របស់អត្តឬអាត្មន៍នេះ មានច្រើនបែប ច្រើនយ៉ាង ព្រោះពាក្យថា អត្តឬអាត្មន៍ នេះ ជាឈ្មោះនៃជីវៈ, ក្នុងទីនេះ ពួកឥណ្ឌាប្រកាន់ជឿថា ជាអ្វីមួយដ៏វិសេស, កាលបើមនុស្សនិងសត្វស្លាប់ហើយ ជីវៈឬអត្ត មិនស្លាប់ទេ ត្រូវទៅរកលំនៅថ្មីទៀត ។

អត្តា ជា វេទកោ គឺជាអ្នកសោយសេចក្តីសុខនិងទុក្ខ, ការធ្វើល្អឬអាក្រក់, អត្ត នឹងត្រូវសោយផលក្នុងជាតិថ្មីក្នុងអនាគត ។

អត្ត ជា សាមី គឺជាអ្នកគ្រប់គ្រង, ជាម្ចាស់របស់, ជានាយទៅ-ហ្វាយលោក ទាំងជាម្ចាស់របស់គឺកងកាយគ្រប់រូបមនុស្សនិងសត្វទៀតផង ។

អត្ត ជា និវាសី គឺអ្នកទៀងមិនចេះស្លាប់, កាលបើផ្ទះបាក់បែកហើយ ក៏ចុះចេញទៅរកលំនៅថ្មីទៅទៀត ។

អត្ត ជា សយំវសី គឺនឹងធ្វើអ្វីក៏អាចធ្វើបានតាមចិត្តរបស់អត្ត ដូចភ្នែកឃើញរូប ត្រចៀកឮសំឡេង ច្រមុះធុំក្លិន អណ្តាតដឹងរសជាតិជាដើមនោះស្រេចតែ អត្ត គឺតាមតែចិត្តអត្តគ្រប់បែបគ្រប់យ៉ាង, ព្រោះហេតុនោះអត្តទើបឈ្មោះថា ជាម្ចាស់លោក, ជាម្ចាស់សាងលោក ។ គុណប្ដនាមរបស់អត្ត ដែលពោលមកហើយនេះ ក្នុងព្រះពុទ្ធសាសនាហៅថា អត្តវាទុបាទាន គឺអ្នកមានសេចក្តីប្រកាន់អត្តវាទ (ទ្រឹស្តីថាមានអត្តឬអាត្មន); អត្តវាទុបាទាននេះ ក្នុងព្រះពុទ្ធសាសនាចាត់ជាមិច្ឆាទិដ្ឋិ គឺជាសេចក្តីយល់ឃើញខុស ជាសេចក្តីយល់ឃើញមិនត្រឹមត្រូវ ដែលវង្វេងឃ្លាងចាកផ្លូវនៃសេចក្តីពិត គឺអរិយមគ្គទាំង ៨ ដែលជាដំណើរទៅកាន់ព្រះនិព្វាន ។

ឯពុទ្ធភាសិតខាងដើមថា "ខ្លួនឯងជាទីពឹងរបស់ខ្លួន" នោះ បានខាងអត្ត ត្រង់ន័យទី ១ និងន័យទី ៣ ដែលសំដៅយកការធ្វើចិត្តឲ្យល្អ ។ ព្រោះហេតុនោះ គោលនៃពុទ្ធភាសិតនេះ សំដៅសេចក្តីថា "មុននឹងទីពឹងអ្នកដទៃ ត្រូវធ្វើខ្លួនឯងឲ្យជាទីពឹងរបស់ខ្លួន គឺត្រូវធ្វើខ្លួនឲ្យល្អសិន" ។

ធម្មតាមនុស្សក្នុងលោក នឹងនៅតែលឯកឯងតាមចំនែងមិនបាន ត្រូវតែពឹងគ្នានិងគ្នា ទាក់ទងគ្នាក្នុងផ្លូវណាមួយ បើមិនច្រើនក៏តិចពុំខាន ដូចបុត្រធីតាត្រូវពឹងមាតាបិតា ។ ត្រូវពឹងបុត្រធីតាបានខ្លះវិញជាដើម ។

យើងពឹងលោកបានយ៉ាងណា ៗ, លោកក៏ពឹងយើងបានយ៉ាងនោះៗ ដែរ ។ លោកណាឲ្យគេពឹងមុន លោកនោះហៅថា បុព្វការី ។ អ្នកណាពឹងលោកនោះ ហើយពេញចិត្តតបឧបការគុណឲ្យលោកបានពឹងខ្លួនឯងវិញ, អ្នកនោះហៅថា កតញ្ញូកតវេទី ។ ធ្វើដូច្នេះ ទើបពេញជាមនុស្សល្អ ព្រោះថា ការប្រព្រឹត្តបែបនោះ ជាគ្រឿងសម្គាល់នូវភាពនៃមនុស្សល្អ ដែលគេរកបានដោយក្រក្នុងលោក ។

មនុស្សគ្រប់គណៈ, គ្រប់ជាតិ, ប្រទេសនិងប្រទេស ទោះបីធៀងៗគ្នា ក៏ត្រូវពឹងពាក់អាស្រ័យគ្នានិងគ្នាទៅវិញទៅមកទើបរស់នៅបាន, មិនមែនត្រឹមតែមនុស្សទីពឹងគ្នានិងគ្នាប៉ុណ្ណោះទេ សូម្បីក្រៅពីនេះ មនុស្សយើងនៅត្រូវមានទីពឹងរបស់ឯទៀតជាច្រើន ដូចត្រូវទីពឹងដី, ទឹក, ភ្លើង, ខ្យល់, មេឃ, អាកាសជាដើម; តែរឿងនេះមិនចាំបាច់និយាយទេ ព្រោះមិនត្រូវតាមបំណង ។

សេចក្តីដែលរៀបរាប់មកនេះ សឲ្យឃើញថា មនុស្សយើងត្រូវតែពឹងគ្នាទៅវិញទៅមក ខានពុំបាន បើទុកជាមានពាក្យជាអំនួតប្រកាន់ថា "មិនត្រូវពឹងអ្នកណា, មិនបាច់ទាក់ទងនឹងអ្នកណាក៏នៅជាសុខបានដែរ"

ត្រូវចាត់ពាក្យនោះថាជាពាក្យខុស ។ ហេតុនោះយើងមិនត្រូវគិត មិនត្រូវនិយាយមិនត្រូវសរសេរ យ៉ាងនោះទេ គឺត្រូវតែពឹងអ្នកដទៃ ឬរបស់ដទៃជាច្រើនតាមធម្មតា ទ្រង់គេចឲ្យផុតអំពីធម្មតាទៅពុំបាន, បើដូច្នោះពុទ្ធ-ភាសិតថា "ខ្លួនឯងជាទីពឹងរបស់ខ្លួន" ទ្រង់ទៅជាពាក្យមិនពិតវិញហើយ ឬ ? តាលមានពាក្យគេសួរយ៉ាងនេះ បើអ្នកធ្វើយ ធ្វើយមិនស្រួលល្អទេ ត្រូវចាត់ជាមិច្ឆាទិដ្ឋ ។ បញ្ហាកម្មនេះ យើងត្រូវធ្វើយដោយសេចក្តីពិតត្រង់ក្នុងមាត ថា ការពឹងពាក់អាស្រ័យគ្នាទ្រង់គ្នានោះមាន ២ យ៉ាងគឺ

១– ពឹងអ្នកដទៃ ឬរបស់ដទៃដែលកាន់ថាជាទីពឹងក្រៅអំពីខ្លួនយើង,

២– ពឹងខ្លួនឯង គឺការប្រព្រឹត្តល្អរបស់ខ្លួនឯង ។

ធម្មតាដែលយើងត្រូវតែពឹងអ្នកដទៃ ឬរបស់ដទៃក្រៅពីខ្លួនយើងនោះ បានអធិប្បាយរួចមកហើយ ។ ឯពឹងខ្លួនឯង គឺត្រូវធ្វើចិត្តឲ្យប្រាសចាកអគតិធម៌ជាមុនបំផុត ហើយពិចារណាមើលក៏គង់ដឹងបានថា យើងពឹងអ្នកដទៃបាន ឬអ្នកដទៃដែលឲ្យយើងពឹងគេបាននោះ លុះត្រាតែយើងមានសេចក្តីល្អយ៉ាងណាមួយ ជាមូលហេតុពិត ទើបគេឲ្យយើងពឹងគេបាន, បើមិនដូច្នោះទេ កុំសង្ឃឹមថា ទ្រង់ពឹងគេបានឡើយ, សូម្បីខ្លួនយើងវិញក៏ដូច្នោះដែរ ត្រាតែគេមានសេចក្តីល្អណាមួយ ជាមូលហេតុពិតផងដែរ ទើបយើងឲ្យគេពឹងយើងបាន, បើគេប្រព្រឹត្តអាក្រក់ទុច្ចរិត មិនពោលពាក្យសត្យចំពោះយើង ក៏យើងឲ្យគេពឹងយើងមិនបានដែរ ។ មែនពិត

បុគ្គលប្រព្រឹត្តអាក្រក់ហើយ នឹងពឹងអ្នកដទៃ ឬរបស់ដទៃដើម្បីចៀសវាងសេចក្តីអាក្រក់គឺសេចក្តីទុក្ខនោះ ពុំបានឡើយ សូម្បីអ្នកដទៃខំប្រឹងព្យាយាមជួយឈឺឆ្អាលឲ្យពឹងផ្អែកយ៉ាងណាក៏ដោយ, សេចក្តីទុក្ខដែលជាផលនៃសេចក្តីអាក្រក់នោះ គង់កើតឡើងប្រាកដជាក់ស្តែងយូរឆាប់ពុំខានសមដូចពុទ្ធភាសិតថា "ធ្វើអាក្រក់ បានផលអាក្រក់ ដូចស្រមោលអន្ទោលតាមប្រាណ"ដូច្នោះ ។ យ៉ាងនេះល្មមបញ្ជាក់ឲ្យឃើញបានថា មុននឹងទីពឹងអ្នកដទៃនោះ យើងត្រូវពឹងខ្លួនយើង គឺត្រូវមានសេចក្តីល្អយ៉ាងណាមួយជាមូលហេតុសិន ទើបពឹងគេបាន ។ ការពឹងអ្នកដទៃតែម្យ៉ាងនោះមិនបានទេ ព្រោះជាការពឹងមិនឋិតថេរ តែបើទុកជាពឹងគេបាន ក៏បានត្រឹមតែជាតិនេះប៉ុណ្ណោះ ។

ឯការពឹងគ្នាបានក្នុងជាតិនេះនិងជាតិមុខៗ ដល់ទីបំផុត ក៏រួចចាកទុក្ខភ័យ គឺ ជាតិ ជរា ព្យាធិ មរណៈ នោះ យើងត្រូវពឹងព្រះធម៌ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺព្យាយាមប្រតិបត្តិតាម ឲ្យបានល្អបរិសុទ្ធ ។ ក៏ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធនោះ មានច្រើនជាអនេក, ប៉ុន្តែ ធម៌សម្រាប់ធ្វើខ្លួនឲ្យជាទីពឹងនោះ ហៅថា នាថករណធម៌ មាន ១០ យ៉ាងគឺ

១– សីលៈ រក្សាកាយវាចាឲ្យរាបសា ,

២– ពាហុសច្ចៈ ភាពជាពហុស្សុត,

៣- កាលញ្ញូណាមិត្តតា ភាពជាអ្នកមានមិត្តល្អ,

៤- សោវចសុតា ភាពជាបុគ្គលដែលគេបាយប្រដៅ,

៥- ឥតិការណីយេសុ ឧក្ខិតា ភាពជាបុគ្គលបុំនប្រសប់មិនខ្ជិល គឺឧស្សាហ៍ខ្នុះខ្នែងក្នុងកិច្ចធ្វើរបស់មិត្តអ្នកប្រព្រឹត្តធម៌ជាមួយគ្នា,

៦- ធម្មកាមតា ភាពជាអ្នកស្រឡាញ់ធម៌ ចូលត្រេកអរក្នុងធម៌,

៧ វីរិយ: ព្យាយាមដើម្បីលះបង់សេចក្តីអាក្រក់ហើយប្រព្រឹត្តល្អ,

៨- សន្តោស: សន្តោស ត្រេកអរចំពោះវត្ថុដែលជារបស់ខ្លួនតាមមានតាមបាន,

៩- សតិ សេចក្តីលឹកបានទ្រទ្រង់កិច្ចការដែលធ្វើហើយ និងពាក្យសម្តីដែលនិយាយហើយ,

១០- បញ្ញា ដឹងច្បាស់ក្នុងកន្លងនូវតាមសភាពដែលពិតមែន ។

អ្នកដែលប្រព្រឹត្តធម៌ ១០ ប្រការនេះ ទាំងពីរអ្នកណាវ៉ៃ គេក៏មិនមានសេចក្តីរង្គ្រាស ព្រោះខ្លួនជាមនុស្សមានគុណ គឺសេចក្តីល្អនៅក្នុងខ្លួនដែលជាផលនៃការពឹងព្រះធម៌ គឺប្រព្រឹត្តតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បានឈ្មោះថា ធ្វើខ្លួនរបស់ខ្លួនឲ្យជាទីពឹងដល់ខ្លួនឯង ។

អ្នកដែលមានទាឋការណធម៌ ១០ ប្រការនេះ ឈ្មោះថា ជានខ្ជូនានខ្ជនដោយល្អ រមែងបានទីតាំងដ៏ល្អយ៉ាងឯក គឺព្រះនិព្វានដែលជាទីពឹងមិនជាប់ដោយទុក្ខពាំងពួង ជាទីពឹងដែលគេបានដោយក្រកន្ធ លោក ។

ទ្រព្យ ដ្ឋ ប្រសើរនេះ គ្មានមានអ្នកណាមួយអាចជួយគ្នាបានទេ ដែលនឹងជួយគ្នាបាននោះ ត្រឹមតែប្រាប់ផ្លូវប៉ុណ្ណោះ ។ ឯការដើរទៅតាមផ្លូវនោះ ស្រេចតែខ្លួនឯងដើរ ទើបបានដល់, សម្ដីមាតាបិតាដែលជួយចិញ្ចឹមបម្រុងបុត្រធីតា គ្រាន់តែជួយផ្ដល់ឲ្យបានប្រើប្រាស់ មានសំពត់ឬភោជនាហារជាដើមប៉ុណ្ណោះ ត្រង់ការស្ដាប់ជណ្ដាប់ ឬលេងចូលទៅ ជាការលើកបុត្រធីតាធ្វើខ្លួនឯង ។ ត្រង់នេះ អាចចូលចិត្តបានថា ការពឹងពាក់អ្នកដទៃ សម្ដីមិនធ្វើតាមធម្មតាក៏មិនបាន តែជាទីពឹងមិនមាំ ព្រោះធម្មតាក៏មិនបានតាំងគោលច្បាប់ឲ្យមនុស្សត្រូវតែពឹងគ្នាជានិច្ចទេ ។ ធម្មតាបានកំណត់ផ្លូវឲ្យយើងត្រាត់ប្រាសនិងសចាកគ្នា ហើយត្រូវលត់អស់ជីវិតទៅជាទីបំផុត ។ ហេតុនេះ ត្រូវខ្លួនខ្ជាន់ខ្លួនឯងឲ្យតាំងនៅក្នុងគុណធម៌ គឺសេចក្ដីល្អជានិច្ច ទើបឈ្មោះថា ខ្លួនឯងជាទីពឹងរបស់ខ្លួន ដោយពិត ព្រោះអាចបណ្ដុះសិល្បវិទ្យាឲ្យកើតមាននៅក្នុងខ្លួន តាមសមគួរដល់ឋានៈនិងសេចក្ដីអង់អាច ។

សេចក្ដីដែលបានសម្ដែងមកនេះ បញ្ជាក់ឲ្យឃើញច្បាស់ថា ទីពឹងខ្លួន គឺធ្វើខ្លួនឲ្យមានសេចក្ដីល្អបរិសុទ្ធ គឺថាធ្វើខ្លួនឲ្យមានទាឋការណៈធម៌នៅក្នុងខ្លួន ទើបទីពឹងអ្នកដទៃ ឬរបស់ដទៃ រហូតដល់មគ្គផលសួគ៌និព្វានបានដោយពិត, ព្រោះហេតុនោះ បានជាព្រះសក្យមុនីគោតមបរម-

សៈស្ពាចារ្យអនាវរណញ្ញាណ ទ្រង់ត្រាស់ថា អត្តា ហ៉ា អត្តនោ
នាថោ "ខ្ជួនឯង ជាទីពឹងរបស់ខ្ជួន" ។

ដល់មកត្រង់នេះ, ល្មមចូលចិត្តបានថា ត្រូវធ្វើខ្ជួនឲ្យជាទីពឹងរបស់
- ខ្ជួន ឲ្យបានមុនពឹងអ្នកដទៃ ។

ចប់ អត្តនាថកថា ដោយសង្ខេប ។

(ស្រង់ពីប្រដុំធម្មកថា)



រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ន្ធ - ភន

ប្រែ - ឡេបឡេង

(ត)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ	អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន	ទាំងមានសន្ធានស្នេហាជាតិ

—— យូរ-អ៊ុន ——

សាមកុក ឡៃ ៣៣

តាំងពីព្រះចៅចូយ៉យព្រួយព្រះទ័យ ដួបជុំមុខមន្ត្រីត្រឡប់ឲ្យហៅយកខ្លួនសុម៉ាអ៊ីចូលមកធ្វើមេទ័ពលើកទៅច្បាំងនឹងខុងបេង, បេងតាត់ ត្រឡប់ចូលមករួបរួមធ្វើការទាងព្រះចៅឡៅ-សៀន ហើយលើកទ័ពទៅវាយស្រុកឡុកអៀង, សុម៉ាអ៊ី លើកទ័ពទៅសម្លាប់បេងតាត់បានរហូតដល់សុម៉ាអ៊ី ឡោមព័ទ្ធអ៊ុយអៀន, កោសៀងបែកទ័ព រត់ត្រឡប់ទៅស្រុកលីវិសៀ ។

ព្រះចៅចូយ៉យទ្រង់ជ្រាបតាមសំបុត្រ កឹស្ទុតព្រះទ័យភ័យណាស់ ត្រាស់ឲ្យប្រជុំក្រុមប្រឹក្សានឹងបណ្ណានាម៉ឺនទាំងពួងថា : កងទ័ពស្រុកយើងបាញ់ប្រៀបទ័ពខុងបេង ប្រឹងរត់បែកខ្ចែកមកដូច្នេះ, អស់អ្នកទាំងឲ្យាយនឹងយល់ដោយអភិប្រាយយ៉ាងម្តេច ? ហ្លួហ៊ឺមក្រាបទូលថា : ទ័ពខុង-បេងលើកមកត្រានេះធំពន្ធឹកសន្ធឹកសន្ធាប់ណាស់ , បើនឹងលះចិត្តគិតតែ

ទៅសៀមពុំគិត , មុខជាខុងបេងប្រឹងរុកកានទ្រានចូលមកដិតហើយ , ក្រោយទៀត យើងក៏ធ្វើការដោយលំបាកណាស់ , សូមព្រះអង្គទ្រង់គិតឲ្យហ៊ាសលើកទ័ពលួងចេញទៅឯដែលទើបបាន, អស់នាម៉ឺនតូចធំទាំងប៉ុន្មានដែលបានតាំងចិត្តគិតប្រឹងធ្វើការថ្វាយឲ្យអស់ថ្លៃដែ ។

ចុងហ៊ីវ ក្រាបទូលថា : ឯធម្មតាមេកងទ័ពធំ សមគួរនឹងត្រួតត្រាបង្គាប់បញ្ជាលើមេនាយ ឲ្យដឹងទីបង់ទីបាន ហើយចេះយកចិត្តសេនាពហានឲ្យចម្រើនបានការ ក៏អាស្រ័យដោយមានសតិបញ្ញានិងអធ្យាស្រ័យប្រពៃល្អមែន ។, តែបើឃើញថា នរណាវៃក្ងុនស្ងាត់ប្រាកដក្នុងរណរង្គសង្គ្រាម , ក៏ញ្ញាយាមទំនងលើកគុណបំណាច់ឲ្យជាប់លើសគេ , បើឃើញថា នរណាមិនបានការអ្វីទេ ឬធ្វើខុសលោះលើសពីបញ្ញត្តិ, ក៏ត្រូវប្រិតឲ្យមានទោសតាមធ្ងន់ស្រាល ផ្ទាល់ឲ្យរ៉ែងក្រែងខ្ទាច តាមអំណាចមេទ័ព , ដូចជ្ជដែន ក៏ជាធំហ៊ានម្ចាប់តែធ្វើការជានាម៉ឺនក្នុងប៉ុណ្ណោះ, លុះនឹងឲ្យចុះទៅកាន់កាប់ជាមេកងទ័ពធំ ក៏មិនសមជាគ្រូដែនឹងខុងបេងឲ្យតាំងនេះបាន, ខ្ញុំលព្រះបង្គំ យើញមានតែមនុស្សម្នាក់មានសិទ្ធិស័ក្តិខ្ពាំងពូកែមុតមាំសមជាមហានាយកខាងការណរង្គសង្គ្រាម , បើព្រះអង្គទ្រង់ប្រោសឲ្យចេញទៅតទល់នឹងខុងបេងហើយ ត្រឡប់ទៅជាបាត់ជ័យចាញ់ថ្លៃដែខុងបេងវិញ, ខ្ញុំលព្រះបង្គំហ៊ានជានាថ្វាយសិរសាឲ្យអស់ទាំងគ្រោត, តែក្រែងព្រះអង្គមិនចង់ពិសោធឲ្យឃើញច្បាស់ការ ។

ព្រះចៅចូយ៉ាយគ្រាស់ថា : ឥឡូវ ខុងបេងធ្វើការកម្រើបចិត្តតែតែ ទ្រានចូលមកហើយ, បើអ្នកកាល់ គ្នាយល់ឃើញថា អ្នកឯណាខ៏ឯ-ណាចេញធ្វើការបាន , ក៏ចូលតិតអានឲ្យប្រមូលឲ្យមូលមាត់គ្នាវើសយកមកធ្វើការចុះ, យើងក៏ភ្ជុំបានយល់ពាស់ទេ ។ ចុងហ៊ីវគ្រាបទូលទៀតថា ឯបណ្ណាមន្ត្រីធំនៅក្នុងក្រុងនេះ ទូលព្រះបង្គំត្រិះរិះមើលមិនឃើញអ្នកឯណាមានតម្រិះប្រាជ្ញាស្រួចស្រាស់ ក៏ចំពោះមានតែសុម៉ាអ៊ី ១ ប៉ុណ្ណោះ ល្ម-ម៏ឯងចេញមុ១ទៅតទល់យកជ័យជម្នះខុងបេងបាន ។ ព្រះចៅចូយ៉ាយគ្រាស់តបថា : អ្នកបានចេញវាចាមកតាំងប៉ុន្មាន ក៏ប្រពៃណាស់ តែឥឡូវនេះ សុម៉ាអ៊ីនៅទីឯណា? ចុងហ៊ីវទូលថា ទូលព្រះបង្គំបានឮដំណឹងថា សព្វថ្ងៃនេះ, សុ"ម៉ាអ៊ីនៅស្រុកអ្ជនសៀ ។

ព្រះចៅចូយ៉ាយទ្រង់ព្រះសណ្ដាប់ ក៏គ្រាស់ប្រាប់អាល័ក្ស ឲ្យតែងព្រះសុភមក្សរជាសេចក្ដីថា : ទ្រង់ប្រាសព្រះពរជានតាំងសុ"ម៉ាអ៊ីឲ្យជាមន្ត្រីធំតាមតំណែងដើម , ហើយឲ្យចាត់ប្រមូលរេហ៍ពលសកលយោធាលើកទៅទល់ទ័ពនៅភ្ជុំគ្ជិសាន , រួមបញ្ចូលគ្នានឹងកងទ័ពលួងតាំងប៉ុន្មានដែលលើកមកពីស្រុកទៀងអាន់ , ដើម្ប"ីនឹងចាត់ចែងឲ្យមានមេកំណាន់លើកទៅតនឹងទ័ពខុងបេង , ហើយក៏ឲ្យព្រះពជបម្រ៉ូតរ្ជតនាំទៅឲ្យសុ"ម៉ាអ៊ីឯស្រុកអ្ជនសៀ ។

ឯខុងបេងតាំងលើកទ័ពទៅឈប់នៅភ្ជុំគ្ជិសានដ៏ងពតិមានថា : ចូដ៏ន

បែកទ័ពរត់ត្រឡប់ទៅក្រោយ ក៏ឲ្យមានសេចក្តីសប្បាយរួសពយណាស់, ១ដ៏ឧត្តមរូតរះបាតលចូលទៅតាំងនៅក្នុងបន្ទាយចូជិន, ១ណៈនេះ មានមនុស្សបម្រើចូលទៅជម្រាប១ដ៏ឧត្តមថា លីផៃ្ស នៅស្រុកតេងអាន់ ប្រើលីអង ជាបុត្រឲ្យចូលមកគំនាប់មហាឧបពាជដោយកិច្ចពាជការ ។ ១ដ៏ឧត្តម ក៏ភ្ញាក់អាត្មាថា អ្ហែ! នេះ ប្រហែលមានកងទ័ពស្រុកកាំងតាំងនឹងលើកមកច្បាំងយកស្រុកសែឈួនទេដឹង ? ១ដ៏ឧត្តម ក៏ឲ្យហៅលីអងចូលទៅក្នុងហើយសួរថា : អ្នកឯងមកមានការអ្វី ? លីអងជម្រាបថា: ខ្ញុំបាទមកប្រណិប័ត្តន៍មហាឧបពាជនេះ ដោយរឿងឧត្តមតាត់ ដែលត្រូវតែចូលនៅទ្រាងចូកីអ៊ីពីថ្ងៃមុននោះ ព្រោះដោយសេចក្តីភ័យខ្លាចខ្លួនទេ, ឯចិត្តគិតចាំនឹងត្រឡប់មកវិញ, តែចូកីឃើញឧត្តមតាត់មានសតិបញ្ញា ក៏មានមេត្តាប្រោសប្រាណ ចានប្រទានទ្រព្យជាច្រើន, ហើយតាំងឲ្យលឿនទ័ជាមន្ត្រីធំ ឲ្យទៅឈរបន្ទំជាចៅហ្វាយស្រុកសុងយ៉ុង , លុះចូកីទ្ធ្ងតទៅ, ព្រះចៅចូយ៉ីយសោយពាជសម្ផត្ត, អស់នាម៉ឹន ដែលនៅជិតព្រះមហាក្សត្រិយ៍ ចេះតែមានចិត្តឫស្យាញ្ជុះស្ពេចឲ្យដាច់ផ្លូវមេត្តាសោះ, ពេលនេះ ឧត្តមតាត់ក៏អស់សេចក្តីសុខសប្បាយ តាំងចិត្តគិតព្រះគុណ ១ដ៏ឧត្តមដែលមានលើខ្លួនមកពីអតីត , ទើបរិះគិតចាត់ប្រើខ្ញុំបាទឲ្យមកសូមសារ ១ដ៏ឧត្តមថា ការដែលបានប្រព្រឹត្តខុសទៅហើយនោះ, សូមឲ្យមហាឧបពាជអនុគ្រោះប្រោសមេត្តាលើកលាលទៅចុះ , ពីត្រឹមថ្ងៃនេះទៅមុខទៀតនឹងសុំតាំងគំនិតមានយោនធ្វើការកែខ្លួនឲ្យបាន , បើមហាឧបពាជប្រោស

ប្រាណ ក៏សូមឲ្យលើកទ័ពទៅវាយយកស្រុកទៀងអាន់ចុះ, បេងតាត់ទីធ លើកតាហានស្រុកសុងយ៉ុងខាងណោះ និងស្រុកស៊ីនសៀ, ស្រុកគ្រីម-សៀ បញ្ជូលគ្នាទៅសន្ធាប់គប់វាយទម្លាយយកស្រុកឡ្ការអៀង គបគុណ មហាឧបការដឲ្យបាន ។ ឧកបេងបានស្តាប់សព្ទចប់ពតិមាន ក៏មានអំណារ ណាស់, ឲ្យវង្វាន់ប្រាក់មាសទៅលីអង់ជារច្រើន ។

ខណៈនោះ, មានតាហានល្ងាតនាំហេតុទៅផ្សាយឧកបេងថា: ឥឡូវ ចូយ៉ីយ ឲ្យបម្រើនាំសំបុត្រទៅតាំងសុ៉ាអ៊ី ជានាមុនជំនាំណែង ជាដល ហើយឲ្យប្រមូលរេហ៍ពល ឲ្យក្រាស់ក្រែលលើកទៅបញ្ជូលគ្នានឹង ទ័ពចូយ៉ីយឯស្រុកទៀងអាន់ ។ ឧកបេងដឹងពតិមានដូច្នោះ ក៏លុះស្ទាត់ ក័យដូចគេកន្ត្រាក់ខ្ជួន, ម៉ាចេកដឹងសំនួនក៏ជម្រាបទៅឧកបេងថា ពោះបី ចូយ៉ីយនឹងលើកទ័ពលួងធ្ងងមកតាំងក្នុងស្រុកទៀងអាន់ពិត ក៏មិនត្រូវគិត ខ្វាចអ្វី, ត្រូវតែយើងប្រឹងយកជ័យជម្នះឲ្យបាន ។ ឧកបេងធ្វើយក្ខានថា: យើងមិនមែននឹងកោតញ្ញើតចូយ៉ីយបន្ទិចសោះ , យើងចារម្ភចំពោះតែ សុ៉ាអ៊ី ១ ព្រោះជាមនុស្សមានសតិបញ្ញាស្រៀវស្រួចណាស់, ពោះបី បេងតាត់ទីធក្រឡាស់លើកទ័ពទៅវាយយកស្រុកត្រុងនោះ បើប្រទះនឹង ទ័ពសុ៉ាអ៊ី ក៏គង់ទីធ ខ្ជេចខ្ជីពុំខាន ព្រោះបេងតាត់ពុំបានជាមនុស្សមាន ប្រាជ្ញាស្មើនឹងសុ៉ាអ៊ី ។

ម៉ាចេកបានស្តាប់ ក៏យល់ឃើញត្រូវ ទើបនិយាយថា បើដូច្នោះ យើងនឹងបណ្តាយ ឲ្យបេងតាត់ជ្ជានសេចក្តីអន្ទ្ធាយម្ដេចបាន, ត្រូវតែ

មានសំបុត្រទៅគឿនរំពុកស្នាតីបេងតាត់ ឲ្យប្រុងប្រយ័ត្នខ្ជួន ដោយមួនមាំ ។ ពុងបេង ក៏ធ្វើសំបុត្រផ្ញើទៅឲ្យបេងតាត់ថា ត្រាតបេងតាត់ ជាអ្នកមានសតិបញ្ញា គិតនឹងធ្វើកាលើកទ័ពទៅវាយយកស្រុកឡុកអៀងស្ងួតគុណព្រះបៅឡៅសៀននោះ, យើងក៏មានចិត្តស្ទុះត្រេកអរនឹងអ្នកណាស់, បើសម្រេចដូចប្រាថ្នាវេលាណា យើងនឹងយកសេចក្តីក្រាបបង្គំទូលព្រះបៅឡៅសៀនជាម្ចាស់ ឲ្យទ្រង់លើកគុណចំណាចឲ្យជាប់លើសគេ, តែឥឡូវនេះ យើងបានឮកិត្តិស័ព្ទថា ចូយ៉ីយតាំងសុម៉ាអ៊ីជាមេកងទ័ពធំ, ឲ្យលើកវេហ៍ពលមកប្រដុំនឹងទ័ពលួងទៅស្រុកទៀងកាន់, បើសុ-ម៉ាអ៊ីដឹងថា អ្នកឯងប្រែប្រួលកាន់ជាចូលមកទាងយើងវិញ, គង់នឹងលើកទ័ពមកផ្ទាញ់បំបាក់ទ័ពអ្នកដែលជាមុខ១សឹកមុន, អ្នកឯងគង់នឹងធន់ពុំបាន, ត្រូវអ្នកនឹងរិះគិតរកាំងខ្ជួនប្រាណកុំគប្បីប្រមាទ, បើនឹងប្រើតហាន ត្រូវឲ្យស្គាល់បទបាទខ្ជាតពីដំយសង្គ្រាម, កុំធ្វើតាមចិត្ត ហើយត្រូវបាំងបិទកុំឲ្យដឹងកល់ដល់សុ-ម៉ាអ៊ី, លុះសរសេរហើយ ក៏ប្រកប្រាមបិទដិតប្រគ្ងល់ឲ្យលីអង្ការ ទៅឲ្យបេងតាត់ឯស្រុកសុងយ៉ុង ។

លីអង ក៏ចូលទៅដល់បេងតាត់, ហើយអធិប្បាយពាយរឿងឲ្យស្តាប់ត្រាប់ប្រការ, ហុចតាងសំបុត្រសារទៅឲ្យ, បេងតាត់ ក៏លាមើលឃើញសេចក្តីសព្វគ្រប់ ក៏អស់សំណើចហើយថា គំនិតប្រាជ្ញាពុងបេងនេះ សេសមែនណាស់ តែហួសលើសការពេក, បេងតាត់ក៏ផ្ញើសំបុត្រ ១ ច្បាប់ឆ្លើតឆ្លាប់ទៅពុងបេងវិញ សេចក្តីថា : ខ្ញុំបាទ បេងតាត់, សូមក្រាប-

ប្រណិបត្តន៍ចូលមកមហាឧបាសក សូមជ្រាប, ដែលប្រសាសន៍មានមេត្តាជួយរំឭកសតិបញ្ញាខ្ញុំបាទតាំងប៉ុន្មាន, មានព្រះគុណធ្ងន់ ជាអនន្តអនេកណាស់, តែដែលមានប្រសាសន៍ថា សុ"ម"ាអ"ុ"ានោះ, សូមកុំឲ្យព្រួយអ"ី"ឡើយ, ជាក្នាក់ការនៃខ្ញុំបាទហើយនឹងទទួលជាធុរៈឯង, ព្រោះសុ"ម"ាអ"ុ"សព្វថ្ងៃនៅមានកន្លែងឯស្រុកអ"ូ"នសៀ, ចម្ងាយផ្លូវ ពីស្រុកនោះទៅដល់ក្រុងឡុកអៀង ៨.០០០ សិន (៣២០ គម), បើពីក្រុងឡុកអៀងទៅដល់ខេត្តខ្ញុំបាទចម្ងាយ ១២.០០០ សិន (៤៨០ គម), ទោះណាជាសុ"ម"ាអ"ុ"ដឹងកិច្ចកលយល់ជ្រៅណាស់ នឹងចាត់ការហ"ៅ"សទៅ"ប"ាប់ចូ"យ"យ ហើយទើបលើកទ"ៅ"ត្រឡប់ទៅដល់ខេត្តខ្ញុំបាទ ក"ៅ"អស់រៀង ១ ខែ ស្ទើរនឹងមិនដល់ ។ ប្រការ ១ ទៀត, ពលពាហនៈដែលមានតាំង ៣ ខែត្រនោះ, ខ្ញុំបាទក"ៅ"ចានកណ្ដាប្រមូលទុកអស់ហើយ, ទោះបីបើសុ"ម"ាអ"ុ"លើកទៅដល់, ខ្ញុំបាទ ក"ៅ"មិនព្រួយរវល់នឹងខ្ជាចក្រែង, ត្រូវតែប្រឹងប្រែងយកជ័យជម្នះឲ្យបាន ។ លុះសរសេរចប ក"ៅ"ចាត់ចម្រើ គឺ លីអង"ឲ្យ"ការ"ត"ត្រឡប់ទៅជូនខុងបេង ។ ដឹងក្នុងសេចក្ដីសំបុត្រដូច្នោះ ក"ៅ"ឲ្យ"ន"ឹ"ក"ខ"ឹ"ងខ្លាំងណាស់, ចោះសំបុត្រនោះចោលទៅដី ហើយស្ទុះដៃក្ដាប់ដៃទ្រ"ា"ំ"ដ"ើ"ងថា បេងតាត់ គិតការនេះ ពេញជាមើលងាយគេណាស់ នឹងស្ងាប់ស្រឡះ ព្រោះថ្ងៃដែ"ល"សុ"ម"ាអ"ុ"ពុ"ំ"ានទេ ។

ម"ា"ចកសួ"ួ"រថា ហេតុអ"ីម"ានជាមហាឧបាសកមានប្រសាសន៍ដូ"ច"ច្នេ"ះ"? ខុ"ង"ប"ង"ឆ្ងើ"យ"ថ"ា : ពាក្យចាស់ពុ"ក"ណ"ា"ម"ានពោ"ល"ទ"ុ"ក"ម"ក"ថ"ា ធ"ម"្ម"ត"ា"ម"ន"ុ"ស"្ស

ដែលកូតផ្ទៃដី, បើគេមិនដឹងសេចក្តីឲ្យច្បាស់ ទើបលះចេញទៅធ្វើការ
ចានស្រួល, ដូចយ៉ាងបេងតាត់ ត្រូវបាត់ដោយទ្រនង់អង់អាចដូច្នេះ
ឃើញថាខុសនឹងចាស់ចុងណាស់; ឯសុម៉ាអ៊ី គេជានាម៉ឺនធំណាស់,
បើដឹងច្បាស់ថាបេងតាត់ក្ងាត់ហើយ គេមិនចាំបាច់ទៅទូលស្តេចចូយ៉ាយ
ឲ្យយូរការទេ, គង់តែគេនឹងស្រូតលើកទ័ពទៅក្នុង ១០-២០ ថ្ងៃឲ្យដល់
ទៅខ្លួនបេងតាត់, បើមិនប្រុងប្រយ័ត្ន មុខជាអន្ទាយខ្លួន, លុះគេធ្វើការ
ពេញសំនួនហើយ ទើបយកសេចក្តីទូលឲ្យជ្រាបជាក្រោយ មិនបានឬ?
អស់ពួកនាយទាហានបានសេចក្តី ក៏ស្រដីសរសើរគំនិតខុងបេងគ្រប់គ្នា,
ទើបខុងបេងតែងសំបុត្រ ១ ច្បាប់ចង្អាប់ឲ្យបម្រើនាំទៅឲ្យបេងតាត់, សេចក្តី
ថា ឲ្យបេងតាត់ប្រុងប្រយ័ត្នខ្លួនជាមួនមាំឲ្យណាស់, ក្រែងការនេះដឹងទៅ
ដល់សុម៉ាអ៊ីហើយ មុខជាថ្ងៃការ ។ បម្រើក៏នាំសំបុត្រចេញទៅ ។

ឯសុម៉ាអ៊ីនៅស្រុកអ្ងនសៀដឹងថា ព្រះចៅចូយ៉ាយលើកទ័ពចេញទៅ
តច្បាំងនឹងខុងបេង ចាញ់ប្រៀបជាច្រើនក្លា ក៏ឲ្យឈឺផ្ទាក្នុងចិត្ត ចេះតែ
អង្គុយគិតហើយដកដង្ហើមធំ, សុម៉ាស៊ូ និង សុម៉ាចៀវជាបុត្រា មានសតិ
ប្ញាណ្ឌ្ងៀវ្ងាត , បិតាបានបង្ហាត់បង្រៀនសិល្បសាស្ត្រឲ្យចេះខាងតម្រិះ
ក្ងួនពិជ័យសង្គ្រាមតាំងពីទើបដឹងក្តី លុះឃើញបិតាជាទុក្ខសញ្ជប់សញ្ជឹង
សព្វទិនរាត្រី ហើយមិនចេញស្រដី ចេះតែដកដង្ហើមធំដូច្នោះ ក៏ចូលទៅ
ពាក្រ្ទោះជម្រាបសួរថា បិតាកើតទុក្ខព្រួយពីអ្វី? សុម៉ាអ៊ីឆ្លើយថា ចៅឯង
នៅក្មេងណាស់, បើបិតាប្រាប់ឲ្យច្បាស់ ក៏ពុំអាចដឹងដល់, សុម៉ាស៊ូ

ធ្វើយថា រឿងដែលបិតាកើតទុក្ខវិតក្កព្រួយនោះ, ខ្ញុំបានដឹងយល់អស់ហើយ, ព្រោះព្រះចៅចូយ៉ាយធ្វើល្មើសលើយើងណាស់, ចានជាមានសត្រូវមកប៉ះពុំកោតខ្ជាបអំណាចព្រះបេស្ត្ត ។

សុម៉ាចៀវឮហើយធ្វើយថា: ខ្ញុំបងតែអស់សំណើចទេ ដែលបងថាដូច្នោះ, តែការនោះ សូមកុំឲ្យបិតាព្រួយឡើយ, ព្រោះខ្ញុំបានគ្នាមើលហើយ, បើមិនព្រឹក ក៏ថ្ងៃរសៀលនេះ, មុខជាមានតម្រាស់ព្រះចៅចូយ៉ាយឲ្យមកដល់បិតា ។ គង់ទឹងបានទទួលពាជការជួយទំនុកបម្រុងផ្ទៃនដ៏ជាប្រាកដ, លុះនិយាយមិនទាន់ផុតមាត់ ស្រាប់តែឃើញអ្នកកាន់ព្រះតម្រាស់ចូលទៅដល់, សុម៉ាអ៊ីក្រេឡេកទៅយល់ស្គាល់ជាព្រះពាជបម្រើកាន់ព្រះតម្រាស់ ក៏ត្រេកអរមហិមា, ចុះទៅលុតក្រាបវន្ទាដោយកិរិយាគោរពហើយ ក៏អញ្ជើញទៅតម្កល់លើតុតាំង រួចបានមើលដឹងសេចក្ដីហើយ ក៏រលះរលាំង ឲ្យកេណ្ឌប្រមូលរេហ៍ពលសកលយោធានឹងលើកទៅស្រុកខ្ទៀងអាន់តាមព្រះតម្រាស់ ។ ក្នុងពេលនោះ ពួកលក្ខាតចូលទៅជម្រាបថា មានបម្រើពីសុិនធីចៅហ្វាយស្រុកគ្រីមសៀឲ្យមកជ្ជ្ជ្ជ ជាសម្ងាត់, សុម៉ាអ៊ី ក៏ឲ្យហៅចូលទៅ, បម្រើនោះក៏ជម្រាបថា : ចៅហ្វាយខ្ញុំបានឲ្យមកជម្រាបលោក, ដ្ឋិតបេងតាត់ចៅហ្វាយស្រុកសុងយ៉ុង ប្រែចិត្តក្បត់ទៅចូលគំនិតនឹងខុងបេងហើយ, គេងហៀនឹងលីដូទៅប្រាប់សុិនធី ។ ប្រើខ្ញុំបានឲ្យស្រួតរូតមកជ្ជ្ជ្ជ ។

សុម៉ាអ៊ីក៏និយាយថា: បើប្រសិនជាបេងតាត់ទៅចូលគំនិតនឹងខុង-

ហេតុមិន មុខជាហេតុតាត់ទឹងសុំអាសាលើកទ័ពទៅវាយយកស្រុកឡុក-
ឆៀងហើយ, ឯខុងហេតុ គង់ទឹងចូលវាយយកស្រុកឆៀងអាន់ខាងណោះ
មុខជានឹងសម្រេចដោយងាយ, នេះហាក់ជាបុណ្យ ព្រះចៅចូយ៉ីយទៅ
មានវាសនាបារមីបុណ្យមកអកិបាល ទើបបណ្តាលឲ្យព្រះចៅចូយ៉ីយមាន
ព្រះទ័យមេត្រីកប់អានយើងវិញ, ហើយតាំងយើងឲ្យធ្វើជានាម៉ឺនធំដូចដើម
ថែមទាំងឲ្យយើងបានដឹងរឿងនេះ, យើងនឹងស្ងៀមពុំត្រិះរិះក៏ពុំបាន, ត្រូវ
តែគិតអានលើកស្រួតទៅចាប់ខ្លួនហេតុតាត់ កាត់ផ្តាច់កិច្ចកលយោបល់
ខុងហេតុជាមុន, ទើបខុងហេតុនឹងអ័ហេតុ១ យ៉ីទ័ពលើកត្រឡប់ទៅឯង ។
សុ៉ាស៊ីថា: ហេតុតាត់ គាត់ជានាម៉ឺនធំខ្ពស់, ហើតាមពិគ្រោះ គួរតែហ៊ីតា
ធ្វើសំបុត្រក្រាបទូលព្រះចៅចូយ៉ីយឲ្យជ្រាបសិន, សុ៉ាអ៊ីថា: ធម្មតាការ
ក្បត់ផែនដីនោះ, ហើនឹងរង់ចាំពិគ្រោះទូលស្នើ ក៏ពុំបាន, ព្រោះសត្រូវនឹង
មានកម្លាំងច្រើនឡើងទៀត, ត្រូវតែយើងគិតធ្វើតលើកទ័ពទៅចាប់ខ្លួន
ហេតុតាត់ឲ្យហើយ សឹមយកសេចក្តីក្រាបទូលឲ្យជ្រាបជាក្រោយទើបបាន,
ហើយសុ៉ាអ៊ី ក៏ត្រិះគិតប្រើកលឧបាយឲ្យឈ្លោះលឿងគី កាន់សំបុត្រ
ទៅប្រាប់ហេតុតាត់ជាសេចក្តីថា: ឲ្យហេតុតាត់ចាត់ចែងកងទ័ពនឹងប្រជាប់
ស្បៀងអាហារបម្រុងការទុកឲ្យព្រមបុះ, យើងនឹងលើកកងទ័ពខាងណោះ
មកបញ្ចូលផ្សំនឹងស្រុកឆៀងអាន់ ដើម្បីនឹងធ្វើការណាវ៉ាសង្គ្រាមតនឹង
ខុងហេតុ ។ លុះលឿងគីកាន់សំបុត្រចេញទៅហើយ, សុ៉ាអ៊ី ក៏ចាត់
ការប្រមូលយោធាពាហនលើកចេញចាកហ៊ានចំនួនផ្ទៃ ២ ថ្ងៃ, ប្រទះនឹង

ស៊ីឡាងលើកទ័ពជ័យទៅដល់, ស៊ីឡាង ក៏ចុះពីលើសេះ ចូលទៅជម្រាបសុម៉ាអ៊ីថា: ដ្ឋានព្រះចៅចូយ៉ាយ បានរៀបចំប្រមូលពលទាហានលើកទៅស្រុកទ្រៀងអាន់ ហើយជ្រាបថា ត្រែងលោកនៅយឺតយូរការ, បានជាប្រើខ្ញុំបានឲ្យមកតាម ដើម្បីឲ្យស្រួតរួតទៅប្រញាប់, សុម៉ាអ៊ីបានស្តាប់ក៏ឆ្លើយតបថា ឥឡូវនេះ បេងតាត់ចេញជាក្បត់ទៅហើយ, ខ្ញុំលើកទ័ពទៅចាប់សិន, ហើយក៏ពណ៌នារឿងក៏ឲ្យស៊ីឡាងស្តាប់គ្រប់ប្រការ ។ ស៊ីឡាងថា បើដូច្នោះ គួរហើយ ។ សុម៉ាអ៊ីឆ្លើយថា អ្នកឯងត្រូវទៅជាមួយនឹងខ្ញុំ, ក្រុមរបស់អ្នក ត្រូវចេញជាទ័ពមុខ, ខ្ញុំឲ្យបុត្រាខ្ញុំ ២ នាក់ជាទ័ពក្រោយ, ក៏ឲ្យលើកព្រមគ្នាទៅដល់ពាក់កណ្តាលផ្លូវ ប្រទះនឹងពួកទាហានបេងតាត់ដែលកាន់សំបុត្រទៅឲ្យ១ងបេងនោះ ត្រឡប់ពី១ងបេងមកវិញ ។ ក១ងទ័ពឃើញប្ចូកក៏ស្រែកស្ងាត់ចាប់ខ្លួនបាននាំទៅជួនសុម៉ាអ៊ី ។ ក៏ដណ្តឹងសួរពិចារណាថា ឯងជាទាហានអ្នកណា ? មកពីណា ? ទៅណា ? ឲ្យឆ្លើយតាមត្រង់ ទើបគង់អាយុជីវិត, បើឆ្លើយមិនពិត នឹងកាត់ក្បាលឥឡូវនេះ, បម្រើកាន់សំបុត្រនោះភ័យខ្លាំងណាស់ ក្រាបសំពះហើយឆ្លើយឲ្យការតាមត្រង់គ្រប់ប្រការ, យកទាំងសំបុត្រលេខារបស់១ងបេងនោះឲ្យទៅសុម៉ាអ៊ី ។ មើលដឹងសេចក្តី ក៏ភ័យណាស់និយាយថា តម្រិះប្ចូជ្ញា១ង-បេងនោះ ត្រូវដូចគំនិតយើងគិតទាំងអស់, បើប្រសិនណាជាបេងតាត់ដឹងតាមសំបុត្រនេះហើយ, កាលណាឡើយយើងនឹងធ្វើការនេះទៅរហូតបាន, មុខជាបេងតាត់នឹងទំស្រួតរួតធ្វើតាមពាក្យ១ងបេងបង្គាប់, ការ

គេក៏បានចំណាប់យ៉ាងមាំណាស់, នេះហាក់ថា អម្ចាស់យើងមានបុណ្យ
អស្ចារ្យ បានជាមានទេព្តាមកបណ្តាល ឲ្យយើងចាប់អ្នកកាន់សំបុត្រនេះ
បាន, ហើយសុម៉ាអ៊ីក៏ស្រួតលើកគាហានឡេទៀត ។

ឯបេងតាត់ នៅស្រុកសុងយ៉ុងនោះ ឲ្យមនុស្សឡេបបួលសុិនងីថៅ
ហ្វាយស្រុកគិមសៀ និងសុិនតាំថៅហ្វាយស្រុកសុិនសៀ ឲ្យចូលគំនិត
តាមខ្លួន ។ ថៅហ្វាយស្រុកគាំង ២ ខ្ទាចបេងតាត់ ក៏ទទួលព្រមតាមតែ
មាត់ក្រៅដោយស្មោះ, ឯក្នុងពោះគិតបម្រុងគាហានទុកស្រេច, បើសុ-
ម៉ាអ៊ីលើកទ័ពមកកាច់ពេលណា នឹងអាសាធ្វើជាកលសឹកខាងក្នុង ។ បេង-
តាត់ក៏ជឿស្ទុងក្នុងចិត្តឥតសង្ស័យ, ទទួលលៀងគីកាន់សំបុត្រសុម៉ាអ៊ីឡេ
ជល់, បេងតាត់ទទួលយកឡេមើលដឹងសេចក្តីហើយសួរថា ឥឡូវសុ-
ម៉ាអ៊ីលើកទ័ពមកហើយឬនៅ ? លៀងគីក្រូងប្រាប់ថា: សុម៉ាអ៊ីចាត់
ចែងកងទ័ពលើកត្រឡប់ឡេស្រុកទៀងអាន់ហើយ ។ បេងតាត់ព្ធជូច្នោះ
ក៏សោមនស្សត្រេកអរណាស់, ទើបរៀបតុតាំងលៀងអាហារ អញ្ជើញ
លៀងគីបរិភោគផឹកស្រាជាសប្បាយ, ស្រេចហើយ លៀងគីក៏លាបេង-
តាត់ឡើងបំជាយសេះវេះឡេរកសុិនតាំនិងសុិនងី ប្រាប់អំពីការអាថិកំបាំង
ដែលសុម៉ាអ៊ីលើកទ័ពមកនោះឲ្យស្តាប់ត្រប់ប្រការ, សុិនតាំ និងសុិនងីថា:
បេងតាត់ជាក់សញ្ញាឲ្យយើងថា ព្រឹកស្អែក នឹងលើកទង់ខុងបេងឡើងជា
សម្គាល់, ឲ្យយើងអស់ពិកាល់នឹងលើកទ័ពឡេវាយយកស្រុកឡុកអៀង ។

[នៅមានត]

រឿង

គ្រោះថ្នាក់នាទាដោយខ្យល់ញុះ

បេស់លោក ប៉ាម៊ិន្ទណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

(ក)

វគ្គទី ៤៥

រាមេស្ហទៅដល់ត្ហាស៊ីបុ៉រតាំងពីព្រលឹម នៅតាមវិថីនានា ពុំទាន់មានមនុស្សម្នាដើរទៅមកនៅឡើយ អាកាសធាតុត្រជាក់ស្រឹប មើលទៅរុក្ខជាតិនៅតាមដងផ្លូវហាក់ដូចជាខំប្រច្រៀតគ្នា ដើម្បីឲ្យបានកក់ក្តៅដោយស្លឹកត្រសុំត្រសាយ ។ មេឃចុះអ៊ីបត្របលើដំបូលផ្ទះ ហាក់ដូចជាមេក្លានកាងស្លាបក្រុងកូនការពារ អាកាសធាតុត្រជាក់ ។ នៅពេលនោះ រាមេស្ហដិះរទេះតាមផ្លូវ ពាក់អាវរងាមួយយ៉ាងក្រាស់ អ្នកគ្មានព្ធអ៊ីក្រៅអំពីដំណើរបេះដូងអ្នកឡើយ ។

មកដល់មុខផ្ទះ អ្នកបញ្ជាឲ្យរទេះឈប់ អ្នកចុះ ក្នែកវំពៃចោលរកនាងកាមាលា ត្ទូរតែនាងព្ធសូររទេះ ហើយរត់ចេញមកបាំអ្នកនៅមាត់ទ្វារ អ្នកខំហូតប្រអប់កងកមួយពីហោប៉ៅ ដែលអ្នកខំទិញបម្រុងនឹងលើកពាក់ឲ្យនាង នៅពេលដែលនាងរត់មកទទួលអ្នក ប៉ុន្តែ . . . . ទ្វារ

ផ្ទះចាំងអស់ចិត្តដាតឈឹង ដូចជាគ្មានមនុស្សនៅ អ្នកស្រីជាកចិត្ត... ម្តេចដូច្នេះ ?.... ជាកៅពនហាលម្ខាង អ្នកបម្រើម្ចាស់ដេកលក់ដូចស្លាប់ ។ អ្នកការ៉ាមួយសន្ទុះ ទើបជាស់អ្នកដេក ។ អ្នកនឹកក្នុងចិត្ត "យ! ឯងមកពីនោះមកអាចន៍ហោ: ព្រោះវាទេះបារមិនមានចិត្ត មកដល់នេះ គេទទួលឯងបែបត្រជាក់ស្ងួត តាំងពីយប់ម្ង៉ៃ ឯងទន្ទឹងឲ្យតែកូនាប់ទឹងបានឃើញមុខគេ! ឃើញផ្ទះ! មកដល់ទទេស្អាត-លត់ឈឹង-ស្ងាត់ស្ងប-ស្ងាប់អស់រលីង!... ។

ជាស់ល្ងមៗមិនក្ងាក់ទេ ទ្រមក់ អស់យ៉ាងតែម្ពងហើយ ពមេស្ហ ម្ហូមម៉ៅ ចាប់ត្រាក់ អ្នកនោះក្ងាក់ឡើង ស្រឡាំងកាំង ស្ទុះក្រោកអង្គុយ ញ៉ាកែកញ្ជាប់ស្ទេញ ។

-ម្ចាស់ស្រីឯងនៅផ្ទះឬទេ-? (ពមេស្ហសួរ)

-ចាទនៅពន (ជ្ជាធ្វើយតាំងមមីមមើ ហើយទម្ងាក់ដេកងងឹតកៅវិញ)

ពមេស្ហ ខ្ជិលសួរច្រើន ញ្ជាតូរចូលទៅក្នុង ដើរអើតមើលគ្រប់ជ្ជុំ ទទេស្អាត! គ្មានឃើញនាងកាមណាសោះ

ព្រះអាទិត្យកាន់តែកូនាស់ ក្ងនអ្នកក្ងមិ ទូលក្ងមទឹក ដើរហែតាមផ្លូ ។ ទៅលើចិញ្ចើមផ្លូម្ខាងឯនោះ ស្រីៗនាំគ្នាកំនមេ្ម ជជែកគ្នាលាន....

ពមេស្ហដើរមើលសត្ងហើយ ដើរត្រឡប់ទៅដាតអ្នកបម្រើវិញ ហើយ

អង្រួនវាយកតែមែនទែន ម្តងនេះវាមេស្ហលែងចូលហើយ អ្នកដេកធុំក្លិនល្អតុំហ្វូងពីខ្លួន តែវាបានប្រាប់អ្នកថា ពីល្ងាចម្សិលមិញនាងកាមាលានៅៗឡើយទេតើ ក្រែងនាងទៅផ្ទះគេជិតខាងទេដឹង ?

នៅពេលនោះ អ៊ុយមេស្ហដើរមកដល់ ស្លៀកពាក់យ៉ាងស្អាត តែមុខស្រមេះៗ ព្រោះវាអត់ងងុយមើលកាំ វាមេស្ហសួរទៅវា វាគ្មានដឹងនោះអ៊ីសោះ ក៏ចាប់វាឲ្យឡើងជិះរទេះទៅផ្ទះលោកមា ដើម្បីសួរដំណឹងក្រែងលោនាងកាមាលា មកជួយមើលកូននាងសីលា ជា—នាងកាមាលាឥតមានមកទេ (អ្នកផ្ទះឆ្លើយទាំងភ័យឆោទៀត) អ៊ូមី ពីយប់មិញយំពាល់តែខៀវទាំងមុខ មិនព្រមគេងសោះ មិនដឹងជាវាឈឺឥទេ ។ ឃើញអ៊ុយមេស្ហ ដើរចូលមកសួរកម្ចាស់ស្រីវា នាងសីលាឆ្លើយ :

— ចុះពីម្សិលមិញ ឯងទៅជាមួយអ្នកស្រីឯង ម្តេចថាមិនដឹងនិយាយឲ្យស្រួលបួលទៅមើល ... ?

— គាត់មិនព្រមឲ្យខ្ញុំនៅជាមួយគាត់ទេ គាត់ដេញខ្ញុំឲ្យទៅមើលគេកាំនៅផ្ទះស៊ុឌូ បាប៊ូ

— ល្អហើយ-ចុះប៊ីសាន(១)ទៅណា ?

— ខ្ញុំសួរវាហើយ វាថាមិនដឹង ។ វាផឹកស្រាស្រវឹង ដេក

១- អ្នកបម្រើដែលស្រវឹងស្រាដេកអម្បាញ់មិញ ។

លៀកនៅឡើយ តាំងពីយប់មកម្ល៉េះ ។

ប៊ិតិនដើរចូលមក នាងសីលាស្រែកប្រាប់

– ស្តាប់ហើយបង កាមាលាមិនដឹងជាទៅឯណាទេ បងមានជួប កមេស្ហហើយឬនៅ ?

– ជួបហើយ គេថាក្រែងនាងមកឯនេះ . . .

– ទេ ! ទៅបង ទៅជួយរកគ្នាផង . . .

ប៊ិតិននិងកមេស្ហ នាំគ្នាឡើងរទេះសេះដៅទៅសណ្ឋាគារ ។ អ្នកដើរសួរគេឯងគ្រប់គ្នាទៅបានដំណឹងខ្លះថា ពីល្ងាចម្សិលមិញនេះ គេឃើញនាងកាមាលា ដើរឆ្ពោះទៅទន្លេគង្គាតែម្នាក់ឯង នាងមិនព្រមឲ្យគេជូនទៅទេ នាងបានឲ្យលុយទៅប៊ីសានមួយរូបពី ប៊ីសានបានលុយយកទៅផឹកប្រៈក្លាន លុះគេចង្អុលប្រាប់កន្លែង ដែលគេបានជួបទីងនាង កមេស្ហ ប៊ិតិន និងអ៊ុយមេស្ហ នាំគ្នាដើរជាន់លើកញ្ចាំងស្រូវ កាត់ទៅមើលកន្លែងនោះ អ្នកវាំងប៊ីមកដល់មាត់ទឹកក៏ឈប់ឆាករកមើល ព្រោះនៅទីនោះវាលស្រឡះ អ៊ុយមេស្ហ ក៏យស្តោជាងគេ វិលក្អកដោល ដូចមេមាន់បាត់កូន វាចាំស្រែកបន្លឺក រត់ចុះតាមបណ្តោយមាត់ទឹក ។ បន្តិចមក វាក្រឡេកឃើញអ្វី ? នៅមាត់ទឹក ក៏ស្រែកហៅម្ចាស់ប្រុសវា គេនាំគ្នារត់ទៅមើល ឃើញកន្សែងខ្ចប់ក្រវិលកូនសោនិងកន្ទាស់មាស ដែលកមេស្ហបានទិញឲ្យនាង ហើយឃើញជាន់ជើងថ្មីៗនៅលើដីខ្សាច់

នោះ ។ ក្មេងកាយល់សញ្ញាស្ទុះចុះទៅកន្លងទឹក យំផងនិយាយផង ។

-ម៉ែអើយ ម៉ែចង់ទៅចាលខ្ញុំ ឲ្យខ្ញុំនៅជាមួយនឹងអ្នកណា ។

ក្ដីយមេស្ហយំកាសពួកទឹកហើយមិនអស់ចិត្ត ទ្បើងមកយំនៅ្ល លើខ្ទាប់ទ្ទៀត តែពាមេស្ហនៅធ្ងន់ដូចឥតវិញ្ញាណ យ៉ាងម្ដេច-អ្នកកំ យ ហួសចិត្ត អស់សង្ឆឹម មិនយល់គំនិតនាងកាមាលា ពុទ្ធោ ! កម្មអ្ហីមក ពន្ត្រាត់ហើយពន្ត្រាត់ទ្ទៀត មិនចេះអ្ហីចប់ ។

នៅក្នុងផ្ទះលោកមា គេពួសូវតែមាត់រ្ទៀបរាប់ ស្រណោះស្រណោកនឹងសម្ដេងមនុស្សយ៉ាងគ្មានអ្នកណាមួយគិតរកបាយរកទឹកអ្ហីសោះ ។

មិនយូរប៉ុន្មាន ពួកអ្នកនេសាទនឹងក្ដ្រមប្ហ៉ូលិសបានចេញទ្ទូក-ការ្ណូតទៅកន្ទ្ចោចពេញទ្ទេ ។ ត្រ្ចប់ចំណតរថភ្ល្ងើង នឹងឡានគ្ងាយទ្ទូរលេខ ស្ហ្ហ្ក់ចាំងអស់ តែគ្ងានឃើញឈ្ហ្ះកាមាលាសោះ ។

នៅពេលដែលគេកំពុងតែនោ្ទ្ចត្ត្ចប់គ្ងានោះ លោកមាអញ្ជ្ហើញ មកដល់ លុះសួរដើមទង្ហ្ត្ចប់សពួទៅ គាត់ក៏យល់ថា នាងកាមាលា ច្ប្ហ្ស់ជាសម្ងាប់ខ្ជួនមែនហើយ ។

តែពាមេស្ហយំមិនចេញ ទៅជាសួត ក្ដ្ម្ងៀមគ្ងួទ្ទ្ចកយ៉ងទៅវិញ អ្នកនិ-យាយថា អ្នកវើសបាននាងពីក្នុ្ងទឹក ឥឡ្ហ្ងវនេះ ទឹកត្ត្ចូវយកនាងទៅវិញ ហើយ អ្នកដោះស្ស្ម្ងកជ្ជើង ដ្ជើរចុះទៅក្នុងទឹក លុះដល់ក្ប្ហ្ងលជ្ជ្ងន់ ទ្ទើប អ្នកយកកង្ហ្ត ដែលអ្នកទ្ចំទ្ចិញ្ចម្ងងុ្ងកទ្ទ្ចនាង ត្ត្ចូវ្ងងៃ្ងចាលទៅ្ងាយ ។

ត្ត្ចលឹមស្ស្ម្ងកទ្ទ្ចើ្ង អ្នកៈ្ងៀ្ងតវ៉ាន់ចេញចាកគ្ងាស៊ីប៊ីៈ ។ អ្នក

ផ្ទះលោកមារវល់តែព្រួយយំសោក គ្មានអ្នកណាយកចិត្តទុកដាក់នឹងអ្នកសោះ ។

វគ្គទី ៤៦

កាមេស្ហមើលទៅអនាគតរបស់អ្នក ឃើញតែជញ្ជាំងបាំងពីមុខគ្រប់ជុំ ហានតើមានសង្ឃឹមអ្វីទៀត ការងារក៏មិនបានជាប់លាប់ប្រាកដប្រជា ផ្ទះសម្បែងក៏មិនដឹងនៅឯណា— បើតាមទម្ងន់ទុក្ខ ដែលតាមជះជាន់អ្នកមួយផ្ទើមហើយមួយផ្ទើមទៀត ស្ទើរតែគ្មានពេលល្ហែ គួរតែកុំចង់រស់ ៗ រន្ទះបាញ់ពន្លំដើមឈើយ៉ាងណាមិញ រូបអ្នកក៏ប្រៀបបាននឹងដើមឈើយ៉ាងនោះដែរ ។

ដើម្បីនឹងបំភ្លេចទុក្ខ អ្នកចេះតែធ្វើដំណើរពីខេត្តមួយទៅខេត្តមួយ ៗ តាមរថភ្លើងក្តី តាមកប៉ាល់ក្តី អ្នកអង្គុយមើលតែមនុស្ស ដើរចុះដើរឡើង អ្នកទៅមើលព្រះវិហារបុរាណនៅដេល្ហី នៅអគ្រា នៅកជពុទ គានា......... ។ល។

លុះដើរយូរពេកទៅ កាមេស្ហនឹកស្រណោះស្រុកកំណើតរបស់ខ្លួន នឹកស្រណោះកន្លែងដែលអ្នកបានត្រូវសរកាមទេពជាដំបូង អ្នកចេះតែនឹកមមៃៗពេក ក៏ដាក់ចិត្តថា នឹងត្រឡប់ទៅកាលកត្តាវិញ តាមរថភ្លើង ។

អ្នកមកដល់កាលកត្តាយូរបន្តិចហើយដែរ តែអ្នកមិនហ៊ាន ដើរទៅ

ម្តុំកាលត្រូវគ្នាសោះ ថ្ងៃមួយ ដោយចង់ដឹងពេកអត់ទ្រាំពុំបាន អ្នកកំដើរ
រហូតទៅកន្សែងផ្ទះនោះ តែអ្នកមិនហ៊ានបង្ហាញមុខ ក៏ត្រឡប់មកវិញទេ ។
ស្អែកឡើងអ្នកតាំងចិត្តក្លាហានយ៉ាងពេញកំហឹង ក្រោកកំដើរតម្រង់ទៅផ្ទះ
នាងហ៊ីមណាលីនតែម្តង ទៅដល់ឃើញទ្វារបង្អួចចាក់សោរ ស្ងាត់ស្ងប់
អ្នកចង់ចាប់ពត៌មានក៏ចេះតែទ្រាំគោះទ្វារទៀត ក្រែងមានស្ងួនាន់នៅចាំផ្ទះ ។

ចន្ទ្រាមហានជាអ្នកដឹងខាង ដែលអង្គុយជក់ចាវ៉ានៅមាត់ទ្វារផ្ទះគាត់
ក្រឡេកឃើញអ្នកកម្ទេចក៏ស្រែកសួរ :

– ពេមស្ងួ ចាប៉ូ សុខសប្បាយជាទេឬ ? ឥតមានអ្នកណានៅទេ ?

– គេទៅណាអស់ហើយតូ ?

– គាត់ទៅខេត្តក្រៅជាមួយនឹងកូនគាត់ទៅហើយ

– មានអ្នកណាទៅជាមួយគាត់ទៀតទេ ?

– ឥតមានទេ ខ្ញុំឃើញគាត់ទៅតែពីរនាក់នឹងកូនគាត់

– គេប្រាប់ខ្ញុំថា គាត់ទៅជាមួយនឹងណាលីន ចាប៉ូ

– ឥតមានទេ អ្នកនិយាយប្រាប់ក្មួយឯងនឹងផ្លាសទេ កាលពីមុន
ណាលីននៅត្រង់ផ្ទះក្មួយឯងចាស់នោះមែន ប៉ុន្តែណាលីនទៅឯបេណា-
រ៉ែសយូរថ្ងៃទៅហើយ ទើបលោកអ្ណាណាជាទៅក្រោយទេ ។

ពេមស្ងួទំនឹកសួរចន្ទ្រាមហានអំពីណាលីនហើយក៏ដឹងច្បាស់ថាឈ្មោះ
មែនមែនរបស់គេគឺ ណាលីណាក់ស្ងួ ធ្ងន់ចច្ចាយ គេធ្វើពេទ្យ ហើយ

ឥឡូវនេះគេរស់នៅជាមួយម្ពាយមេម៉ាយនៅឯបេណារ៉ស ។ អ្នកសួរ ជំណឹងអំពីជោជេន្ត្រា នឹងសួរអំពីការដែលគេធ្វើជាចាងហ្វាងសាលា រៀនជាន់ខ្ពស់ឈ្មោះមីមេនស៊ីងនោះ ។

ចន្ទ្រាមហានក៏សួរវិញ :

– យូរណាស់ហើយ ក្មួយរវល់ទៅឯណា ចានជាមិនដែលឃើញ

– ខ្ញុំចាទទៅនៅឯគ្ហាស៊ីប៉ុរ៉ឯនោះ

– ឥឡូវគិតត្រឡប់មកនៅឯនេះវិញឬ ?

– ខ្ញុំឥតចង់មកវិញទេ ប៉ុន្តែចាំគិតមើលសិន ។

ត្រាន់តែរាមេស្ហបេញផុត អាក់ស្ហាយមកដល់ភ្លាម ។ ព្រោះមុននឹងបេញពីផ្ទះទៅ ជោជេន្ត្រាបានផ្តាំឲ្យអាក់ស្ហាយឲ្យឧស្សាហ៍ទៅមើលផ្ទះឲ្យផង អាក់ស្ហាយបានទទួលបណ្តាំ ហើយក៏ឥតមានផ្ទេសប្រហែសឡើយ គេមកជាញយ។ ដើម្បីឃ្លាំមើលអ្នកយាម ក្រែងរាដើរចោលផ្ទះ ។

ឃើញអាក់ស្ហាយមក ចន្ទ្រាមហានក៏ប្រាប់ថា រាមេស្ហមកទើបនឹងបេញផុតអម្បាញ់មិញ ។

- រាមកធ្វើអ្វីទៀតហើយ (អាក់ស្ហាយលាន់មាត់ធ្លល់)

– ខ្ញុំមិនដឹងដែរ ។ គេមកសួរអំពីគ្រួសារលោកអាណាដា-ចាប៊ីខ្ញុំមើលសឹងតែមិនស្គាល់ ប្រៃកមែនទែន !

- តើរាមានប្រាប់ថា រាទៅឯណាឬទេ ?

-គេថានៅឯគ្លាស៊ីប៉ូ ប៉ុន្តែឥឡូវនេះគេឈប់នៅហើយ ហើយមិនចាន់កំណត់ថានៅឯណានៅឡើយទេ . . .

ក្នុងពេលនោះ ពាមេស្ត្រឡប់ទៅដល់ផ្ទះវិញ អ្នកនឹកក្នុងចិត្តថា "ចុះត្រហ្ម លិ ១ តនៅតាមធ្វើកម្មធ្វើទោសអ្នកដល់ណាទៀត ក៏មិនចេះចប់យ៉ាងនេះ រឿងជាមួយនាងកាមាលាទើបនឹងហើយក្តៅ។ ឥឡូវនាងមកកេនាងហ៊ាមណាលិនី គេមកកាត់មុខបាត់ទៅទៀត បើប្រសិនជារឿងប្រលោមលោក ដែលគេចង់ក្រងវិញ ប្រហែលជាមានមនុស្សទ១ទៀនមិនចប់ឡើយ! អ្នកណាអាចដឿបាន បើរឿងមើលតែនាងបជាចារទៅហើយនោះ ។ អ្នកនឹកម្យ៉ាងទៅទៀត ឃើញថា ដូចជាស្រាលម្យ៉ាងដែរ ស្រាលត្រង់ដែលគ្មានចំណាន់ប្រចាំជីវិតអ្វីចាំងអស់ ម្ហ៉ះ!ហើយអ្នកធ្វើអ្វីក៏ចាន ម្តងនេះប្រហែលជាធ្ងរស្រាលជាងមុន . . . . ។

ថ្ងៃអាទិត្យក្រោយមកទៀត ជោជន្ត្រាកំពុងតែដេកមើលសៀវភៅក្នុងផ្ទះរបស់គេ ស្រាប់តែមានក្មេងម្នាក់ យកកូនសំបុត្រតូចមួយមកឲ្យអ្នកស្គាល់អក្សរពាមេស្ត្រ អ្នកទ១ញីក្អែកក្រែងមើលមិនច្បាស់ អ្នកបើកសំបុត្រយ៉ាងរហ័ស សេចក្តីក្នុងសំបុត្រនោះថា "ពាមេស្ត្រមានការចង់ជួបនឹងអ្នកគេនៅចាំអ្នក នៅហាងលក់ឥ៉ាន់ នៅ ២ ១ សាយ ១ ។

ជោជន្ត្រាស្ទុះក្រោកឡើងភ្លាម! កាលពីមុន អ្នកមានរឿងជាមួយនឹងពាមេស្ត្រមែន ប៉ុន្តែឥឡូវនេះអ្នកមកនៅតែឯង ២ ១ ដូចជានៅកណ្តាល

សម្រេចខ្ជាប់ រកញាតិមិត្តណាមួយគ្មានសោះ លុះឮថាមិត្តចាស់ម្នាក់មករក អ្នកសប្បាយចិត្តក្រៃលែង មិនគ្រាន់តែសប្បាយនឹងឃើញមិត្តនោះទេអ្នកចង់ដឹងឲ្យច្បាស់អំពីហេតុ ដែលធ្វើឲ្យខកការជាមួយនឹងនាងហិម-ណាលិនី ម្យ៉ាងទៀត នាងហិមណាលិនីក៏ឥតនៅទីនេះផង គ្រាន់តែជួបគ្នាមានទៅចាស់ការអ្វី . . . . ។

ជោជេន្ទ្រាដើរតាមអ្នកយកសំបុត្រមក អ្នកក្រឡេកឃើញកមេស្ហអង្គុយលើឡាំងមួយ នៅមុខគៀមលក់ឥវ៉ាន់ អ្នកស្ទុះទៅទាញដៃកមេស្ហ ។

–យីអញរកគិតអ្វីមិនយល់ទាល់តែសោះ តែម្តង ចុះឯងធ្វើមុខអីចឹងវុំ-ម្តេចឯងមិនទៅផ្ទះគាតែម្តងទៅ បានជាមកអង្គុយចាំនៅឯនេះទៅវិញ ឈ្ងុយអង្ករលីងជាប់ច្រមុះប្អើ អា ?

កាមេស្ហមិនទឹកស្មានថា ជោជេន្ទ្រាទទាក់ទទួលអ្នកបានស្រួលយប៉ុណ្ណេះទេ អ្នកសប្បាយចិត្តណាស់នឹងឃើញមិត្តអ្នកមិនគំគួននឹងអ្នក អ្នកក្រោកដើរតាមមិត្តទៅទាំងញញឹម ។

ជោជេន្ទ្រាតែនិយាយម្នាក់ឯងមិនឈប់សោះ ?

– ឯងអើយ គួរឲ្យអស្ចារ្យមែន តែព្រះលោកតារទុកមកហើយកុំឯងចេះប៉ុន្មានប៉ោតក៏ដោយ ក៏នៅតែតាយខុសដែរ ។ ឯងឃើញទេដូចបងខ្ញុំ ខ្ញុំកើតនៅទីក្រុង ធ្លាប់រស់នៅតែទីក្រុង ឥឡូវនេះត្រូវគេត្រាត់មកឲ្យនៅស្រុកស្រែវិញខ្ញុំចង់ទ្រហោយំហើយ អ្នកណាចេះនៅ ?

- ក្នុងនេះដូចជាគួរសមដែរតើ (ពេមស្ហូធ្វើយបណ្ដើរ ដាកមើលផ្ទុំវិញខ្លួនគេបណ្ដើរ) ។

- ឯងថាគ្រាន់បើ ព្រោះឯងចូលចិត្តស្ងាត់ ចូលចិត្តនៅតែឯង គ្មានចង់ស្ងាត់ជាងឯងទៅទៀត ប៉ុន្តែ . . . ។

- ស្ងាត់ដើម្បីឲ្យវាស្រាលខ្លួកក្បាលបន្ដិចទៅ . . . . ។

- កុំចង់ស្ងាត់ខ្លួកក្បាលធ្វើអ្វី ស្ងាត់ណាស់ពេកទៅ គ្មានចង់ថប់ស្ងាប់ទៅហើយ ។ ឥឡូវនេះ កំពុងតែមានរឿងជាមួយនឹងលោកធ-ការគណ:កម្មការសិក្សាផង អញបានបង្ហាញវាឲ្យដឹងចិត្តអញខ្លះហើយ វាបែបមិនសូវហ៊ានប្រកួតនឹងអញទៀតទេ ព្រោះអញបានប្រាប់វាថា តែធ្វើផ្ដេសផ្ដាស់ អញផ្សាយការសែតម្ពង ឲ្យដឹងដែ អញប្រាប់វាទៀតថា អញមិនមែនជាកូនក្រាលបង្គោលស្ទឹងអ្នកណាទេវ៉ុយ បើអញនៅកន្លែងនេះបានគឺដោយសារតែតម្លៃការងារដែលអញធ្វើទេ មិនមែនមកពីអញពួកបក្ខអ្នកណាទេ មានបុគ្គលិកជាច្រើននិយាយសរសើរពីអញ បើពុំនោះម្ល៉ះមិនដឹងជាគណ:កម្មការនោះ វាធ្វើទុក្ខអញយ៉ាងម្ដេចទៅហើយទេ ប៉ុន្តែគាត់ឯងដឹងទេ វាមិនហ៊ានធ្វើអ្វីអញមែន ប៉ុន្តែវាមិនមែនចូលចិត្តនឹងអញទេណា ម្ល៉ះហើយបានជាអញគ្មានត្រូវការនិយាយលេងជាមួយនឹងអ្នកណាក្រៅអំពីគាពុង ក្នុងអញនេះទេ ។

មកដល់ផ្ទះដោយជ្រាន ពេមស្ហូទម្លាក់អង្គុយប្រូស ។

នៃអង្គុយឥតក្លាម អញមិនទាន់ក្ងុបទេ ឯងចូលចិត្តងូតទឹកពេលព្រលឹម អញទៅដាក់ទឹកឲ្យក្តៅឲ្យ ថ្ងៃនេះគាត់ឯងមកលេងទឹងអញ យើងស្រស់ស្រួបម្តងទៀតទាំងអស់គ្នា ។

· មិត្តទាំងពីរនេះតែមានការជជែកគ្នាមួយថ្ងៃទាល់ល្ងាច កាមេស្ហច្ងៀតឱកាសនឹងបញ្ចេញគោលបំណង ដែលនាំខ្លួនឲ្យមកបីសាយបុរី សឹងតែមិនបាន លុះបាយល្ងាចរួចហើយ អ្នកទាំងពីរអូសកៅអីផ្អែកមួយម្នាក់មកអង្គុយក្បែរបង្កៀង ទើបកាមេស្ហបានឱកាសនឹងក៏យករឿងរ៉ាវទាំងប៉ុន្មានរបស់ខ្លួនប្រាប់មិត្ត ឲ្យបានធូរស្រាលអស់អំពីដួងចិត្ត ។

នៅជងផ្លូវខាងក្រៅផ្ទះ គ្មានឮសូរមាត់មនុស្សម្នាដើរទេ ងងឹតសែនងងឹត គេឮសូរតែសម្លេងចង្រិតយំច្រែក ៗ លាយនឹងសម្លេងសត្វស្វាន ផ្កៃព្រៃ ព្រួសលួតឲ្យខ្លាច ។

– ជោដ្ត្រាឯងប្រហែលជាទាយត្រូវ ថាហេតុអ្វីបានជាយើងមករកគាត់ឯងក្នុងពេលនេះ ឯងចាំទេ ថ្ងៃមួយគាត់ឯងបានសួរយើងមួយម៉ាត់ ហើយយើងឆ្លើយនឹងសំនួរគាត់ឯងមិនកើត ឥឡូវនេះយើងអាចឆ្លើយនឹងសំនួរនោះបានហើយ ។

ថាហើយ កាមេស្ហក៏ចាប់និយាយរឿងនាងកាមាណា លុះចប់សព្វគ្រប់ហើយ ទើបជោដ្ត្រាឆ្លើយ :

- ត្រូវមែនហើយ តែបើឯងនិយាយរឿងដដែលនឹងប្រាប់យើង ពីកាលនោះ យើងក៏ឥតជឿតាត់ឯងដែរ ។

- ទោះជាយើងនិយាយឥឡូវនេះ ក៏ឥង់ឯងពិបាកជឿដែរ តែយើងមកនេះ ដោយយើងចង់នាំឯងទៅកូមិដែលយើងបានរៀបការ នឹងទៅជួបនឹងមាវរបស់នាងកាមាលាផង ។

-ទេ យើងឥទៅទេតាត់ យើងជឿតាត់ឯងហើយ ចាំឲ្យយើងទៅបានប្រយោជន៍អ្វី ឯងដឹងស្រាប់ហើយថា តាំងតែពីដើមរៀងមក យើងតែងតែជឿពាក្យឯង ទើបតែម្តងនេះទេ ដែលយើងសង្ស័យឯងកុំខឹងនឹងគ្នាអីវ៉ុ ។

មិត្តទាំងពីរស្ទុះក្រោកឡើងឧបរឹតគ្នាយ៉ាងស្ទិទជួចកាលដើម ការសង្ការបន្ទិចបន្ទួចក៏រលាយអស់រលីង មួយសន្ទុះទើបរាមេស្ហរកដង្ហើមរួចហើយចាប់និយាយមុន ។

-ព្រហ្មលិខិតបានចាប់យើងច្រកកន្ទុងសំណាញ់មួយ យ៉ាងសាន់វ៉ុណ្ណអស្ចារ្យ ម្ទ៉ោះហើយអ្នកណាដៅក្បែរយើងទាំងប៉ុន្មាន យើងអូសទាញគេឲ្យចូលជាមួយយើងផងទាំងអស់ ។ ឥឡូវនេះ ដោយគ្នាគ្មានការអ្វីលាក់លៀបនិងឯងទៀតទេ គ្នាជកដង្ហើមបានធូរស្រួលហើយ ។ ប៉ុន្តែមកទល់និងថ្ងៃនេះ ហើយគ្នានៅតែមិនយល់ថា ហេតុអ្វីបានជានាងកាមាលា សុខចិត្តសម្ងាប់ខ្ជូន ប៉ុន្តែមានមធ្យោបាយណាក្រៅអំពីអត្តឃាត

នេះ ឯងដឹងទេ បើប្រសិនជានាងមិនធ្វើអត្តឃាតទេ គ្នាក៏មិនដឹងជាពិចារណយ៉ាងណាៗ ប្រពន្ធមិនប្រពន្ធ ប្តីមិនប្តីទៅណាក៏មិនរួច មកណាក៏មិនរួច បើប្រសិនជានាងមិនចាន់ធ្វើឲ្យចប់ទេមិនដឹងជាគ្នាត្រូវប្រកាច់ប្តីនានត្រឡប់ទៀតទេរឺអើយ តែបើកក្នុងកន្ទ្រឹងកាលណា ដូចមានកំមួយសង្ក្តត់ចេះដូងកាលថ្ងៃ ។

-អញមិនចាន់ជឿថានាងនោះសម្ងាប់ខ្លួនទេ (ដោយជន្ត្រានិយាយ) ប៉ុន្តែនៅមានរឿងមួយទៀត ដែលយើងត្រូវលើកមកចកស្រាយចាំងអស់គ្នា គឺរឿងណាលីណាក់ស្ហ ។ អាមនុស្សវៃចន្ទ ! អញមិនយល់សោះ ឯងដឹងស្រាប់ហើយថា ការអ្វីក៏ដោយ តែអញមិនយល់ មិនស្គាល់ច្បាស់ អញតត្រូវការយកខ្លួនបៀតទេ ផ្ទុយទៅវិញ មានមនុស្សច្រើនណាស់ ដែលចូលចិត្តអ្ន ? ដែលមានអាថកំចាំង មានប្ជុនអញនេះជាដើម ហេតុនេះហើយ ចាន់ជាអញចារម្ភ ។ គាត់ឯងដឹងទេ ឥឡូវនេះ ហ៊ាមឈប់ញ៉ាំសាច់ហើយ ត្រាន់តែទឹកកំ៉ាគ្ងមដែរ មានអ្ហីល្អកើត មនុស្សដែលធ្លាប់តែញ៉ាញ៉ីមញ៉ាញ៉ាមស្រស់ស្រាយ តែវ៉ាក្ខកថ្ងាយ ! ឥឡូវឡើងមុខស្ងាំ ក្ខកសត្រាតដូចត្រីឈ្ងក់ទឹក ។ គេសើចរក មិនចង់ចាំងញ៉ាញ៉ីមរកគេវិញផង ! ខ្ញ- បើគាត់ឯងសុខចិត្តជួយអញ ប្រហែលជាអញអាចចាញ់ឲ្យផុតពីការយល់ខុសនោះបាន ។ ម៉ូចសុខចិត្តទេ ? បើត្រមមួរដើងទេ មួរដៃអាវមក យើងទៅលេងអាតាប៉ុក

ណាលីណាក់ស្ហាម្ពង់យកដោតជ័យ ប៉ុន្តែទៅឥឡូវមិនទាន់បានទេ ចាំ ដល់ឈប់បុណ្យ" ណូ-ឯល " សិន ។

-ចាំធ្វើអីឲ្យទាតពេល ឲ្យគ្នាទៅតែម្នាក់ឯង មិនបានប្ត ?

-ឯងទៅតែឯងមិនបានទេ-អញទេតើ ដែលជាអ្នកបណ្ណាច់បំណង ឯង ទាល់តែអញទៅចងវិញទើបត្រូវ គាត់ឯងនៅជាមួយនឹងអញ សិនទៅ រាថ្ថី...? អញមានរឿងនឹងគេ ចង់ជុំវិញខ្ជូនទៅហើយ បើ ឯងមិននៅជាមួយអញទេឲ្យអញធ្វើដូចម្តេច ។ យប់ៗឡើង ដេកតែ ស្តាប់សម្ងេងត្រែវ្រៃលូវ រកអ្នកណានិយាយឲ្យស្តាប់គ្នានសោះ ដល់បាន សម្ងេងឯងបកពីះរាះដូចបានស្តាប់គេច្រៀង អីចឹង រ៉ី.... ។

(នៅមានត)

ផ្នែកមទំនៀមទម្លាប់ខ្មែរ

សត្វចិញ្ចឹម

- ថ្នាំការពារជម្ងឺគោ
- របៀបរើសពូជគោ
- របៀបរើសក្រយៅគោ
- របៀបបង្ហាត់សត្វផ្តៃ
- ថ្នាំសម្រាប់ការពារផ្តៃទាំ-ឃ្មុំទិច-ថ្ងៃនទាំ-ពស់ចឹក

រៀបរៀងដោយ :

លោក ស៊ូ-សែម

នាយតម្រូតរងថ្នាក់ទី ១ នៅបញ្ជាការ

ផ្នែក ក.រ.ត. ស្រុកត្រាំកក់

ខេត្តតាកែវ

អំពីសត្វដែលគេចិញ្ចឹមក្នុងប្រទេសកម្ពុជា

- គេចិញ្ចឹមទា - មាន់ យកស៊ុតនិងសាច់បរិភោគ
- - ជ្រូក - គោ យកសាច់ជាអាហារ
- - ក្រប៉ី - គោ សម្រាប់ទឹមប្រើនិងយកសាច់ជាអាហារ
- - សេះ សម្រាប់ជិះនិងទឹមរទេះ
- - គោ យកស្បែកជាសស្ពរនិងរឹតយកទឹកដោះ

— គេចិញ្ចឹមឆ្កែ ទុកឲ្យចាំផ្ទះ ឆ្កែខ្មៅយកឆ្អឹងធ្វើថ្នាំ យកប្រាក់ នោមនិងលិង្គការពារគេបង្កប់ យកឈាមផឹកឈាប់កញ្ច្រៀល ។ ចាន់ក្រញាសសម្លាប់ស្វាយកទឹកផឹកការពារពុល ។

— សត្វព្រៃ កុក ក្រសា ទុង យកស្លាបវាធ្វើផ្លិត ។

មាន់មានស្រែកាដើងល្អ គេចិញ្ចឹមទុកប្រជល់ភ្នាល់ ដាក់លុយកាត់ ។

អំពីរបៀបរើសពូជ

- គោគេច្រើនរកពូជ កូនកាត់គោពីអុីតាលី មាឌវាច្រើនធំហើយ ស្លូត ខ្លាំងស្រួលទឹមប្រើ ពុំសូវរើសស្មៅ គោពូជកូនកាត់នេះ នៅស្រុកត្រាំកក់ គេចិញ្ចឹមច្រើននៅភូមិត្រាំកក់-គុស-ញ៉ែងញ៉ង ខាងជើងផ្សារអង្គតាសោម ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ សព្វថ្ងៃ បើត្រូវការទិញពូជក៏បាន តែថ្លៃណាស់ ១ ក្បាល ថ្លៃ ៥ ០០:០០០ ។

របៀបថែទាំវាឱ្យឆាប់ធំធាត់ ត្រូវលាងទឹកវាព្រឹកល្ងាច ចងវា តែព្រឹកនិងល្ងាច ពេលថ្ងៃក្តៅ ចងក្នុងម្លប់ឲ្យវាស៊ីស្មៅកាត់ទុកឲ្យយូរៗ ត្រាំស្រូវលាយនឹងដើមចេកហាន់ឲ្យហ្មត់ បុកលាយកន្ទក់ដាក់ឲ្យស៊ី ឆាប់ធាត់ហើយចាំសាច់ ដាក់ចំបើងឲ្យវាស៊ីយប់ៗ ម្យ៉ាងទៀតច្របាច់ទឹកផ្លែត្នោតទុំលាយនឹងទឹកយើងធម្មតាឲ្យវាផឹក ខ្លះគេឲ្យផឹកទឹកអង្ករដំណើបខ្មៅ និងកាកល័ក្តដើម្បីឲ្យវាស្រួលក្នុងខ្លួន ឬច្រកបណ្តូលពោតដើម្បីឲ្យវាល្មោភ

ស៊ីស្ម៉ា ធាប់ធំធាត់ ។ ប្រយ័ត្នកុំឲ្យវាចុះផឹកទឹកត្រពាំង ឬអណ្តូងណា ដែលមានជាតិជ័ម្ភមានខ្សាច់សោក យូរៗទៅនាំឲ្យវាកើតឫសដូងប្រមុះ ។

របៀបធ្វើប្រាំការពាររោគផ្សេង ។

១- យកកន្ទបជ្រលក់ប្រេងដូងជូតខ្សែវា ពល់ព្រឹក ដើម្បីឲ្យសម្បូរវាខ្ទីរលោង ម្យ៉ាងទៀតមិនអន់សម្បូរទេ ។

២- បើអង្ករ៉ូ កើតវៃច្រើន ទៅកន្ទុយទៅត្រង់ចន្ទោះក្ងៅ មានកូនតុកកែតូច ១ បុកស្ងឹកខៀបចាក់ជាលាបជូតសព្វខ្លួនឲ្យវាពល់ព្រឹក នឹងជាអស់ហើយ ទើបលាបប្រេងដូងពល់ព្រឹក ឲ្យបានសម្បូរតទៅ ។

៣- បើគោកើតជំងឺ ឲ្យយកកំបោរ ស្ករត្នោត ថ្នាំខ្ចាំង បុកលាយគ្នា លាបឲ្យវា បើមានដង្កូវ ឲ្យប្រចាប់ទឹកនោះចូលក្នុងរន្ធជំងឺ នឹងជ្រុះដង្កូវអស់ សះជាហើយ ។

៤- បើគោកើតជ្ងឺ ហ៊ីមពោះ សាចាប់ ឈ្ងាសកុក ដែកពពុះ ម្ទាត់ ក្តៅខ្លួន ឈ្ងាដង្ហក់ ឲ្យយកប្រហុកត្រីកំភ្លាញ ៧ ត្រួយដំឡូងជ្ងា ៧ ត្រួយត្រឡាច ៧ ឬពោះត្រឡាចកំបាន បុកលាយគ្នា លាយទឹកឲ្យល្ម ហើយប្រកព្រឹកល្ងាច បើធ្ងន់ឲ្យប្រក ២ ដង ក្នុង ១ ថ្ងៃ ជាហើយ ចៀវហ៊ីមពោះ ចេះតែទៅផឹកទឹក ត្រូវយកថ្ម ១ ការបូណាតដ៏ស្ងួត លាយនឹងទឹកផ្ងិន ទុកឲ្យត្រជាក់ជាក់ផើងឲ្យផឹក ធាប់ស្រកពោះ ។ ថ្នាំនេះ

ដ៏ធ៍ពីលោកគ្រូ ច្រាត់-ណែ ផ្ទះនៅភូមិពោធ៍ព្រះសង្ឆសង្កាត់តាកេម ស្រុកត្រាំកក់ ខេត្តតាកែវ គាត់មើលជាច្រើនណាស់ ជម្ងឺគេតែយកគាត់ ១-ន ពុំដែលជាប់មួយក្បាលទេ ។

របៀបវើសក្រយៅគោចិញ្ចឹមសុខ ឬមិនបានបម្រើន

ក- ក្រយៅក្រឡាប់ មានក្រយៅមួយនៅលើស្នាមុខ តែដើរទៅ ក្រឡាប់ចុះ-ឡើង ចាស់ថាចង្រៃណាស់ ហ៊ានហោចទ្រព្យសម្បត្តិ ពុំ នោះទេ ស្លាប់ម្ចាស់អ្នកចិញ្ចឹម ។

១- ព្រះពាយជ្ជាត់ សភេមចុងគប់ក្ដួយ ចាស់ ១ ចំណាំថា ចិញ្ចឹម គោរបៀបនេះផ្ទាត់ចង់លាកសក្ការ: រកទ្រព្យចូលមិនបានតាល់តែសោះ ។ (ចានដ៏ធ៍រឿងនេះពីឈ្មោះ ង៉ែ«ត ប្រពន្ធឈ្មោះនាង ធឿ«ន នៅភូមិត្រៃ ត្រេច សង្ឆាត់តាកេម ស្រុកត្រាំកក់ គាត់ជាអ្នកប្រសព្ធចិញ្ចឹមគោ) ។

អំពីវើសកេទ៍ក្នុងដើម្បីចិញ្ចឹមគោ បើចង់ចិញ្ចឹមគោច្រើន លុះគ្រា តែទៅនៅកន្សែរដើងកុ ទើបមានដ៏ចូលាយ សម្ផ្ជាណ៍ តិណជាតិ ។ នៅ ស្រុកត្រាំកក់ ចិញ្ចឹមពុំបានច្រើនក្បាលទេ ព្រោះទ៍ចង្ហ្ន«ត ។ ទ៍ក្នុង ចង់ទ៍ធ៍ថ្ងៃ ត្រូវធ្វើកេងនិងចុះយ«ង មួយដោយឡែក នៅកន្សែរផ្ទះ ។ ត្រូវធ្វើធុងជាក់ស្ដៅ ១ ១ មួយ នៅចំកណ្ដាល ក្នុងធុងមួយ សម្រាប់គោ មួយទ៍ម នៅក្នុងកេង ត្រូវចាក់ដ៏ដ៏ចូក ហើយបង្ហ«ប់ឲ្យហាប់ ១ សប្ដាហ៍ សម្ងាត លើកអាចម៍គោយកទៅចាក់ឯកន្ទ«ងកេងដ ១ ដោយឡែក ។

របៀបទិញសត្វយកមកបិញ្ចឹម:

ក ក្របី ពុំសូវរើសទេ គេរើសកុំឲ្យតែស្នែងតាក គេពុំសូវយកឲ្យយកស្នែងឲ្យកុងឡើងលើទើបល្អ រើសមាឌធំ ជើងថ្លោសមកបិញ្ចឹម ទើបពូកែធ្វើការ ។

ខ– គោ ត្រូវកុំចិញ្ចឹមគោក្រយៅក្រឡាប់ ព្រោះពាយផាត់ សបុងគប់កន្ទុយ ប្រឡោះជើងហាធំពេក ដើរទ្រាំខ្សាប់ពុំបាន គោពពាលកន្ទុយវែក ពងតែ ១ ខ្នួនសំឪបសំឪប មាឌកងទាប គ្មានសំបុកពោះធ្មេញប្រឡោះខ្មោច តាប់ស្មៅពុំដាច់ កើតឫសដូង ដកស្រមុកយប់ប្រគីវជើង មាត់ទ្រង់ស្រួច ។ គេចិញ្ចឹមតែគោណាមានជើងថ្លោសក្បាលទ្រង់ឆើប ខ្នងទ្រវែងដូចគ្រាប់គ្រសក់ បើខ្នងខ្ពី ឲ្យសំបុកពោះធំ វង្វះមាត់ធំ ល្មោកស្មៅ សព្វថ្ងៃគេច្រើនចិញ្ចឹមគោកាត់ ។

គ– ឆ្កែ គេច្រើនយកពូជឆ្កែបែរហៀវធំៗ តែអ្នកក្រចិញ្ចឹមពុំបានព្រោះវាស៊ីតែសាច់ ស្រុកស្រែឬនៅជិតដើងភ្នំ រើសតែឆ្កែណាដែលឧស្សាហ៍ព្រុស ពោះមនុស្សចម្លែកដើរចូលក្នុងរបងផ្ទះ ដើម្បីការពារទ្រព្យរបស់ និងគោជ្រូក មាន់ទា នៅពេលយប់ ។ អ្នកបរបាញ់សត្វគេរើសឆ្កែអណ្តាតពាំព្រីង គឺឆ្កែដែលមានអណ្តាតខ្មៅ គេហៅថាស្ទាក់ពោះសត្វធ្លាក់ដី ។

ឃ– ឆ្មា គេរើសយកឆ្មាសម្បុរ ៣ "ឆ្មាដែលមានរោមវាមួយ

សរសៃ សម្បុរមានពណ៌ បែបគីឡៅ លឿនជាំ ហើយនិងស" ជាសំគាល់ចំណាំថា ចិញ្ចឹមវាចូលទ្រព្យសម្បត្តិ (បានឮពីឈ្មោះ អែល នៅភូមិអាចម៍កុក សង្កាត់ពពេល និយាយពន្យល់ប្រាប់) ៕

អំពីរបៀបបង្ហាត់សត្វគោ

សត្វគោ គេបង្ហាត់តាំងពីតូច ឲ្យរៀនពាំកូនទ្វើយតូច គេបោះឲ្យវាពាំនាំយកមកឲ្យយើង រួចគេនាំឲ្យចូលព្រៃ បង្ហាត់ឲ្យចេះដេញសត្វជំបូងគេបោលជុំជីកនព្រៃ ឲ្យគោព្រុសកោះ តែនៅភូមិត្រពាំងបីជិតជើងភ្នំគេថាគោមិនទាន់គ្រប់អាយុ គឺមិនមានអាយុគ្រប់មួយខួប គេមិនយកទៅឲ្យដេញសត្វទេ ខ្លាចវាអាយុខ្លី នេះជាទម្លាប់ស្រុកភ្នំ ភូមិត្រពាំងបី ស្រុកឈូក (កំពត) ៕ លុះបង្ហាត់ឲ្យស្ទាត់ខាងប្រដេញហើយ បើចង់ឲ្យវាចេះឃ្វាលគោទៀតនោះ ត្រង់នេះពិបាកណាស់ ខ្លះបង្ហាត់មិនបានទាល់តែសោះក៏មានដែរ ៕ ជំបូងគេដាក់ប្រវាក់វា ឲ្យដេកជាមួយគោរាល់យប់ ជាយូរថ្ងៃ លុះតែវាធ្លាប់ចំណាំកន្លែង ទោះបីលែងដាក់ប្រវាក់ ក៏គង់វាមកដេកជាមួយគោដដែល ក្រោយមក គេដាក់ប្រវាក់វានៅពេលថ្ងៃក្តៅ គេបង្ហាត់វាឲ្យចេះស្រឡាញ់គោ បង្រៀនឲ្យវាប្រឡែងនឹងកូនគោ នៅពេលគោដេក ដាក់បាយឲ្យស៊ីក្នុងទ្រុងគោរាល់ពេល ធ្វើដូច្នេះយូរថ្ងៃទៅ គោនិងគោ វាប្រឡែងគ្នា វាចេះស្រឡាញ់គ្នា ទោះបីលែងដាក់ប្រវាក់ក៏គោនៅតែដើរតាមសត្វគោ ដែលវាស្គាល់ថាជាគោម្ចាស់

ក្នុងដែល បន្ទាប់មក គេលែងគោទៅ គេលែងផ្តែទៅជាមួយផង លុះគោដើរទៅស៊ីធ្លាយ គេហៅផ្តែឲ្យដើរទៅជាមួយ រួចគេដេញគោចាំងអស់ ឲ្យត្រឡប់ក្សាល ដើរស៊ីស្មៅត្រង់មកខ្លួនគេវិញ ធ្វើយ៉ាងនេះជាច្រើនលើកច្រើនសា ក្រោយទៀតគេឃើញទៅធ្លាយ គេហៅផ្តែ រួចគេវត់សំដៅទៅកគោ ឲ្យផ្តែវត់ទៅតាម រួចគេស្លាកមុខគោទៀត ផ្តែខ្លះគេគ្រាន់តែបង្ហាត់ពីរបីដង ក្នុងដំណ ម្ចាស់ក្រាប ប្រើឲ្យទៅកៀងគោម្នាក់ក្នុងបានដូចបំណង ។ នៅខាងសង្កាត់ត្រពាំងកាង ស្រុកឈូក "កំពត" ឃើញគេបង្ហាត់ផ្តែរបៀបខាងលើនេះ តែពេលនោះខ្ញុំពុំបានសួរឈ្មោះអ្នកដែលធ្លាប់បង្ហាត់នោះទេ ។

អំពីជំនឿផ្សេង ៗ ទាក់ទងជាមួយសត្វបិញ្ចឹមនិងសត្វព្រៃ

សត្វជ្រូកជើង ៣ គេមិនឲ្យចិញ្ចឹមទេ ចាស់ ១ ចំណាំថាចង្រៃ គេច្រើនយកទៅប្រាសចេលនៅក្រោមសាលាលោក ឲ្យវាស់នៅជាយសាបាយវត្ត ឃើញនៅខាងព្រៃកតាឃ្លាក សង្កាត់ត្រើយស្វាយ ស្រុកស្អាង "កណ្តាល" ។ ជ្រូកមានជើង ៤ តែវាសក្រចកជើង ១ ឬសពេមជើង ១ ហៅជ្រូកជើង ៣ (ចានត្នតម្ងូត ស្វាយ-សៃ នៅព្រៃកតាឃ្លាក ប្រាប់ពីឆ្នាំ ១៩៦០) ។ ឆ្នាំនេះលួច ក៏គេយកទៅប្រាសចេលជាវត្តដែរ ។

អំពីជំនឿចំពោះសត្វព្រៃ គេចិញ្ចឹមស្វាព្រៃ ចង់នៅជិតទ្រូងជ្រូក កុំឲ្យជ្រូកមានជម្ងឺ ចិញ្ចឹមសេះ គោ សាមិនចាប់ វាឈ្នះជម្ងឺដោយចិញ្ចឹមស្វាព្រៃនេះ ។

សត្វដែលខ្មែរយើងយកមកប្រើជាមង្គល :

-គោធំៗសន្ធតថា គោឧសភរាជ គេនាំយកមកជាមង្គល នៅពេលធ្វើពិធីច្រត់ព្រះនង្គ័ល ដូចជាក្នុងឆ្នាំ ១៩៦៩ នេះ ធ្វើនៅខេត្តតាកែវ ។

-ក្របីឡើង-ក គេយកធ្វើជាមង្គលក្នុងពិធីឡើងអ្នកតា ១ នៅភាគភូមិកំពស់ សង្កាត់ទឹកវិល ស្រុកស្អាង (កណ្តាល) ពីឆ្នាំ១៩៦០ ។

ឆ្នាសម្ស៊ូ ៣ គេសែងជាក់ក្នុងទ្រូង ហើយលេងក្ងេងត្រុដ សែងដង្ហែតាមភូមិ ឲ្យអ្នកស្រុកស្រោចទឹក ហើយសុំទឹកក្ងៀងក្នុងផ្ទះ ដូរកំងក្ងៀង ដោយគេយល់ថា ជាពិធី ជួងសួងសុំទឹកភ្លៀង ។ ឃើញនៅភាគភូមិក្តាំងដារ សង្កាត់ក្ពង់ហ្លួង ស្រុកសង្កែ (ចាត់ដំបង) ពីឆ្នាំ ១៩៤៧ ។

សត្វជាឧត្ត្យាទ ចាស់ៗនិយាយថាមាន :

ខ្ទង់ស្រាក់ លលកខ្ចោច ឥឡូ គោ គេច្រើននិយាយថាជាសត្វបម្រើខ្ចោច តែពួកយំ នៅកន្ទ្ធងណាជិតភូមិ ជិតផ្ទះគេ១ យកគប់ក្ងើងចាល ខ្ទះស្រែកដេរបញ្ជោរច្រាសនេះ បណ្តេញចេញ គេថាកុំឲ្យមានឧត្ត្យាទចង្រៃចូលមកយាយីក្នុងភូមិគេ ។ ម្យ៉ាងទៀតនៅកន្ទ្ធង

ខ្វះ សត្វមៀមយំនៅពេលយប់ ក៏គេថាជាសត្វឧត្បាទ បម្រើខ្មោចដែរ ព្រោះមៀមហ៊ានចេញរកស៊ីតែពេលយប់ ។

ដោយមានរឿងព្រេងនិទានថា:

កាលពីព្រេងនាយ កន្លងយូរយារណាស់មកហើយ ព្រះឥសូរ ក្រោយអំពីបានផប់សត្វទាំងអស់ឲ្យមានរូបរាងប្លែកគ្នា ហៅប្រមូលសត្វទាំងអស់ ទៅប្រជុំ ហើយសួរសត្វទាំងនោះថា ខ្ញុំផប់រូបឲ្យអ្នកទាំងអស់គ្នា ពេញចិត្តឬទេ ? សត្វទាំងអស់ឆ្លើយព្រមគ្នាថា ត្រូវចិត្តហើយ ប៉ុន្តែក្អែកឆ្លើយឡើងថា ទូលព្រះបង្គំពេញចិត្តហើយ ចាស់តែរូបសត្វមៀមមួយទេ ព្រះអង្គពុំគួរ ផប់ឲ្យមានក្អែកធំៗ ក្រឡោតក្រឡែតគួរខ្លាចដូច្នេះសោះ សត្វមៀមតបវិញថា ទូលបង្គំយល់ឃើញថាល្អពេញចិត្តហើយ ទូលបង្គំឃើញចាស់រូបក្អែក ខ្មៅកខ្វក់ជាងសត្វឯទៀត គួរឲ្យខ្ពើម ក្អែកឮដូច្នោះខឹងខ្លួនឡើង ដេញចឹកមៀមខ្លាច មៀមរត់គេចខ្លួនមិនហ៊ានរកស៊ីពេលថ្ងៃ រហូតដល់សព្វថ្ងៃនេះ (ដកស្រង់ពីកម្ពុជសុរិយា និពន្ធលោកអាចារ្យ តែម នៅភូមិព្រះពោធិព្រះសង្ឃ សង្កាត់តាគេម ស្រុកត្រាំកក់ ខេត្តតាកែវ និទានប្រាប់) ។ ពួកចាស់ៗហាមមិនឲ្យជិះដំរីមួយ ពីរនាក់ប្តីប្រពន្ធ គេថាវាព្រាត់ប្រាសគ្នា ពួកតែនិយាយតៗមកពិតដូច្នេះ នៅខាងស្រុកត្រាំកក់ ពុំដែលឃើញមានគេហ៊ានជិះមែន តែសួរដល់ចាស់ៗថា នាំគ្នាខ្លាចតៗគ្នាមក ពុំដែលឃើញ

មានក្បួនតម្រាអ្វីហាមឲ្យប្រាកដទេ ។

ថាបើស្រីណាផិតប្តី ជិះដំរីៗ នោះរលាស់ចោល មិនឲ្យជិះទេ ត្រង់នេះបានឮឈ្មោះ អ៊ុវ-ជួង នៅសង្កាត់ញ៉ែងញ៉ង ប្រាប់ ថាខ្លួនគាត់នៅពីតូចបានទៅជាមួយហ្មដំរីទៅទាក់ដំរី បានឮហ្មគេប្រាប់ ថាមិនចំពោះគ្រប់តែស្ត្រីផិតប្តីទេ ចំពោះតែប្រពន្ធហ្មទាក់ប៉ុណ្ណោះ ហ្មដែលធ្វើចេញទៅទាក់ គេឲ្យប្រពន្ធកាន់ត្រណម បើនៅឯផ្ទះ ក្បត់ចិត្តប្តី លុះដល់ប្តីត្រឡប់វិលមកវិញ ហើយប្រពន្ធនោះមកឡើងមកជិះលើខ្នងដំរី ៗ មុខជាទឹងទឹង ហើយរលាស់ទម្លាក់ចោលក្លាមពិតប្រាកដណាស់ លាក់មិនជិតទេ ។

ពស់ជា គេថាប្តីប្រពន្ធឬពីរនាក់បងប្អូនឃើញហើយ មើលជាមួយគ្នាមិនបានទេ ព្រាត់ប្រាស ត្រង់នេះសួរចាស់ៗ ទៅថា គេទម្លាប់ជឿដូច្នេះមែន តែឲ្យមានក៏ស្គាល់ថា ឈ្មោះណាម្នាក់ នៅភូមិស្រុកណា មានគេព្រាត់ប្រាសទៅហើយ ក៏ពុំប្រាកដ តែឮឈ្មោះ ប៉ាំង-ញ៉ែ នៅសង្កាត់តាភេម ស្រុកត្រាំកក់ ប្រាប់ថា ចាស់ពីដើមជំនាន់ឪពុកគាត់ ឃើញពស់ជាពីរនាក់បងប្អូនគាត់ ឪពុកគាត់យកគាត់ទៅលក់ឲ្យបងគាត់ម្នាក់ នៅផ្ទះខាងលិច យកប្អូនគាត់ឲ្យទៅលក់ផ្ទះគេខាងកើត កន្លងទៅបាន ១ យប់ ១ ថ្ងៃ ទើបឪពុកគាត់យកអង្ករ ១ ចាន ទៅលោះមកវិញ ពីរនាក់អស់អង្ករ ២ ចាន ដើម្បីឧបកិច្ចការពារមិនឲ្យព្រាត់ប្រាសគ្នា តមក

ឥតមានត្រាត់ត្រាសគ្នាមែន ។

អ្នកស្រុកថា ដំរីមួយបុស គឺដំរី ៨ ។

អំពីការបិញ្ចឹមមាន់ :

សត្វមាន់រាងងមិនសូវទ្រៀងទេ ខ្ទះពង់ចាន១០ ខ្ទះលើស ពី ១០ ដល់ ១៣.១៤-១៥ ក៏សឹងមាន បើវាចានប៉ុន្មាន គឺចំនួនថ្ងៃ ប៉ុណ្ណោះ ឧបមាថា ពង ១៥ ចំនួន ១៥ថ្ងៃ រាលាប ខ្ទួនវាត្រូវក្រាបតាម ការពិសោធន៍ភាប់ថ្ងៃចំណាំយើញ ២៣ ថ្ងៃ ត្រូវញាស់អស់ បើមេមាន់ចៃ ឬគេហៅចៃទ្រៀង តែ ២០ ថ្ងៃញាស់ហើយ បើមេមាន់គកពី ២៣ ទៅ ២៥ ថ្ងៃទើបញាស់អស់ ចាប់បណ្តើរកូន ។ មាន់បណ្តើរកូនតែ ១ ខែ ១០ ថ្ងៃ ពង់ទ្រៀតហើយមេមាន់គកពី ១ ខែកន្ទុះ ទៅ ២ ខែ ទើបឈប់បណ្តើរកូន ។

របៀបភ្ញាស់ធ្វើឲ្យពងវាញាស់អស់

ចាប់ពីមាន់ទ្រៀងក្រាប ថ្ងៃដំបូងត្រូវរៀបចំសំបុកឲ្យវា គឺ : ត្រូវយក កញ្ជ្រៅចាស់ឬសម្ពកឡ្ចាំងដែលមានទំហំធំជាងខ្ទួនមាន់បន្តិច ទំហំចំនួន ៣ ត្រឹក ជួនជ្រុង តម្ពស់ ០ម១៦ ឲ្យស្ងួមមាន់ចូលក្រាបបាន ឬក្រាលចំបើង ឬសម្ពកជាវាចាស់ពីក្រោម រួចយកពង់វាទៅដុសនិងគ្រាប់ស្រូវគ្រប់ពង ជ៉ាង់អស់ តែប្រយ័ត្នកុំឲ្យបែកធ្ងុ: រួចយកទៅរៀបឲ្យស្ងើ ទុកឲ្យ មាន ក្រាបខ្ទុសរ្ស ហ៍ឲ្យចំណាមេមាន់ស៊ី ដើម្បីកុំឲ្យវាចុះកស៊ីចោលសំបុកយូ ពេក នាំឲ្យត្រជាក់ពង ប្រយ័ត្នកុំឲ្យត្រូវចំកក្ងៀង តែត្រូវក្ងៀងឥតញាស់

សោះ បើញាស់វិញពិបាកចិញ្ចឹម ច្រើនតែងាប់ ។

– របៀបឱ្យចំណីមាន់ តាមចំណាំនៅស្រុកស្រែ តែឧស្សាហ៍បាចអង្ករឱ្យចំណីមាន់ ឬគ្រាប់ធាយឱ្យញឹកញាប់រាល់ថ្ងៃ យូរៗទៅមាន់ច្រើនកើតជម្ងឺស្លាប់ ។ បើឱ្យស្រូវស៊ីជាចំណីឈ្នះជម្ងឺ (ត្រង់នេះខ្ញុំបានធ្លាប់បានពិសោធន៍ចិញ្ចឹមខ្លួនឯងរួចហើយ) ។

បើឆ្កែខាំ ឮចាស់ៗប្រាប់ថា :

ក)- យកម្ទេសទុំញោចមុខរបួស រួចយកមុខកាំបិតជូតមុខរបួស វាឆាប់សះមិនក្លាយ ។

ខ)- ម្យ៉ាងទៀត ឱ្យយកស្រួយដំឡូងជ្វានិងបាយកក បិទមុខរបួស ឆាប់សះ មិនក្លាយដែរ ។

គ) បើឃ្មុំទិច យកទឹកខ្ទះលាបឆាប់បាត់ឈឺមែន ។

ឃ)- ថ្ងៃខាំ ឱ្យប្រញាប់ផឹកទឹកមុនវាៗពុំស្លូវឈឺ ហើយពុំមានគ្រោះថ្នាក់ដល់ស្លាប់ ។

ង) ពស់ចឹក យកគ្រាប់ក្រូចសើច ៧ ទំពារលេប អាចនឹងទប់ទល់ពិសបានយូរ ដើម្បីទុកពេលរកគ្រូមើលពុំស្លាប់រហ័សពេក បើល្មមៗជានឹងគ្រាប់ក្រូចសើចនេះ ។

ត្រណាម និង ជំនឿផ្សេង ៗ :

– បិញ្ចឹមមេមាន់ពូជមាន់ប្រជល់ គេតមមិនឱ្យយកពងមេដែល

ក្បាលនោះទៅស្មោរទេ ខ្មោចវាក្លាយដល់មិនតូកែ ។

-បិញ្ចឹមមាន់សម្ល គេតមប្រហាមមិនឲ្យយកមាន់ជម្ងឺមកទទួល ពានខ្មោចវាចូល ។

គេបិញ្ចឹមមាន់ញីបេះរងាវ ថាវាចង្រៃផ្ទះសម្បែង ។

-គេបិញ្ចឹមគោ មេពូជល្អ ពេលមេវាពោះធំ គេហាមមិនឲ្យគោឈ្មោលតូចតាច ប្ដុះគោឈ្មោលទៅពានពាក់ ខ្មោចកូនទៅក្នុងពោះមិនល្អ ។ នៅកន្លែងខ្លះ ច្រើនតែនៅឫស្សីមួយគុម្ព ស្រុកឈូក (កំពត) បើគេចិញ្ចឹមគោច្រើនក្បាល គេរៀបពិធីសែនព្រេនដល់ម្រេញគង្វាលមានធ្មើប្រម ទឹកបំពង់ ដាក់បាយសំណុំ ប្របទឹកក្នុងបំពង់កល់ថ្ងៃសីល ដោយគេជឿថា ម្រេញគង្វាលជួយថែរក្សាគោឲ្យគេ ។ (បានព្រុះឈ្មោះ ខៀវ-ចាប នៅឫស្សី១គុម្ព និយាយប្រាប់ ខ្ញុំនូវគាត់នៅជិតដើមក្ដី) ។

សត្វ និងផ្ទះសំបែង :

-ដែលខ្មែរយើងយល់ថា មានប្រយោជន៍ដល់ផ្ទះសម្បែងនោះ

ក)-តក្កែទន្សែបតាយសាក គេយកមកទុកការពារភ្លើងឆេះផ្ទះ ។

ខ)-ក្រពះកាំប្រមា ការពារជម្ងឺចាស់ ។

គ)-ទុទុយ គេចិញ្ចឹមការពារចោរលួច ។

ឃ)-ឆ្កែចិញ្ចឹម ការពារចោរនិងរក្សាទ្រព្យសម្បត្តិ ។

ង)- សត្វក្ងាន គេចិញ្ចឹមការពារចោរលួចដែរ ។

ច)- ចិញ្ចឹមឲ្យចាប់កណ្តុរ មិនឲ្យកាត់របស់ទ្រព្យ

សត្វ និង អាទិទេព :

– មានសត្វរាជហង្ស ដែលខ្មែរយើងយករូបទៅដាក់លើកំពូលដងទង់ នៅតាមផ្លូវ វត្តអារាម គោរពដូចអាទិទេព ។

– អាទិទេពខ្លះជាមានក្បាលដូចដំរីនោះ មានរឿងនិទានថា កន្លងកាលពីព្រេងនាយ កន្លងមកជាយូរណាស់មកហើយ មានព្រះមហាក្សត្រមួយព្រះអង្គ មានព្រះរាជបុត្រា ២ អង្គ មាននគរពុំប្រាកដ បុត្រច្បងនាមសិទ្ធិសួស្តិ៍ បុត្រប្អូននាមព្រះកណេស ។ ព្រះរាជបុត្រប្អូនទៅស្វែងរករៀនចំណេះវិជ្ជានៅក្រុងរោម តែទំនៀមទម្លាប់ស្រុកគេ តែសិស្សរៀនសិល្បសាស្ត្រពូកែ គេមិនឲ្យចេញពីប្រទេសរបស់គេទេ ខ្លាចសាយភាយតម្រិះវិជ្ជានោះទៅបរទេស លុះបានដឹងដូច្នេះហើយ ក៏ទៅសុំគេរៀន ពេលរៀនចេះបត្តសិល្បសាស្ត្រវិជ្ជាពូកែស័ក្តិសិទ្ធិហើយ ព្រះកណេស ខ្លាចភ្លេច ក៏សាក់សរសេរដាក់ពេញខ្លួនទាំងអស់ មានទាំងដាក់ជាចំណាំជើងទៀតផង ។ ព្រះកណេសឃើញថាសិល្បសាស្ត្រវិជ្ជាការខ្លួនបានចេះសព្វ ហើយពូកែជាងកូនសិស្សឯទៀតផង ថែមទាំងអាចារ្យទិសាបាមោក្ខ គេដាក់បញ្ញត្តិមិនឲ្យត្រឡប់វិលមកស្រុកខ្លួនវិញផង ក៏លបរត់ចេញពីក្រុងរោមមកស្រុកខ្លួនវិញ ។ ក្រោយមកអាចារ្យគេដឹងថា បាត់ព្រះ

កឃ្លេសហើយ គេប្រើហិបយន្តឲ្យហោះតាមរក គេបញ្ជាឲ្យកាត់ក្បាល នាំត្រឡប់ទៅវិញ លុះហិបយន្តតាមទាន់ក្នុងព្រៃកណ្ដាលផ្លូវ ក៏កាត់ក្បាលព្រះកឃ្លេសយកបាត់ទៅ ៗ នៅសល់តែដងខ្លួន ដេកស្តូកស្តឹងកណ្ដាលព្រៃម្នាក់ឯង បាត់ប្អូនយូរពេក ព្រះសិទ្ធិស្វស្តិ៍ជាព្រះជេដ្ឋា ក៏ទៅតាមរក ឃើញស្នាមគេកាត់ក្បាលព្រះអនុជថ្មី ៗ ដងខ្លួនដេកស្តូក តែមានដង្ហើមនៅឡើយ ចង់ឃើញប្អូនដូច្នេះ ក៏សោកសង្រេងជាខ្លាំង រូបពិនិត្យនូវដងខ្លួន មានសាក់ជាអក្សរថា ឲ្យយកក្បាលអ្វីក៏ដោយចុះមនុស្សក្តី សត្វក្តី ទៅភ្ជាប់ត្រង់ស្នាមកំបុត ហើយសូត្រគាថាដែលចារឹកទុកខាងលើនេះ សត្វឬមនុស្ស ដែលស្លាប់ ដោយគេកាត់ក្បាលនោះនឹងរស់វិញ ព្រះសិទ្ធិស្វស្តិ៍ត្រេកអរណាស់ ខំស្វែងរកទៅ ប្រទះឃើញដំរីមួយទើបស្លាប់ ក៏កាត់ក្បាលមកបន្តឲ្យប្អូន ត្រឡប់ជាមានជីវិតរស់ឡើងវិញ នាំគ្នាបួលមកស្រុកទេសដើមវិញ សិល្បសាស្ត្រមន្តវិជ្ជាការបែកសាយភាយពេញទាំងស្រុកទៅ ៗ យើងនិយមសាក់មន្តគាថានិងចេះបញ្ចេញបទនមស្ការគ្រូបាលីគាថាស្តោះផ្លុំថា ឧម្ម (អូម) ជាខាងដើម តាំងពីនោះរហូតមក ៗ (បានឮលោក លឹម-ចេង ទៅអង្គតាសាមនិទាន)

ការប្រើសត្វជាតុជារបស់ប្រើប្រាស់និងក្នុងការផ្សំថ្នាំ :

ស្បែកពស់ គេដាសស្គរការ៉ែ ដាសទ្រ ស្បែកគោដាសស្គរធំ តូច ស្គរយីកេ, ស្លាបក្ងុក គេធ្វើផ្លិត, រោមចៀម គេធ្វើចៀមព្រំ,

ឆ្អឹងគោ គេដុតឲ្យខ្មៅ, បុកឲ្យម៉ដ្ឋលាយដំបៅឲ្យឆាប់សះមុខ ឆ្អឹងសត្វញញី ធ្វើថ្នាំលាបពិស ថ្នាំត្រជាក់, ឆ្អឹងជីវី ទំនុកកាគេយកធ្វើមេអាប៉ោន ធ្វើថ្នាំត្រជាក់ដែរ, ស្នែងក្របី គេធ្វើជាប្រអប់ ធ្វើខ្សែក្រវាត់, ស្នែងក្របីផ្ទុះ ការពារអំពើ ការពារដើរកាត់ភ្លៀងកុំឲ្យរន្ទះបាញ់, ក្រចកអក ចង-កកូនៈក្នុងការពារជម្ងឺស្កន្ធ, ក្រចកខ្លា ចង-កកូនកុំឲ្យយំយប់ ធ្មេញប្រហោង ការពារដើរព្រៃភ្នំ ផ្ទុំកុំឲ្យខ្លាមកបៀតបៀន. ខ្មោចបិសាចក៏មិនហ៊ានលងបន្លាចដែរ ។ (លោកគ្រូដ៉ែត-ស៊ុង ភូមិព្រៃឈើទាល គាត់ពន្យល់ប្រាប់ពីឆ្នាំ ១៩៦៧) ។

សត្វនិងទីកន្លែងនានា:

ត្រង់នេះក្នុងក្បួនបុរាណលោកស្ដីថា បើឈ្មោះប្រុសត្រូវរើសយកដើមអក្សរ អក្សរ៦វគ្គដូចខាងក្រោម :

១ — អក្សរ ក ខ គ ឃ ង នាមខ្លា

២ — — ច ឆ ជ ឈ ញ នាមរាជសីហ៍

៣ — — ដ ឋ ឌ ឍ ណ នាមគ្រុឌ

៤ — — ត ថ ទ ធ ន នាមនាគ

៥ — — ប ផ ព ភ ម នាមកណ្ដុរ

៦ — — សេសវគ្គ យ រ ល វ ស ហ ឡ អ នាមដំរី

- បើឈ្មោះស្រីប្ចកូមិ ស្រុក ឲ្យយកខាងបុងអក្សរ ឧបមាថា :
- ស្រីឈ្មោះនាង ឡេកវ ឃូរ សេសវត្ត ជានាមដំរី
- កូមិប្រស្ចិង ខាងបុងឲ្យល់ង ពួក កវត្ត នាមឆ្ងា ។

សត្ថនិងពិធីផ្សេង ៗ

សត្ថចិញ្ចឹមឆ្ងះ គេនិយមយកទៅប្រើក្នុងពិធីផ្សេង ៗគឺ :

- ត្រីរ៉ស់ យកទៅជាក់ក្នុងទឹកស្រះ ក្នុងពិធីសុំទឹកភ្លៀង ។
- ធ្មាសម្ប្សរ ៣ គេបីហៃឡើងផ្ទះថ្មី ។
- គោឡេ គេយកទៅក្នុងពិធីឡើងអ្នកតា ជាទ្រនឹបក្នុងការ រៀនមន្តអាគម ។ ប្រើនតែជិតព្រំដែនលាវ ។
- ក្របីឡើង-ក គេយកទៅធ្វើក្នុងពិធីឡើងអ្នកតាដែរ គេសន្មត ថាជាយានជំនិះ ថ្ងាយលោកតា ឃើញនៅខាងយុំទឹកវិល ស្រុកស្អាង (កណ្ណាល) គេឡើងអ្នកតាយ្ងាំងមៀង ។
- គោធំ ៗ គេហៅគោ ឧសភរាជ គេយកទៅធ្វើពិធីបួងសួង នៅពេលធ្វើព្រះរាជពិធីច្រត់ព្រះនង្គ័ល ឃើញធ្វើនៅខេត្តតាកែវ ក្នុងឆ្នាំ ១៩៤៩ ។

- ចប់ -



រឿង ចរវង្ស-សូរវង្ស

(បម្លងពីសាស្ត្រាស្លឹករឹត)

លោក លី-ធាមតេង ស្រាវជ្រាវ-ពិនិត្យផ្ទៀងផ្ទាត់

(ក)

បទពំនោល

នេសាទចេញពីគុហា នាំព្រាយនេះណា ដល់ផ្ទះកំលោះទ្រង់ទុក ៗ
ព្រាយនោះបម្រះអុកឡុក នៅពុំស្រណុក ភិតភ័យចប្រប់អាត្មា ៗ
ហេតុតែមានពៀរវេរា ពៀរនោះឯណា មកត្រូវព្រះអង្គក្សត្រថ្លៃ ៗ
រីអ្នករន់ទុករន់ភ័យ ប្រាំឆ្នាំហើយន័យ ពុំបានអាហារភោគា ៗ
ហេតុអ្វីក៏អត់ម្ល៉េះណា ពុំក្ស័យជន្មា តើហេតុអំពើកម្មអ្វី ៗ
ឆ្លើយថាបទអ្នកបានធី សាបមានអំពី ព្រះពិស្ណុការគាឡា ៗ
ទោះអស់ៗសែនឆ្នាំណា ពុំក្ស័យជន្មា ចម្រើនទិត្យនៅពុំដាច់ ៗ
ព្រះអង្គពូជពង្សរពេធ្ម ប្រាំមួយឆ្នាំគ្រប់ ក៏ស្ដេចរន់ទុកវេទនា ៗ
ស្ដេចតែងសង្វេគអនិច្ចា គិតគុណមាតា ពុំដែលដល់មួយពគ្រី ៗ
តែដះហេតុព្រះបារមី ពន្ធកជិនស្រី វេញកតែគុណមាតា ៗ
ករក្រើកអំពើកមហិមា ក្តៅដល់អាសនា ព្រះឥន្ទឥស្សរឯងហោង ៗ
ព្រះឥន្ទបើកទិព្វចក្ខុផង ដឹងអស់អាថិផង ដោយនូវវិញ្ញាណនេត្រា

ព្រះឥន្ទ្រគន់គិតឯងថា　អ្នកនោះណា　ទីងអស់វេទទុក្ខល់ ។
បើដោយអង្គអញឯងយល់ អ្នកនេះដូចកល់　ព្រះពុទ្ធបុណ្យអ្នកហើយ ។
ឲនាងកែសកេសីហើយ　ពុំជឹងខ្លួនឡើយ　ជាប្ដីបុណ្យឯងហោង ។
ត្បូងអញបំពេញនេះម្ដង　អាសូរអ្នកវង　លំបាកពន្ទឹកមហិមា ។
ព្រះឥន្ទ្រហោះផ្សងវេហាស៍　ប្រាណប្រែកាឡា　ដំជាព្រាហ្មណ៍មួយព្រឹទ្ធ ។
មកកាឡាក្នុងពត្រី　នាងកែសកេសី　ក៏នាងផ្ទុំលក់និទ្រា ។
យល់សប្ដិដូចព្រាហ្មណ៍មួយណា តាចាស់ព្រឹទ្ធា　សំណេះសំណាលស្រដី ។
ថាហៃនាងកែសកេសី　នាងជឹងជាប្ដី　បុណ្យនៃនាងមករក ។
អ្នកនេះជាតិជាពន្លក　ពង្សពុទ្ធអ្នកមក　អម្ចង់ប្រាំមួយឆ្នាំហើយ ។
ម្ដេចនាងនៅស្ងៀមព្រងើយ　ពុំនាំពារឡើយ　អាសូរព្រះអង្គតិចក៏ ។
ព្រះអង្គពូជពង្សក្សត្រា　ស្ដេចទួលទុក្ខា　លំបាកព្រះអង្គសល់ក្ដាត់ ។
ព្រះឥន្ទ្រប្រាប់ស្រេចស្ងៀមស្ងាត់ អន្ដរធានបាត់　ក៏ហោះឡើងទៅសួគ៌ា ។

បទកាកគតិ

នាងកែសកេសី　នាងភ្ញាក់ឡើងពី　បន្ទំនិទ្រា
នាងគិតរំពឹង　ដញ្ជឹងឯងថា　ឲអ្នកឯណា
មែនជាស្វាមី ។

បើដោយអញ្ញសព្ទ	អញ្ញគិតទៅត្រប់	ក្រែងបោរក្នុងក្តី
សន្ធៃសន្ធឹក	ពន្ធឹកឥតបី	ចូលជួបធ្នាំថ្ម
	ប្រាំមួយធ្នាំហើយ	។
ឥតមានអ្នកឯណា	មួយនឹងមកជា	គម្រប់ពីរទ្បើយ
បើដោយនិមិត្ត	ខ្ញុំគិតជាត្រើយ	អ្នកនោះឯងហើយ
	មិនទេទ្បើយណា	។
ឆ្លរអញ្ញឯងលង	ហើយប្រណិធានផ្សង	នឹងអស់ទៅតា
បើអ្នកនេះមែន	ជាតិជាក្សត្រា	តំណែងកាឡា
	អញ្ញឯងមែនពិត	។
ជូចនាអញ្ញយល់-	សប្ពសួស៏មង្គល	បរិបូណ៌ពិពិធ
រីអញ្ញនេះហោង	ផ្សងដោយនិម្មិត	សូមជូចកំហិត
	ប្រាថ្នាអញ្ញហោង	។
តេជះទៅតា	និត្យនៅរក្សា	ប្រាង្គប្រាសាទផង
នូវស្ទេតច្ចត្រ	រួតរ័ត្នឥតហ្មង	សូមស្តាប់ខ្ញុំផ្សង
	ប្រណិធានសច្ចា	។
បើអ្នកនេះពិត	មែនជូចតំនិត	ខ្ញុំយល់ទាត្រា
សូមឲ្យអ្នកផង	ដេកគងលើគ្នា	ពុំក្ញាក់អាត្មា
	ដល់មួយទ្បើយហោង	។

នាងផ្សងតែម្ហ៉ះ	កាលរាត្រីនោះ	អស់ក្រវែលផង
ងងុយទីទៃ	ក្ងេចដៃវាយតង	ដោយយាមសោតហោង
	ក្ងេចតាំងនាឡិកា	។
អស់ស្រីស្រិង្គារ	អម្បាលក្នាក់ងារ	ចូលចាំរក្សា
ងងុយដោកងាក់	ពួនពាក់លើគ្នា	ប្រះប្រាណនិត្រា
	លក់លន់ពេកហោង	។
អ្នកខ្ទះរវៃ	សំឡីនៅដៃ	ដេកទៅជាម្តង
អ្នកខ្ទះសសោះ	អម្បោះអនួង	ដេកលក់ទៅហោង
	ពុំក្រាក់អាត្មា	។
ប្រាសាទនោះនៃ	តាំងយប់តាំងថ្ងៃ	ក្ងើងក្ងឹជួចគ្នា
ក្នាក់ងាររក្សា	សព្ទទិនទំវា	ពុំដែលជាប់ជា
	រាត្រី ១ ឡើយ	។
នាងកែសកេស៊	នាងផ្សងបារម៉	ប្រាកដមែនហ៊ីយ
នាងដៀនិម្ងិត	ពុំតិតជាត្រើយ	នាងមិនតិតឡើយ
	យល់ស្តែងមហិមា	។
នាងកែសកេស៊	នាងចេញអំពី	ប្រាសាទហោកា
ម៉ើលយល់អ្នកផង	ដេកតង់លើគ្នា	ទើបនាងយាត្រា
	យាងយាស់ដើរជល់	។

ព្រះពោធិសត្វ ពន្ធុកបរមត្ថ ស្ដេចស្ដែងយន់យល់
រត្នកជក្សត្រី ប្រឹមប្រីយ៍សោភា ប្រសើរមង្គល
ម៉ត់ហ្មងប្រពៃ ៗ
ស្ដេចឯងដឹងថា រីនាងនេះណា មិនអ្នកដទៃ
សមបុត្រព្រះបាទ នរនាថជៀស្ធជ័យ ស័ក្តិសមប្រពៃ
ប្រឹមប្រិយ៍ម៉ត់ហ្មង ៗ
តាំងនោះសោតណា ក្រែងស្រីទេព្តា មកពីសួគ៌ហោង
ឯងអាចបំពេញ អង្គអញនេះម្ដង ត្បិតអញឯងរង
ពៀរពន់ជូន់ក្រៃ ៗ
គួរអញដណ្ដឹង ឲ្យជាដំណឹង កាលនោះឯងនៃ
ក្រែងជាទេព្តា មេត្តាប្រពៃ មោះមានហឫទ័យ
ដោះទុក្ខអញហោង ៗ
ក្រែងតែបុត្រក្សត្រ ប្រជាកស្ត្ររដ្ឋ មោះមកលលង
អញនៅដណ្ដឹង កាលនោះឯងម្ដង ឲ្យដឹងទំនង
ដំណើរនោះណា ៗ
ទើបពោធិសត្វ ព្រះទុស្សរ័ត្ន ត្រាស់ដណ្ដឹងថា
ហៃនាងប្រសើរ ឈរមើលរក នាងមកពីណា
តាំងរាត្រីកាល ៗ

នាងនាថក្សត្រីយ ថ្វាថ្លែងស្រដី សំណេះសំណាល
ថាខ្ញុំនេះណា ជាបុត្រភូបាល អង់ឥតរង្គាល
សោយសុខពិរម្យ ៗ

មិត្យនៅប្រាសាទ ប្រសើរស្អាងស្អាត ខែនទិព្វបន្ទំ
ក្រោមស្វេតច្ឆត្រ រត្តរតន៍ឧត្តម ពូកព្រៃព្រួញព្រំ
ក្រាលក្រោមនោះណា ៗ

ខ្ញុំដេកនាយប់ នោះខ្ញុំយល់សប្ត ដូចព្រាហ្មណ៍ព្រឹទ្ធា
មួយមកដាលដល់ មណ្ឌលក្រឡា បន្ទំសោភា
សំណេះមេត្រី ៗ

ព្រាហ្មណ៍នោះថៃថា ហៃនាងថ្លៃថ្លា ប្រសើរសល់ស្រី
នាងមិនដឹងជា ក្សត្រាធិបតី ជាតិជាស្វាមី
បុភណខាងហោង ៗ

អ្នកនោះបណ្ឌល ពន្សុត្តង្គុរ លើសលើលោកផង
អ្នករង់ទុក្ខភ័យ ក្រាស់ក្រៃក្រទួង អាហារសោតហោង
ពុំបានភក្តា ៗ

ពិបាកព្រះអង្គ យង់យូរអម្ពុង ប្រាំមួយឆ្នាំណា
ម្តេចនាងព្រងើយ ពិតពុំនាំពារ ប្រណីក្សត្រា
លំបាកក្តាត់ក្តៅ ៗ

ព្រាហ្មណ៍នោះប្រាប់ហើយ ពិតពុំលង់ឡើយ អន្ទរធានទៅ
ខ្ញុំភ្ញាក់និទ្រា ចិន្តាចាំនៅ គិតត្រង់ព្រះចៅ
ខ្ញុំប្រណិធានផ្សង ។
ប្រណិធានសច្ចា អធិដ្ឋានថា ត្រង់អ្នកឯងហោង
ឲ្យអស់ព្រះស្នំ ស្រីក្រមនោះផង ក្រវែលគាក់គង
ដេកលក់និទ្រា ។
ហេតុតែនិមិត្ត យង់យល់ពុំទក្យ ព្រាកដមហិមា
អស់តាំងអ្នកផង ដេកគងលើគ្នា ពុំភ្ញាក់អាត្មា
ដល់មួយឡើយហោង ។
ខ្ញុំយល់ចូរហោះ ទើបខ្ញុំអាចនោះ មោះមកជួបផង
ចិត្តចង់ឲ្យជាក់ ដល់អ្នកជាមួង ហើយចង់មកលង
ដណ្តឹងដើមក្តី ។
អ្នកអើយពីមុន អ្នកនៅតំបន់ ទតទិសទី
ឯនាមស្រុកនោះ តើឈ្មោះអ្វី ចូរអ្នកស្រដី
ប្រាប់ខ្ញុំតិចក៏ ។
ព្រះពោធិសត្វ ស្តាប់ព្រះបុទរ័ត្ន បំណេះសច្ចា
ស្តេចគិតនោះនៃ ព្រះទ័យចិន្តា ឆាន់នោះឯងណា
បុរាណអញពិត ។

ទើបស្ដេចឆ្លើយថា	ហៃប្អូនករិយា	បុកណដំនិត
កាលមុនយើងបាន	រួមហាំឧប្បលមិត្ត	សាច់សង្សារពិត
	ដូចសព្វនោះណា	ៗ
ប្អូនអឺយប្អូនស្ដាប់	បងនឹងថ្លែងប្រាប់	នគរនាមា
បងនៅគំបន់	ក្រសន់ទិសា	ស្ដេចវង្សសុរិយា
	ធិពជជៀស្លដ័យ	ៗ
សោយកជសម្បត្តិ	ប្រាសាទរួតរ័តន៍	ពលព្រិទ្ធក្រាស់ក្រៃ
ស្ដេចប្រាំរយមួយ	សម្រាប់សព្វថ្ងៃ	បង្គំក្យត្រថ្ងៃ
	ប្រក្រតីហោងណា	ៗ
ស្ដេចនោះឯងនៃ	មិនអ្នកដទៃ	គឺព្រះបិតា
ឯម្ដាយបងនោះ	ឈ្មោះនាងវង់ធ្យា	ទេវីសោភា
	កាយិអគ្គមហេសី	ៗ
ឯស្នំស្នេហា	ប្រាំមួយម៉ឺនណា	សម្រាប់ប្រក្រតី
ហាក់ទេពអប្សរ	បវរនារី	ស្ដេចមានទេពី
	ពីរពង្សគ្រប់គ្រង	ៗ
ឈ្មោះនាងមន្ទា	ទេពីនោះណា	បន្ទាប់ម្ដាយបង
ព្រះវរបិតា	ករុណាស្នេហោង	ពុំដែលឲ្យគ្គង
	អាក់អន់ចិត្តា	ៗ

មាតាបងមាន	រាជបុត្រពីរប្រាណ	សឹងប្រុសជូចគ្នា
មួយឈ្មោះសូរវង្ស	មួយឈ្មោះវង់ធ្យា	សូរវង្សនោះជា
	ព្រះរៀមបងហោង	។
បងឯងសោតណា	ឈ្មោះវរវង្ស	អនុជស្នេហ៍ស្នង
ឯនាងមន្ទា	មានបុត្រគ្រប់គ្រង	នាមចៅនោះហោង
	ឈ្មោះវិវវង្ស	។
នាងមន្ទាខ្ទាច	យើងជណ្តើមរាជ្យ	នឹងកូននោះណា
តាត់លួងយើងទៅ	ទាំងពីរអង្គា	ហើយតាត់ស្រែកថា
	យើងនឹងធ្វើអ្វី	។
ឯព្រះបិតា	ពុំពិចារណា	ឲ្យដឹងដើមក្តី
ប្រើគេសម្ទាប់	យើងធាប់ជូចក្តី	នាំយើងទាំងពីរ
	ជល់ព្រៃស្មសាន	។
ឯព្រះមាតា	អ្នករត់ម្ទីម្ទា	តាមយើងដោយដាន
លុះអ្នកដើរជល់	មណ្ឌលទៀបឋាន	អ្នកស្រែកឃាត់ថ្ពាន
	មិនឲ្យសម្ទាប់	។
អ្នកបូតព្រះទំរង់	ពីព្រះហស្តទ្រង់	យកមកប្រដាប់
អ្នកឲ្យដំណើរ	យើងរត់មកធាប់	ហើយអ្នកក្រឡាប់
	រិលវឹងទៅខ្ទី	។

យើងដើរមកស្មោះ ដល់ស្រុកមួយនោះ គន្ធពបុរី
រាអស់កម្ចាំង ទន់ទាំងឥន្ទ្រីយ គាប់ជួនរាត្រី
ព្រលប់សន្ធិយា ។

យើងឈប់សម្រាន្ត យើងដេកនាឋាន បរមសាលា
ស្តេចស្រុកនោះសោត ក្រេវក្រោធមហិមា នាំអស់ឆ្នីគ្នា
ពន្ធឹកវឹកវរ ។

ចាប់ព្រះរៀមបង នានាំទៅបោង ចរចូលនគរ
បងភិតភ័យខ្ចាច ពុំអាចឈប់ឈរ រួតរត់ចេញចរ
ជួចដល់ស្រុកអាយ ។

ដើរមកជួនយប់ ភ្ជៀងអុរសស្រប់ ពុំដឹងអាចនាយ
មកផ្ទះជួនចាស់ ឃ្ជានណាស់សួមបាយ គាត់ថាពាយងាយ
ដេរហើយដៀលផង ។

ប្រែមុខប្រែក្រោយ ហើយទើបគាត់ឲ្យ ចន្ពិចហូបហោង
ងងឹតសព្ទសល់ ពុំយល់ទិសផង យកត្ឈូងនោះហោង
មកពាក់នៅដៃ ។

រាយល់ត្រចះ ភ្ជឹអស់ទាំងផ្ទះ ជួចភ្ជើងវិស័យ
ឯជួនចាស់នោះ គាត់សួះមកនៃ ឃើញត្ឈូងនៅដៃ
ទៅទូលមហាក្ស័ត្រ ។

ទើបនាំអាជ្ញា ចាប់ចងហើយណា ផ្ទើក្តីសល់ក្តិត
សោជ្ជ្ឈលតាងរាង ខ្នោះយ្នាងប្រកិត ជ្រាំមួយឆ្នាំស្ទាត់
                ឥតមានប្រណី ។

ហៃព្រះបួនក្សា ជំណើរថ្នេះណា ឥតមានទោសអ្ទី
តាមតែបួនមាស មិត្រមានប្រណី ហើយក្រែងបារមី
                បុរាណជួយហោង ។

នាងនាថស្រីរ័តន៍ ស្តាប់ពោធិសត្ទ ថ្ទែងដោយតន្ទង
នាងនាថអាណិត មហាក្សត្រក្តាត់ហោង កិលាបយំផង
                នឹងពោធិសត្តា ។

នាងនាថស្រីរ័តន៍ នាងទើបប្រណិប័តន៍ ព្រះអង្គក្សត្រា
នាងថ្ទាយបង្គំ ប្រណម្យលុតលា យាងយាសយាត្រា
                ដើរដល់មណ្ឌល ។

រីកាលនោះហោង អស់អ្នកយាមផង ក្ញាក្ញាក់រចល់
ថាទ្ធយើងដេក ជំណេកសុខសល់ នេះហេតុកាលកល់
                និមិត្តនឹងអ្ទី ។

ម្ទោះហើយអ្នកផង កាន់ការផ្ទើហោង ជួចនៅប្រក្រតី
ខ្ទះសើចខ្ទះលេង ខ្ទះច្រៀងផ្ទុំបុ រក្សាក្សត្រី
                ជួចកាលសព្ទថ្ទៃ ។

រ៉ីនាងក្សត្រី ជានយល់ចក្រី ស្តេចទុលទុក្ខកឹយ
នាងនាថគន់គិត អាណិតក្សត្រិថ្ថ សង្រេងសង្រៃ
សែនសោយសោកា ។

បទ៥ឆ្ជឯ៥

កាលនោះឯក្សត្រី កែសកេសិនាងទៀងទ្ធញ្ញាថា
ឧព្រះវរវង្សា ស្តេចស្តែងជាពង្សពុទ្ធង្ក្ខរ ។
អម្ឃូរព្រះរាជបុត្រក្សត្រា ពន្ធកបណ្ណ្ណលពួជពង្សជាកំពួល
លើសលោកជង ទ្ធទាំងភពត្រ៉ៃយ ។
ម្តេចទ្បើយជល់គោកយ៉ាក មកពីជាករងទុក្ខរងកឹយ
ទាំងអាហារសោតនៃ ព្រះអង្គអត់ពុំជានភោក្តា ។
ឲ្ចុំគិតទៅព្រះអង្គ ជ្ជាប់រែងគង៉ទៅជាក្សត្រា
ពុំដែលអត់អាហារ ចរិកោគក្តារជាប្រក្រតី ។
ពុំដែលស្គាល់ទុក្ខកឹយ ព្ជ្ជួយហប្ចទ៉ីយលំជាកឥន្ធ្ជីយ
ម្តេចទ្បើយមករងក្តី ពន់ប្រមាណពន្ធឹកលើសក្រៃ ។
ឧហេតុកម្មវេរ ព្រេងនាយណាតាមមកទាន់នៃ
ឲ្យអ្នករងទុក្ខកឹយ ពៀរពុំស្មើជល់តិចទ្បើយណា ។
ឧអម្ចាស់ឲ្ចំអើយ ផ្ទើម្តេចទ្បើយនឹងអស់វេរ
ចៃជានរ្ជចកាលត្រានេះ ហេតុបុរាណមកជួយហោង ។

ឱអ្នកណាជួយស្រាយ ឲ្យរសាយអស់ទុក្ខនោះផង
រួចបេញពីចំណង ជ្រួលប្រវាក់ខ្នោះឃ្នាងនោះណា ៗ
នាងនាថសោកគន់គិត គិតអាណិតទៅវរវង្ស
អង្វរអស់ទេព្តា ផងឲ្យជួយដោះទុក្ខនោះនៃ ៗ
បពិត្រអស់ទេព្តា ឋិតនៅនាសុខសួគាល័យ
ទេវតាទិត្យនៅឮ ប្រថពីភូមិភពនេះហោង ៗ
អ្នកជួយលំដោះទុក្ខ ឲ្យសាន្តសុខកាលនោះឯងម្តង
អស់គ្រឿងចំណងផង ឲ្យស្រាកស្រាន្តពីព្រះអង្គថ្លាត់ ៗ
នាងនាថសោកសង្រេង ញ័រកន្ទេងអស់ថ្លើមប្រមាត់
នាងឃើញព្រះមហាក្សត្រ ខ្សឹកខ្សួលនៅពុំភ្លេចឡើយហោង ៗ
នាងឃើញព្រះអង្គថ្លៃ ក្នុងហឫទ័យនាងគិតប៉ុនប៉ង
ចង់មូលដូចបំណង ទឹងមហាក្សត្រជាតិជាស្វាមី ៗ
នាងនាថទឹករលឹក មមាញឹកថៃ ៗ ប្រក្រតី
នាងគិតព្រះចក្រី ខ្លាចពុំរួចពីទុក្ខនោះណា ៗ
នាងគិតរឹងបង្អៀត នាងទួញទៀតពិលាបសោកា
ថាឱព្រះកជា ម្រាងព្រះអង្គទឹងរួចឥឡូវហើយ ៗ
ពីខ្ញុំដើរដូចដល់ បានយង់យល់ព្រះអង្គឯងហើយ
ដួបចិត្តចងជាត្រើយ ពុំរសាយដល់គិចហោងណា ៗ

ថាបើព្រះអង្គថ្លៃ រូបពីភ័យពីទុក្ខទាគ្រា
នេះហើយហេតុទេវតា ជួយចម្រើនព្រះអង្គឯងហោង ៗ
ខ្ញុំក្រពេកអ្នកអើយ ធ្វើម្ដេចឡើយឥឡូវនេះម្ដង
នឹងរូបពីចំណង ទុក្ខភ័យផងកាលនោះឯងណា ៗ
ឥតលុះខ្ញុំជាស្រី ក្រឥតបីនឹងថ្លៃងនឹងថា
ខ្ញុំនឹងទូលបិតា យល់ពុំគួរពីមាត់ខ្ញុំហោង ៗ
ខ្ញុំនឹងរិះម្ដេចណា ឲ្យក្សត្រារូបចេញនេះម្ដង
ខ្ញុំរើសៗហើយហោង រីងថៃថប់ពន្ទុកលើសក្រៃ ៗ
ទើបនេះខ្ញុំបានដឹង ទុក្ខផ្សេងៗក្រាស់វិស័យ
ក៏មានតែសន្ទៃ សន្ទឹកញ៉ាំអស់អង្គអាត្មា ៗ
ក៏មានតែបំផ្អុក ពុំស្រណុកដល់តិចឡើយណា
លន្ទង់លន្ទោពផ្កា កន្ទើមថ្ងៃពុំបានឡើយថៃ ៗ
បើព្រះអង្គក្សត្រថ្លៃ រូបពីភ័យពីទុក្ខមោះផង
ដូចខ្ញុំប្រាថ្នាផ្សង ទើបខ្ញុំនូវស្និទ្ធស្នេហ៍នេះហោង ៗ
នាងទួញកន្ទក្រោ សោយសោកក៏លាបលន់ពេកក្ដាត់
ទួញទៅព្រះមហាក្សត្រ ផ្ដូទទូលសន្ទឹកនោះហោង ៗ

បទកាកគតិ

នេះនូវស្រដី បើកបទបាលី ដំណាលទំនង
មែនមាននគរ បវរឥតហ្មង នាមនោះហោង
ហៅជ័យបុរី ។
ស្តេចមួយសោយរាជ្យ នាមនៃឯងសាប ហៅព្រះបាទស្រី
សោរទត្តរាជា អំណាចបុទ្ធិក្រៃ ឥស្សរធិបតី
រាស្ត្ររដ្ឋប្រជា ។
មែនមានអរ័ក្ស ឃ្លាំងមឿងប្រត្យ័ក្ស និត្យនៅរក្សា
ខាងទិសបូរ៌ បុទ្ធីមហិមា ឲ្យក្សេមប្រជា
រាស្ត្ររដ្ឋបរិវារ ។
ស្តេចនោះជាមិត្ត នឹងស្តេចឧទិត រាជាគូនាថ
ឲ្យទៅឲ្យមក វៃងរកប្រការ ប្រក្រតីជាតិជា
តាំងជាប់មួយថ្ងៃ ។
ស្តេចនោះសោតមាន បុត្រីកល្យាណ រាងរូបប្រពៃ
កើតគបលក្ខណា ប្រាជ្ញាឈ្វេងវៃ មានអធ្យាស្រ័យ
ស្រស់ស្រាយប្រាជ្ញា ។

នាងនាថក្សត្រី ឈ្មោះវេវតី ពន្ធកក្សត្រា
ស្ងួនត្រង់ស្រឡាញ់ អស់អញរគ្រា ថ្នមបុត្រពុំងា
ពិតពុំឲ្យម្តង ។

កាលនោះសោតមាន យក្សមួយហៅបាន មោះមកប្រឡង
ប្រឡែងបេស្តា ទីងឃ្មាំងមឿងហោង នាមយក្សនោះផង
ឈ្មោះសោឡសយក្ស ។

គយុទ្ធគបះ យក្សមានជ័យឈ្នះ វាដេញសាក្យ
រត់ពីលំនៅ នោះជាសំណាក់ ឈើមួយសន្ធិស័ក្តិ
ធំព្រៃកន្ទង ។

រសោឡសយក្ស រត់ទៅសំណាក់ បានឃ្មាំងមឿងហ្ងង
រីបាននោះជា គុហាឯងហោង ថ្មធំពីរផង
ផ្កាប់នាមាត់ទ្វារ ។

យក្សចូលទិក្សនៅ ឯកឯងយោរយៅ ទ្រុស្តទ្រើសគ្រពា
យក្សយកសិលា សឹងជាថ្មជា បាំងបិទមាត់ទ្វារ
គានតឹងក្តាត់ហោង ។

ទើបយក្សស្រែកថា រុំយមបាក្សត្រា ស្តែងស្តេចគ្រប់គ្រង
បុរីមណ្ឌល សកលពស្ត្រផង អង្គអញឯងហោង
ឈ្មោះសោឡសយក្ស ។

អញឯងបេស្តា　ប្អូនមហិមា　គនឹងការក្សា
អញឈ្នះអញរាយ　ខ្ចាត់ខ្ចាយបែកបាក់　រត់ទៅសំណាក់
　សព្វព្រៃព្រឹក្សា　ៗ
អញមកនេះហោង　អញគិតប៉ុនប៉ង　ពីនាយឯងណា
អញប៉ងនឹងធី　តែអង្គក្សត្រា　រាស្ត្រប្រជា
　អញពុំធីឡើយ　ៗ
អញមកនេះណា　តែឯករស្សា　អញបានធីហើយ
អញនឹងវិលទៅ　លំនៅជាត្រើយ　អញមិនទៅឡើយ
　ទៅឋានអញហោង　ៗ
ព្រះបាទក្សត្រា　ស្តាប់ពាក្យយក្សា　ស្តេចគិតក្នុង
ថាឱអាត្មា　អញគ្រានេះម្តង　ម៉ោះសមស្លាប់ហោង
　នឹងយក្សភោក្តា　ៗ
គួរអញឲ្យទៅ　ដល់មហាមិត្រនៅ　នគរនាយណា
បើបានគាត់មក　អញនឹងផ្តាំថា　ឲ្យគាត់រក្សា
　បុត្រភរិយាផង　ៗ
ទើបមហាក្សត្រា　មានព្រះអាជ្ញា　ត្រាស់ប្រើអ្នកផង
ឲ្យបើកសំពៅ　ទៀងទៅថ្វាស់ថ្លង　ក្រាប់ក្រង់ត្រើយហោង
　អញ្ជើញមហាមិត្ត　ៗ

ឯអស់អាជ្ញា បើកការគេត្រា ដល់ដូចកំហិត
ដោយព្រះបណ្តាំ នានាំទូលពិត អញ្ជើញមហាមិត្ត
សម្តេចរាជា ។

កាលថ្ងៃនាងនាថ បានយល់កូបាល ពង្សពោធិ៍ពុទ្ធា
ព្រឹកឡើងដើរដល់ មណ្ឌលនោះណា គេនាំអាជ្ញា
ទៅទូលក្សត្រថ្ងៃ ។

សម្តេចក្សត្រា ស្តេចស្តាប់វាចា បណ្តាំស្តេចនៃ
ឲ្យអស់សេនា យោធាក្រាស់ក្រៃ នាំពលទីទៃ
ទៅដាក់សំពៅ ។

សំពៅនោះណា ទីនាំឯករាជា សឹងមាសឆ្អឹនឆ្អៅ
សេនានាំពល រចល់ទៀនទៅ ខារដាក់សំពៅ
ពុំចុះទឹកថ្លាត់ ។

ទើបអស់សេនា មកទូលរាជា ស្តេចស្តាប់ពាក្យហើយ
ស្តេចឲ្យប៉ាវគង ដណ្តឹងជាត្រើយ ថាហៃអ្នកអើយ
ហៃម្ហាលអ្នកផង ។

មកដាក់សំពៅ នេះបានចុះទៅ រួចដល់ទឹកហោង
ព្រះអង្គនឹងឲ្យ រង្វាន់ដូចប៉ង មាសប្រាក់កែវកង
ទៀនព្រែជា ។ ។

អាជ្ញាបាំវតង រៀងៗ ទៅហោង ឥតមានអ្នកណា
មួយនឹងជណ្តឹង មកកាន់អាជ្ញា អាជ្ញាយាត្រា
  ដើរជល់ទ្រុងនោះ ។
ទើបពោធិសត្ត ពាក្យពិតប្រណិបីតន៍ ស្រែកជណ្តឹងស្មោះ
ថាវិហអ្នកផង បាំវតងថ្ងៃហ្នោះ សូមអ្នកចំពោះ
  ប្រាយប្រាប់ខ្ញុំវ៉ា ។
អាជ្ញាស្តាប់ហើយ ថាឧលោកអឺយ អញស្មានមនុស្សជា
មិនដឹងអ្នកអើយ កំប្រោនទេណា ចំណោះអ្ងីអា
  ជណ្តឹងយើងថ្ងៃ ។
ថាបើអាចេះ អាមានចំណោះ អារងថ្ងៃក្តី
អាស្ងៀមទៅវ៉ា ជានឹងស្រដី អាមានអាថិអ្ងី
  ធ្ងៃជាដើមអាទ៍ ។
អាជ្ញាវិលទៅ ទូលតាល់ព្រះចៅ ជូចដែលអធិប្បាយ
ស្តេចថាបើហ្នោះ ឲ្យដោះវាស្រាយ នាំវាមកអាយ
  ជណ្តឹងវាឯង ។
ឯអស់អាជ្ញា ស្តេចស្តាប់ក្រាបលា វិលក្រោយទៅនូង
ដោះចេញរំពេច ស្រាប់ស្រេចឥតក្រែង ខ្ទះសើចខ្ទះលេង
  ខ្ទះដៀលខ្ទះថា ។

ហើយនាំព្រះអង្គ ចេញចរត្រាច់ត្រង់ ថ្វាត់ថ្វាយក្សត្រា
លុះទៅដល់ស្រេច ស្តេចដណ្តឹងថា អាដាក់គេត្រា
                អញចុះទឹកបាន ។

ប៉ើដាក់ស្រេចស្រាប់ បានដូចបង្គាប់ អញឲ្យរួចប្រាណ
ហើយអញនឹងឲ្យ រង្វាន់ប្រទាន ទៀនព្រៃធនធាន
                មាសប្រាក់កែវកង ។

ព្រះពោធិសត្ត ក្ស្ចញគ្រាបប្រណិប័តន៍ បង្គំទូលស្ទង
បពិត្រសូមទាន ពុំហ៊ានអួតហោង បន្ទូលប្រើម្តង
                នឹងលែងពុំបាន ។

ស្រាប់តែទៅដាក់ ថាប៉ើបានធ្លាក់ ដូចអធិដ្ឋាន
បពិត្រក្សត្រា ករុណាឲ្យទាន ទៀនទង់ដ៉យបាន
                ពីរមកខ្ញុំហោង ។

ឯមហាក្សត្រា ស្តាប់ហើយករុណា ធ្វើដូចបំណង
ឲ្យទៀនពីរនៃ ទង់ដ៉យពីរផង ស្តេចឲ្យទៅលង
                ដាក់ភារគេត្រា ។

ព្រះមហាក្សត្រថ្ថ អ្នកបានទង់ដ៉យ និងទៀននោះណា
អ្នកទ្បើងទៅធ្វើ នៅលើគេត្រា អធិដ្ឋានថា
                នូវព្រះបារមី ។

បពិត្រទេវតា	សឹងសព្វព្រឹក្សា	បពិតគិរី
សឹងសព្វព្រឹក្សា	នៅមហាប្រថពី	ទិសទាំងប្រាំបី
	អញ្ជើញចូលមក	។
ទេវតាគង់ឲ	សុខសួគិថ្ថាវិថ្ថ	សោឲ្យសព្រហ្ម
អញ្ជើញមូលមក	ជួយជ័យចេស្ពា	សូមឲ្យកេត្រា
	ធ្ងាក់ជល់ទឹកថ្ងាត់	។
ហេតុតែបារមី	វរពោធិជិនស្រី	ពង្សពោធិសត្ត
ស្តេចនឹងបានត្រាស់	ច្បងច្បាស់ទៀងទាត់	សំពៅនោះក្ងាត់
	ខ្ជាត់ពីបង្គង	។
ប្រាកដមហិមា	លូនលឿនឯងណា	ជូបគេអនូង
នឹងខ្សែនឹងព្រ័ត្រ	ខ្ជាត់ជល់ទឹកហោង	អស់នរអ្នកធង
	ស្រប់ស្រែងគ្រប់គ្នា	។
ជ្រាបដល់មហាក្សត្រ	ស្តេចអរពេកក្ងាត់	ព្រះអង្គករុណា
ប្រទានរង្ងាន់	គ្រប់គ្រាន់ទ្រព្យា	ខៀនព្រៃជាៗ
	មាសប្រាក់កែវកង	។
ឲ្យជាអមាត្ស	ជានាយមហាត	បម្រើនោះផង
ស្រេចស្តេចចុះទៅ	សំពៅនោះហោង	ជុំអស់ពលផង
	ស្តេចនឹងលីលា	។

នាងកែសកេសី　នាងយល់ចក្រី　ទៅផងក្សត្រា
នាងនាថពុំនៅ　សុំទៅផងណា　នាងទូលបិតា
· អង្វរផងហោង ៗ
បពិត្រព្រះវរ-　បិតាករុណា　យកខ្ញុំទៅផង
ខ្ញុំឥតទីនម្ដាយ　មានព្រះអង្គហោង　ម្ដេចឲ្យខ្ញុំរង
ទុក្ខឯងឯក្រោយ ៗ
សម្ដេចក្សត្រា　មានព្រះមេត្តា　ករុណាឯងឲ្យ
នាងទៅផងហោង　ព្រះអង្គដាលដោយ　ចិត្តនាងខ្វាចខ្លោយ
ទល់ទុក្ខកំព្រា ៗ

បទភុជង្គលីលា

ទីនថ្ងៃសម្ដេចកាលគ្រា ប្រដាប់កេត្រា　នោះស្រេចហើយហោង ៗ
លីលាយាត្រាផ្លាស់ថ្ងៃ　ហើយហូតស្លាបក្ដាន់　ទៅជ័យបុរី ៗ
គង្គាជលសារជលធី　ធំទឹកឥតតបី　ពុំយល់ត្រើយត្រាណ ៗ
រលកមីរេកលឈាន　ធំៗប្រមាណ　ប៉ប៉ុនភ្នំខែ ៗ
មច្ឆារេពក្រាស់ក្រៃ　អណ្ដើកត្រីស　កន្ធាយល្មើះល្មួច ៗ
មើលមានក្បាយក្បានខ្ពរខ្ពច　ហែបហែលលិចលេច　កណ្ដាលជលសា ៗ
ក្សេកឃ្មុំឆ្មាមូតជ្រោ　ឆ្មាមឆ្មាំងប្រាង់ប្រា　កជករកហ្វូ ៗ
ឆ្កាកឆ្លោរទើតោឆ្លាក្ដូរ　ឆ្លាសៀវឆ្លាថ　ឆ្លាស៊ុកប្រម៉ា ៗ

ក្រពើលើរេក　　គៀរគៀនមច្ឆា　　រង្គាត់លែបលេន　។

មករបរអន្លង់　　ហែបហែលគគ្រេន　លលើទៅមក　។

ពិទូនត្រសនរេក　　ហែបហែលទៅមក　ដោយដេញមច្ឆា　។

ត្រែនគ្រុំគ្រឹកឹក　　ចាក់ប្រែងឆាវណា　ខ្សឹនស័ទ្ទខ្សឹនសោក　។

គង្គាជ្រៅថ្លាស្រណុក　　សប្បាយសាន្តសុខ　រំភើយពេកា　។

បើកដល់មណ្ឌលនាយណា　នគរនាមា　　ហៅជ័យបុរី　។

ក្សត្រាពជាធិបតី　　ស្តេចចូលបតន្ធី　　និក្សនៅកំពង់　។

ដល់ចុះកាលនោះពុំលង់　ស្តេចត្រាស់ឲ្យសង់　ព្រះពន្លាជ័យ　។

អស់ពលខ្លាយខ្វល់ទីទៃ　　តាមដោយព្រះទ័យ　បន្ទូលត្រាស់ប្រើ　។

សេនាយោធាផងធ្វើ　　រៀបអស់សារពើ　　ហើយស្តេចយាត្រា　។

ទៅថ្កានដល់ឋានឧកជា　　មហាមិត្តនោះណា　សាកសួរសេចក្តី　។

ពីរពង្សស្តេចទ្រង់បេតី　　រួមរក្សមេត្រី　　សំណេះនឹងគ្នា　។

គំណាលប្រាប់កាលយក្សា　ប៉ងនឹងគោក្កា　　ព្រះអង្គក្សត្រថ្លៃ　។

បទភាគកត

កាលនោះព្រះបាទ　សោទត្តនរនាថ　　បន្ទូលថាហៃ

ព្រះមហាមិត្តអើយ　　រំយក្សនោះនៃ　　ធំក្រៃវិស័យ

ពន្ទឹកមហិមា　　។

ឥនឹងធីអញ អ្នកអើយអញម្នេញ កិតកីយតក្កមា
អញឲ្យទៅយក អ្នកមកនេះណា អញនាងផ្តាំថា
នឹងអ្នកឯងហោង ។

ឲ្យអ្នកអាស្សរ បុត្រីបណ្ណូល កវិយាអញផង
អស់អង្គសេនា ប្រជាពស្ត្រផង អ្នកមើលផងហោង
អញនឹងស្ទាប់ហើយ ។

ព្រះបាទជានិត ស្តេចស្ទាប់មហាមិត្ត ស្តេចបន្ទូលធ្វើយ
ថាហៃមហាមិត្ត កុំតិតនោះឡើយ អញមកដល់ហើយ
អញនឹងតាក់តែង ។

ឱ្យអញមួយណា ឥមានបេស្ទា ត្រកាលគ្ឆរស្រែង
កម្ទាំងឥមាន ហៅហានទៃងវៃង សំពៅមាសទៃង
ទុកលើបង្គង ។

ឥជាក់ម្នាក់ឯង សោះសាឥតក្រែង ដួចដល់ទឹកហោង
មែនមានបេស្ទារ មហិមាកន្ទង មកយើងឲ្យលង
តនឹងយក្ស ។

ប៉ើឥមានជ័យ ឈ្នះយក្សហើយនៃ យើងចិញ្ចឹមឥ
ប៉ើឥឥតជ័យ ចាញ់ដៃយក្ស ទាល់យក្សកោក្ត
តែឥឯងហោង ។

យើងនឹងមុសា ភូតប្រាប់យក្សា ថាជាស្តេចស្នង
ត្រងរាជ្យមណ្ឌល សកលនេះហោង ឯងអាមកលង
ឬទ្ធីចេស្តា ។

យក្សថាជាស្តេច បើបានធីស្រេច ហើយរាយាត្រា
បើដោយតំនិត អញគិតនេះណា អញយល់ជាក់ជា
ពុំខុសឡើយហោង ។

បើមិត្តចូលចិត្ត ដូចពាក្យអញគិត កាលនោះឯងម្ពង
អញឲ្យទៅយក រាមកដូចផ្ពង ឥឡូវនេះហោង
ពុំគិតឡើយណា ។

ព្រះបាទសោទត្ត ស្តេចអរពេកក្តាត់ បន្ទូលត្រាស់ថា
មិនឲ្យទៅយក រាមកធាប់ណា ហើយយើងប្រើរា
ច្បាំងនឹងយក្សា ។

ព្រះបាទធនិត មកុដរាជ្យបពិត្រ ត្រាស់ប្រើអ្នកផង
នាំព្រះអាជ្ញា មហាក្សត្រដូចផ្ពង ដល់កំពង់ហោង
ហៅពោធិសត្ត ។

ថាម្នាលហៅចៅ ស្តេចត្រាស់ឲ្យហៅ ប្រើចៅទៅថ្ងាត់
ទាំងពីរព្រះអង្ត ពូជពង្សសាពៃជ្ញ ស្តេចទន្ទឹងក្តាត់
ចូរចៅយាត្រា ។

ព្រះពោធិសត្ត ស្តេចធ្វើយវឹងថ្ងាត់ ជណ្តឹងអាជ្ញា
ព្រះអង្គឲ្យហៅ ទៅកាន់ពជា ចូរអ្នកប្រាប់ថា
                ឲ្យអញជឹងផង ។

ឯអស់អាជ្ញា ធ្វាស់ធ្វើយវឹងថា មិនជឹងឡើយហោង
ព្រះអង្គឲ្យហៅ ចូរនៅទៅផង នឹងយើងជាម្ពង
                កុំយូរឡើយណា ។

ស្តេចធ្វើយវឹងស្មោះ ថាបើជូហ្នោះ ចូរអស់អាជ្ញា
រិលទៅក្រាបទូល ព្រះអង្គឯងណា ទោះកាចទោះជា
                ព្រះអង្គប្រាប់ហោង ។

ទោះបីក្សត្រា នឹងប្រើទៅឯណា ជូចហប្ចទ័យផ្គង
នឹងងាយប្រជាប់ សម្រាប់ទ្ជូនផង ព្រះអង្គប្រាប់ហោង
                កំណត់ឡើយណា ។

ទើបអស់អ្នកផង នាំពាក្យនោះហោង រិលវឹងយាត្រា
ទៅទូលមហាក្សត្រ ជូចតាត់ផ្តាំថា សម្ពេចពជា
                ជ្រាបព្រះហប្ចទ័យ ។

បន្ទូលត្រាស់ថា អើតាមពិតណា ជូចពាក្យនោះនៃ
ម្នាលអស់អាជ្ញា ធាប់ក៉ៃ ។ រួសរត់ច្រៀវនៃ
                ទៅក៉ធាប់ហោង ។

ថាអញឲ្យហៅ អញទឹងប្រើទៅ ប្រយុទ្ធលេងលង
ទឹងយក្ខនោះណា គុហានេះម្តង ឲ្យវាមកហោង
ឆាប់ៗកុំលង់ ។

រីអស់អាផ្កា ស្វេតម៉ែមា ជូនដល់កំពង់
ប្រាប់ពោធិសត្វ ថាត្បិតព្រះអង្គ ព្រះបិន្តាបង់
ប្រើទៅឯងហោង ។

តទឹងយក្សា នៅក្នុងគុហា កាលនោះឯងម្តង
បើទៅប្រដាប់ សម្រាប់ខ្លួនហោង ស្តេចទឹងឲ្យលង
តទឹងយក្សា ។

ព្រះពោធិសត្វ ឆ្លើយស្នងវិញថ្វាត់ ទឹងអស់អាផ្កា
ថាទទួលហោង រងតាងកជា ស្លាប់រស់ក្តីណា
មិនគិតខ្លួនឡើយ ។

ហៃអស់អាផ្កា បើអញយាត្រា ដើរទៅទៅហើយ
យក្សយល់ហើយណា វាថាមេអើយ បើម៉្លះទៅហើយ
ទឹងកស្ត្រមោះណា ។

ថាបើក្សត្រថ្ងៃ មានព្រះហឫទ័យ ឲ្យអញទៅជា
ចំណីនៃយក្ស សូមឲ្យក្សត្រា ប្រដាប់ប្រដា
វិស័យស្តេចហោង ។

កាផ្សារិលទៅ ទូលគាល់ព្រះចៅ ក្សត្រក្សាន្តកន្ទុង
ថ្ងែងដោយបណ្ដាំ ស្ដេចផ្ដាំនោះហោង ស្ដេចស្ដាប់ត្រាស់ស្នង
ថាគាប់ពិតណា ។

ស្ដេចសន្មតឲ្យ ព្រះមកុដដោយ អាភមកូសា
ព្រះពស្ត្រដែលទ្រង់ កណ្ដាលទិព្វា ព្រះពស្ត្រយសយង់
អាភ៌មកយរតន៍ ។

អាផ្សារួសរត់ នានាំព្រះមកុដ ជូនពោធិសត្វ
ថ្ងែងថាចៅរ៉ឺយ អញឲ្យទៅថ្វាត់ គ្រឿងនេះថ្លៃក្លាក់
ដែលព្រះអង្គទ្រង់ ។

ព្រះអង្គស្ដេចដាក់ ឲ្យចៅឯងពាក់ ព្រះពស្ត្រយសយង់
ចូរចៅយាត្រា ឆាប់ណាកុំលង់ ត្បិតព្រះអង្គទ្រង់
ចន្ទឹងចៅហោង ។

ព្រះវរវង្ស ស្ដាប់ពាក្យអាផ្សា ហើយធ្វើវើងស្នង
ថាគ្រឿងនេះនៃ ថ្វាថ្លៃកន្ទង ឥឡូវនេះដ្ឋង
ព្រះអង្គករុណា ។

ឲ្យអញឯងពាក់ ប្រយុទ្ធនឹងយក្ស គាងព្រះ"ដា
ស្មានជាជំនិះ ជាន់ជិះយាត្រា ដូរទឹងអាត្មា
ប្រដាប់ប្រពៃ ។

ចូលអ្នកយាត្រា នាំពាក្យនោះណា ទៅទូលក្សត្រថ្លៃ
ថ្លែងដោយបណ្ដាំ អញផ្ដាំនេះនៃ ឲ្យជ្រាបហឫទ័យ
សម្ដេចក្សត្រា ៗ
អាត្មាស្លាប់ហើយ ពុំផ្សេផ្សងឡើយ វិលវិញម្ដា
រូបរត់ដាលដល់ មណ្ឌលប្រាជ្ញប្រា- សាទសួគ៌សោភា
ចូលទូលក្សត្រថ្លៃ ៗ
ថ្លែងដោយវាចា បណ្ដាំនោះណា ជ្រាបព្រះហឫទ័យ
ទើបព្រះចក្រី យកដំរីជ័យ ចងគ្រឿងប្រពៃ
ប្រដាប់ពណ្ណរាយ ៗ
ក្លិនក្រស់បន្សំ នូវអភិរម្យ ស្វេតច្ឆត្រឆាយ
រយាបរយ៉ុំ គ្រសុំគ្រសាយ វែងរួតរំកាយ
រំហើយសាកសែង ៗ
នូវគ្រឿងសហាស ប្រូងប្រាងប្រចាស ប្រទើសត្រួខែទ
ឯអស់កំណាន់ ករកាន់ខ្នះខ្នែង មៀងមើលស្ងប់ស្ងែង
ទូទ័រមហិមា ៗ
នូវអស់គៀវផង ក្រាស់ក្រៃកន្ទង់ គ្រប់គ្រឿងនោះណា
សម្រាប់មហាក្សត្រ ចក្រវត្តិរាជា ស្ដេចតែងយាត្រា
ប្រក្រតីសព្វជង ៗ

ទើបក្សត្រឥស្សូរ ស្រេចស្ដេចបន្ទូល នូវអស់អ្នកផង
ថាចូរយើងឆាប់ ឡើងទៅជួបផ្គង នានាំទៅហោង
ទទួលវរវង្ស ៗ
គ្នាថ្លែងប្រាប់ ឲ្យមកឆាប់ៗ កុំឲ្យផ្សូរផ្សង
ថាអញមើលផ្លូវ ឥឡូវនេះវង ឲ្យទៅវរវង្ស
មកឆាប់មីមា ៗ
ទើបអស់អ្នកផង ក្រញូក្រោបក៏បវង ទទួលអាជ្ញា
សព្វគ្រប់សេបគ្រេប ស្រោប់ស្រេចក្រោបលា នាំអស់នោះណា
ដូចដល់គំពង់ ៗ
ទើបអស់សេនា ថ្លែងប្រាប់អាជ្ញា ប្រាប់ទៅវរវង្ស
ថាគ្រឿងនេះថ្ងៃ ប្រពៃដែលគ្រង សម្ដេចស្ដេចទ្រង់
ឲ្យមកទៅហោង ៗ
អញ្ចើញទៅឆាប់ កុំទៅលីលាប់ សសោះគន្លង
ប្រដាប់ស្កល់ស្កប់ សព្វគ្រឿងជាម្ដង កុំឲ្យមានខ្ទង
នូវចិត្តចិន្ដា ៗ

បទពំនោល

កាលនោះទៅវរវង្ស ទទួលអាជ្ញា ស្រេចហើយប្រដាប់ព្រះអង្គ ៗ
ពាក់មកុដរ័ត្នរាយយល់យង់ កណ្ដាលទិព្វទ្រង់ កាក់មនូវតំណិហ្វក់ ៗ

ទ្រង់ព្រះពស្ត្រពៃលៀបណាក់ សែស្បូត្រសរយ៉ាក់ ប្របាក់ប្រទេសក្នុកក្បៀ ។
ស្រេចស្តេចឡើងគង់ដំរី សឹងមានឫទ្ធិជ័យ ប្រដាប់នូវគ្រឿងចាំងឡាយ ។
បង្កំផ្កាក់ឈ្មាន់ធាធាយ ទង្គត់រ័តនកាយ កញ្ចោងកញ្ចាក់យង់យល់ ។
ព្រះហស្តប្រកបទ្រើសទ្រង់ កង្វេរមាសផ្គង់ ប្រសើរប្រសិទ្ធឧត្តម ។
ស្វេតច្ឆត្រត្រែត្រ័ត្នត្រសុំ ក្លឹងក្លស់អភិរម្យ ហាម៉ែរបៃមទៃសេនគ្មាន់ ។
ពលពាលហៃៗខ្ទាប់ខ្ទាន់ ក្រាស់ក្រៃច្រើនដាន់ បីកង់រំពងប្រថពី ។
សព្ទស្គរនូវតូរ្យតន្ត្រី ត្រៃសន្ធិកើរ ស្រវៃប្រទុំសព្ទគ្នា ។
ជើងគោក ជើងជ័យមហិមា ជើងយសសក្តា បីជើងជាយាជើងអង្គ ។
ពុំយល់ជាចៅវរវង្ស យល់ហាក់ដូចអង្គ ព្រះឥន្ទឥស្សរសួគ៌ា ។
គង់លើដំរីព្វាក ពលពាលមហិមា ក៏ហោះអំពីត្រៃត្រឹង្ស ។
កាយកង្កើយនរប្រែប្រឹង បើកបរស្រស់ស្រឹង បីដូចនូវហោះវេហាស៍ ។
ស្រេចដល់មណ្ឌលកជា ពីរព្រះក្សត្រា ស្តេចដូចស្រឡាញ់ស្នេហ៍ស្និទ្ធ ។
កាលនោះព្រះបាទសោទត្ត អរឯងពេញចិត្ត ក៏ស្តេចបន្ទូលឲ្យហៅ ។
ស្រេចចៅវរវង្សឡើងទៅ អង្គុយនិត្យទៅ ក៏ផ្តោះអំពីបុរី ។
ក្រញូក្រាបស្រប៉ាបសិរសី ថ្វាយវរវន្ទិយ៍ បង្គំប្រណម្យប្រណិប័តន៍ ។
កាលនោះព្រះបាទសោទត្ត បន្ទូលត្រាស់ថ្វាត់ សំណេះពីព្រះទ័យា ។
ជាហៃចៅវរវង្សា អញឲ្យហៅបា មកអញទឹងប្រើបាទៅ ។
ប្រយុទ្ធទឹងយក្សយោរយៅ មហិមាមកនៅ ខាក្នុងគុហាយ៉ាងមឿង ។

បើបានមានដ័យថ្ពស់ថ្លៃដ ដ័យបានរុងរឿន ឥតអ្នកណាស្នើបានម្ពន ។
អញជាកំពង់ឲ្យបានគ្រន ជាស្តេចស្តេងហោង អង្គអញនៅជាឧបរាជ ។
លែងបានមហិមាឯងអាច ផ្ទាញ់យក្សកំណាច ក៏លុះកណ្តាប់ដៃបា ។
នោះទើបចៅវរវង្ស ស្តាប់ព្រះអាជ្ញា បង្គំប្រណម្យទៀនទូល ។
បពិត្រព្រះបាទឥសូរ ក្សត្រថ្ងៃត្រកូល ចាំងពីព្រះអង្គពជ ។
សូមទានសូមព្រះខ័ន្ធ សូមព្រះករុណា ឲ្យទានមកអញខ្ញុំហោង ។
ខ្ញុំទៅប្រយុទ្ធលេងលង ទ្រង់យក្សនេះម្ពន ក៏តាមបុកណាខ្ញុំណា ។
បើខ្ញុំចាញ់ដៃយក្ស យក្សវ៉ាកោក្ត ក៏ស្ងាប់ពុំគិតខ្ជូនឡើយ ។
ព្រះបាទសោទត្តស្តាប់ហើយ ស្តេចបន្ទូលឆ្លើយ ថាវៃហៅចៅវរវង្ស ។
យក្សនោះនៅកន្លែងគុហា ក្រមក្ដាត់ណា យកថ្មសន្ធប់ទ្វារផង ។
ទើបចៅវរវង្សទូលសួន ថាបើច្នេះហោង សូមទានសូមព្រះករុណា ។
ឲ្យពលប្រាំពាន់សហស្ស បើកទ្វារគុហា ចានខ្ញុំចូលទៅប្រយុទ្ធ ។
ស្តេចស្តាប់ហើយត្រាស់ចំហុត ស្រាលវ៉ើសពលសុទ្ធ តែមានកម្លាំងមហិមា ។
ស្រេចឲ្យបើកទ្វារគុហា ចាំងប្រាំសហស្ស ក្រមកក្រឹកដល់ជាច់ ។
ឯចៅវរវង្សស្រាប់ស្រេច ថ្វាយបង្គំស្តេច ក៏ចុះមកដល់គុហា ។
មើលអស់ពលប្រាំសហស្ស ត្រួតបើកត្រមគ្នា ក៏ពុំរបើកឡើយហោង ។
ស្រេចទើបចៅវរវង្សផ្ទាន អស់ទៅតាមផង សំ&ដួយបុទ្ធីបេស្ត ។

មណោភាពនៃលោក យឿន - ចឹម

អតីតអគ្គលេខាធិការនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

នៅក្នុងខែឧសភា ១៩៧០ បុគ្គលិកទាំងអស់នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ មានសេចក្តីសោកស្តាយយ៉ាងខ្លាំង ចំពោះមរណភាពនៃលោក យឿន - ចឹម ជាអតីតអគ្គលេខាធិការនៃវិជ្ជាឋាននេះ ។

ទោះបីជា នៅពេលដែលប្រទេសជាតិ កំពុងមានការមមាញឹកយ៉ាងណាក្តី មិត្តភ័ក្តិនៃសព ក៏នាំគ្នាធ្វៀតទៅជួយឧបត្ថម្ភក្នុងពិធីបុណ្យសពរហូតដល់ពេលដង្ហែទៅធ្វើឈាបនកិច្ចនៅវត្តបទុមវតី ពីថ្ងៃ ១ មិថុនា ១៩៧០ ម៉ោង ៨ ព្រឹក ជាអាទ៍មាន ឯ.ឧ. ឯកា យីអ៊ុន អនុប្រធានរដ្ឋសភា ឯ.ឧ. វរសេនីយទោ ហ៊ុយ - ម៉ោង, ឯ.ឧ. ប្រធានសមាគមមន្ត្រីនិវត្តន៍ ព្រមទាំងអស់លោកជាច្រើនទៀត ដែលយើងសូមអភ័យទោសដោយរៀបរាប់នាមពុំអស់ក្នុងទីនេះ មួយអន្ទើនឹងមន្ត្រីរដ្ឋការនៅពុទ្ធសាសនបណ្ឌិត្យទាំងអស់ ។ ផ្នែកព្រះសង្ឆ មានមន្ត្រីសង្ឆជាន់ខ្ពស់ចូលរួបរួមដែរ ជាអាទិមាន ព្រះមុនីកោសល ស្ងូរ - ហាយ ព្រះពុទ្ធាចារ្យ ហ៊ុ - ជា ជាដើម ។

ដើម្បីជូនជ្រាបអំពីប្រវត្តិ និងសកម្មភាពនៃលោក យឿន - ចឹម យើងសូមចុះផ្សាយទាំងស្រុងនូវសុន្ទរកថា របស់ សហ. លាង-ហ៉ាប-អាន នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យបច្ចុប្បន្ន ដូចតទៅ ៖

លោក យ្យើន - ចឹម

អតីតអគ្គលេខាធិការ ពុទ្ធសាសនបណ្ឌិត្យ

កើតនៅឆ្នាំ ១៩០៩ ទទួលអនិច្ចកម្មនៅថ្ងៃទី ២៨ ឧសភា ១៩៦០

សូមនស្ការព្រះករុណាគ្រប់ព្រះអង្គ !

សូមគោរព ឯកឧត្តម អស់លោក-អ្នក និងមិត្តភ័ក្ត្រទាំងឡាយ

ជាបឋម, ខ្ញុំព្រះករុណា-ខ្ញុំ សូមថ្វាយអំណរគុណយ៉ាងក្រៃលែង ចំពោះព្រះករុណាគ្រប់ព្រះអង្គ និងឯកឧត្តម អស់លោក-អ្នក និងមិត្តភ័ក្ត្រ អស់ ដែលមានព្រះទ័យ-មានចិត្តសប្បុរស ធ្វើតតុកាសនិមន្ត-អញ្ជើញ មកជាអធិបតី និងជាកិត្តិយស ក្នុងពិធីបុណ្យបូជាសពលោក យ៉ឿន-ចឹម នេះ ។

បន្ទាប់ពីនេះ ខ្ញុំព្រះករុណា-ខ្ញុំ សូមថ្វាយដោយសង្ខេបនូវជីវប្រវត្តិ របស់លោម យ៉ឿន-ចឹម ដូចតទៅ :

លោក យ៉ឿន-ចឹម កើតនៅឆ្នាំ ១៩០៩ ក្នុងសង្កាត់លេខ ៦ ក្រុងភ្នំពេញ ។ ជាបុត្រច្បងនៃបិតា នាម កិម-យ៉ឿន និងមាតានាម ឆាង-ឫទ្ធុ កាលពីកុមារ ចានចូលសិក្សាអក្សរសាស្ត្រ នៅសាលា ឧដ្ឋាដ៏ឡាត្រ ។ ក្រោយពីចានប្រឡងជាប់វិញ្ញាបនបត្រថ្នាក់ទី១ ចាប់ផ្តើម-ខែវិច្ឆិកាហើយមក, លោកចានប្រឡងជាប់ចូលធ្វើការនៅក្រសួងពេទ្យសត្ត ក្នុងវ័យអាយុ ១៨ឆ្នាំ១ខែ, មិនយូរប៉ុន្មាន សុំចេញពីក្រសួងពេទ្យសត្ត ទៅចូលធ្វើការនៅចំការកៅស៊ូ-ពេជ្ន កំពង់ចាម ។ តមក, សុំចេញពីកន្លែងនេះ ទៅចូលធ្វើការនៅក្រុមហ៊ុនកាយន្ត ចាប់ផ្តើមនៅក្រុងភ្នំពេញ គឺរោងកាយន្តអេដែនសត្ត ។ ធ្វើការនៅទីនេះ ក៏មិន

បានជាយូរប៉ុន្មាន បានសុំលាឈប់ទៅទៀត ។

—នៅថ្ងៃ ទី ១ ខែ កញ្ញា គ.ស. ១៩៣០, លោក យៀង-ជឹម មានអាយុ ២១ ឆ្នាំ បានត្រូវតែងតាំងជាលេខាធិការនៅព្រះរាជបណ្ណាល័យ គឺវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យសព្វថ្ងៃនេះឯង ។

—នៅឆ្នាំ ១៩៤៣, លោក យៀង-ជឹម បានត្រូវតែងតាំងជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។

—នៅចុងឆ្នាំ ១៩៥០, គ្រាដែលបារាំងបានប្រគល់ពុទ្ធសាសនបណ្ឌិត្យ មកឲ្យរាជការខ្មែរ, លោក យៀង-ជឹម បានត្រូវតែងតាំងជាអគ្គលេខាធិការ គឺជានាយកនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ។ ក្នុងឆ្នាំដដែលនេះ, រាជការមុខក្រសួងបានដំឡើងឋានន្តរសក្តិរបស់លោកជាអនុមន្ត្រីថ្នាក់លេខ ១ ជាបក្ខសន្យា (Contractuel assimilé) មានប្រាក់បៀវត្សរ៍ស្មើគ្នានឹងមន្ត្រីរដ្ឋបាលថ្នាក់នេះ ។ តពីនេះមក, លោកបានឡើងឋានន្តរសក្តិជាបន្តបន្ទាប់គ្នា ដូចជាមន្ត្រីរដ្ឋបាលឯទៀតៗដែរ ដរាបមកដល់ឆ្នាំ ១៩៦៤ បានឡើងជាឧត្តមមន្ត្រីថ្នាក់លេខ ២ ។ ចំណែកប្រាក់ត្រែតលោកបានកាត់បង់ទុកនៅ បេឡាសោធន ព្រះរាជវាំង តាំងពីលោកចូលធ្វើការជាលេខាធិការនៅព្រះរាជបណ្ណាល័យ ហូរហែដរាបមកទល់នឹងចូលនិវត្តន៍ ។

នៅថ្ងៃទី ១ មករា ១៩៦៥, លោក យៀង-ជឹម បានចូលនិវត្តន៍

ដោយដល់កំណត់អាយុហួសពី ៥៥ ឆ្នាំ ។

ចំណែកកិត្តិយសដទៃទៀត, លោកបានទទួលការតែងតាំងជាមន្ត្រីកិត្តិយស មានគោរម្យងារជា ឧកញ៉ានាយកមន្ត្រី សក្តិ ៧ ហ្ចិញាន់ និងមានគ្រឿងឥស្សរិយយសជាច្រើន ។

ព្រះករុណាគ្រប់ព្រះអង្ត ।

ឯកឧត្តម អស់លោក-អ្នក ជាមិត្តទាំងឡាយ

តាមការដែលបានរៀបរាប់មកត្រួស ។ នេះ យើញថា លោកយ្រឿន-ឌឹម ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ តែមួយកន្ទែងឥតមានផ្ទាស់ប្តូរទៅទីដទៃទៀតទេ តាំងពីឆ្នាំ ១៩៣០ មកទល់នឹងឆ្នាំ ១៩៦៥ ដែលត្រូវចូលនិវត្តន៍ បូករួមជា ៣៥ ឆ្នាំ ។

ក្នុងរយៈកាលដែលលោកបានបំពេញមុខការនៅព្រះរាជបណ្ណាល័យនិងពុទ្ធសាសនបណ្ឌិត្យតាំងពីដើមទីមក, លោកយ្រឿន-ឌឹម បានយកចិត្តទុកដាក់ជាទីបំផុត ឥតប្រហែសធ្វេសក្នុងមុខការដល់ម្ពងណាសោះ គឺជាអ្នកស្រឡាញ់ការ កាន់ការខ្ជាប់ខ្ជួន មានចិត្តនិងស្មារតីរឹងប៉ឹងនឹងនមុតហំ មានព្យាយាមនិងអំណត់ក្នុងមុខការ មានអធ្យាស្រ័យស្មោះស្មើចំពោះមិត្តទួទៅ បានជាទីស្រឡាញ់រាប់អាននៃបុគ្គលិកក្នុងក្រសួងទាំងបញ្ចដិតទាំងគ្រហស្ត ។

ឯកិច្ចការផ្នែកខាងបោះពុម្ពផ្សាយសៀវភៅព្រះពុទ្ធសាសនា ជាពិ-

សេស សៀវភៅព្រះត្រៃបិដក ហើយនិងសៀវភៅអក្សរសាស្ត្រជាច្រើន នៅពុទ្ធសាសនបណ្ឌិត្យ គឺលោក យ៉ែន-ចឹម នេះឯងមួយរូបវែរ ដែលជាអ្នកដឹកនាំ ចាត់ចែងកិច្ចការទាងវេជ្ជបាល តាមសមត្ថភាពឲ្យបានសម្រេចសមតាមចំណងរបស់ពុទ្ធបរិស័ទនិងអ្នកសិក្សាទាំងឡាយ ដោយរួមកម្លាំងគ្នាជាមួយបុគ្គលិកបច្ចេកទេស ភេទបញ្ជីតនិងគ្រហស្ថទាំងអស់ នៅពុទ្ធសាសនបណ្ឌិត្យ គឺថាលោកជាអ្នកជួយត្រួសត្រាយ ឬកាប់ព្នាវផ្លូវមួយរូបធំ មានឧបការគុណយ៉ាងធំធេងនៅក្រុមនេះ ជាដំបូងដែ ក្នុងចំណោមអ្នកត្រួសត្រាយទាំងឡាយ នៃពុទ្ធសាសនបណ្ឌិត្យ ។

ប៉ុន្តែ គួរឲ្យសោកស្តាយណាស់; ក្នុងថ្ងៃទី ២៨ ខ្សែ ១៩៧០ ស្រាប់តែបានទទួលដំណឹងថា លោក យ៉ែន-ចឹម បានទទួលមរណ-ភាពទៅហើយ ។ បុគ្គលិកនៅពុទ្ធសាសនបណ្ឌិត្យ ទាំងបញ្ជីតទាំងគ្រហស្ថមានសេចក្តីក្រៀមក្រំយ៉ាងក្រៃលែង ចំពោះមរណភាពនៃវេជ្ជ-បណ្ឌិតយើងនេះ ។

លោកស្រី យ៉ែន-ចឹម

អស់លោក-អ្នកជាក្រុមគ្រូសារទាំងអស់

ឯកឧត្តមនៃបុគ្គលិកនៅពុទ្ធសាសនបណ្ឌិត្យ ទាំងបញ្ជីតទាំងគ្រហស្ថ ខ្ញុំសូមចូលរួមកាន់មរណៈទុក្ខយ៉ាងក្រៀមក្រំ ជាទីបំផុតជាមួយលោកស្រីនិងគ្រួសារ ចំពោះមរណភាពនៃលោក យ៉ែន-ចឹម ។ យើងខ្ញុ

មានសេចក្ដីស្តាយមួយចំណែកទៀត, ស្តាយហើយស្តាយទៀត, ស្តាយ
ត្រង់យើងខ្ញុំ ពុំបានជួយឧបត្ថម្ភតាំទ្រយ៉ាងពេញទំហឹងក្នុងពិធីបុណ្យសព
លោក យ្រឿន-ចឺម ឲ្យបានសមរម្យទៅតាមគុណូបការៈរបស់លោក
ដោយហេតុកាលទេសៈបច្ចុប្បន្ទនៃប្រទេសយើងកំពុងតឹងតែង ជួបលោក
ស្រីនិងអស់លោកជាក្រុមគ្រួសារបានជ្រាបស្រាប់ហើយ, ហេតុនេះ សូម
លោកស្រីនិងអស់លោក-អ្នក មេត្តាខន្ធីអភ័យទោសឲ្យទាន ដោយ
អនុគ្រោះផង ។

ទីបំផុត, សូមបួងសួងគុណបុណ្យព្រះរតនត្រ័យ សូមលោកមេត្តា
ជួយឧបត្ថម្ភតាំទ្រវិញ្ញាណក្ខន្ធរបស់លោក យ្រឿន-ចឺម ដែលជាអាទិ-
កម្មិកបុគ្គលនៃពុទ្ធសាសនបណ្ឌិត្យ ឲ្យបានប្រកបដោយសេចក្ដីសុខក្សេម
ក្សាន្តក្នុងសុគតិភព អស់កាលអង្វែងតទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ